រដ្ឋមន្ត្រីៈ «ចូលរួមថែរក្សាសមិទ្ធផលខ្លួន ក្រោមនយោបាយឈ្នះ ឈ្នះ ដើម្បីទុកជូនមនុស្សជំនាន់ក្រោយសិក្សាប្បនសូត្រ» <ទំព័រៈ៣

ត្រីមាសទី១ ឆ្នាំនេះ មនុស្ស៣១នាក់ស្លាប់ដោយសារពុលស្រា ខណៈក្រសួងឱ្យមានការគ្រប់គ្រងម៉ឺងម៉ាត់ <ទំព័រៈ១៥

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១២

# អ្នកនាំសារ

ខែ មេសា | ឆ្នាំ ២០២១ | លេខទី ១៣៨

# the messenger

www.catholiccambodia.org/km/ www.facebook.com/RVAKHMER/ https://khmer.rvasia.org/

April, 2021 | #138

ក្នុងលិខិតរបស់សាលាក្រុងស្តីអំពីការរុះរើឬ បែចល័តចិញ្ចឹមត្រី ផ្ទះបណ្តែតទឹក ផ្ទះទូកតូចៗ និងសំណង់មិនរៀបរយនៅលើផ្ទៃទន្លេ ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ បានទុកពេល១សប្តាហ៍ដើម្បីឱ្យអ្នកដែលរស់នៅ និងធ្វើអាជីវកម្មរុះរើចេញ និងបានបញ្ជាក់ថា ការតាំងទីលំនៅទាំងនេះ គឺខុសនឹងច្បាប់របស់កម្ពុជា ដែលធ្វើឱ្យប៉ះពាល់ដល់ប្រព័ន្ធអេកូឡូហ្ស៊ី មានចរន្តទឹកហូរគោករាក់ ពិសេសការប្រើប្រាស់ចំណីត្រី និងការបញ្ចេញកាកសំណល់ ការបន្ទោបង់ពាសវាលពាសកាលក្នុងទន្លេ ដែលធ្វើឱ្យខូចខាតធ្ងន់ធ្ងរដល់ជីវៈចម្រុះនៅក្នុងទឹក ខូចគុណភាពទឹក បំពុលបរិស្ថាន និងប៉ះពាល់ដល់សោភណ្ឌភាពរាជធានីភ្នំពេញ និងប៉ះពាល់ដល់សុខភាពប្រជាជនដែលប្រើប្រាស់ទឹកមិនស្អាត។

# ប្រជាជនដែលរុះរើផ្ទះបណ្តែតទឹក

## ត្អូញត្អែរអំពីទីលំនៅនិងមុខរបរ

បទយកការណ៍ទំព័រៈ ១២-១៣



ចំនួនសត្វខ្សឹបនៅកម្ពុជាបានថយចុះយ៉ាងគំហុក ទំព័រ-១០

ព្រះសហគមន៍ចូលរួមរំលែកការលំបាករបស់បងប្អូនប្រជាពលរដ្ឋទូទាំងប្រទេសក្នុងស្ថានកូវីដ–១៩ ទំព័រ-១៦-២០



# កូវីដ ១៩ មិនអស់! ជំនឿលើព្រះគ្រីស្តត្រូវស្រពោន?

មេរោគឆ្លង កូវីដ១៩ ចេះតែរីករាលដាលទៅគ្រប់ទីកន្លែងក្នុងពិភពលោកនេះ មិនស្រាកស្រាន្តឡើយ។ មានប្រទេសជាច្រើន នៅបន្តបិទខ្ទប់នៅឡើយ ការជួបជុំ ការធ្វើដំណើរ ចរន្តសេដ្ឋកិច្ចធ្លាក់ចុះជាលំដាប់។ សិស្សានុសិស្ស ជាច្រើនត្រូវផ្លាស់ប្តូររបៀប និងទម្លាប់រស់នៅ និងការរៀនសូត្រតាមប្រព័ន្ធអ៊ីនធើណែត ជំនួសឱ្យការទៅរៀនក្នុងថ្នាក់នៅសាលា។ សាលារៀនទទេគ្មានសិស្ស កន្លែងកីឡាខ្លះស្ងាត់ជ្រងំ ហាងទំនិញខ្លះបិទ ភោជនីយដ្ឋានគ្មានមនុស្សអង្គុយនៅតាមតុ ។ល។ ស្ថានភាពពីមួយថ្ងៃទៅមួយថ្ងៃ មិនច្បាស់លាស់ ម្នាក់ៗភ័យខ្លាចជានិច្ច។







នៅប្រទេសកម្ពុជា យើងវិញ ជាង១០០ថ្ងៃហើយ តាំងពីថ្ងៃទី ២០ កុម្ភៈ មក ចំនួនអ្នកឆ្លងមិនថមថយ ហើយបានសាយភាយ ទៅតាមបណ្តាខេត្តមួយចំនួនទៀតផង។ អ្នកស្លាប់ក៏មានច្រើន ហើយមួយរយៈនេះ មានចំនួនប្រមាណជា១០នាក់ជារៀងរាល់ថ្ងៃ ហើយទិន្នន័យនៅថ្ងៃទី១៧ ខែមិថុនា មាន៣៨០នាក់ហើយ។

រាជរដ្ឋាភិបាលបានខិតខំយ៉ាងខ្លាំងបំផុត ក្នុងការប្រយុទ្ធប្រឆាំងនឹងមេរោគឆ្លងមួយនេះ ដោយអប់រំរំឭក ដាស់តឿន និងដាក់វិធានធ្ងន់ធ្ងរផង។ មានការបិទខ្ទប់ទីក្រុង ខេត្ត រាជធានីជាអន្លើរ បិទផ្សារ ភោជនីយដ្ឋាន សាលារៀន ហាមការជួបជុំគ្រប់ប្រភេទដែលមានមនុស្សច្រើន។ ការជួបជុំបែបសាសនា គឺហាមឃាត់ដាច់ខាត។ គ្មានឡើយពិធីបុណ្យអធឹកអធម តាមវត្ត វិហារ សាសនា ឬស៊ូរ៉ាវ ។ ព្រះវិហារ នៃព្រះសហគមន៍ គ្រប់ទីកន្លែង មិនអាចជួបជុំ អធិដ្ឋាន ឬប្រារព្ធពិធីបុណ្យផ្សេងបានឡើយ។ សម្រាប់គ្រីស្តបរិស័ទ តាមវិន័យ សំខាន់ណាស់ត្រូវ យកពេលដើម្បីលើកតម្កើង ព្រះជាម្ចាស់ នៅថ្ងៃអាទិត្យ។

*តើបងប្អូនមានពិសោធន៍រក្សាជំនឿរបស់ខ្លួនយ៉ាងណាខ្លះ? តើការចូលរួមអភិបូជានៅថ្ងៃអាទិត្យ នឹងសាបរលាបទៅមែនទេ? តើជំនឿរបស់ខ្ញុំ នឹងត្រូវស្រពោនមែន? ខ្ញុំជាកាតូលិក ត្រូវតែទទួលព្រះកាយ បើមិនបានចូលអភិបូជាយូរបែបនេះ មិនអីទេមែនទេ? ខ្ញុំអធិដ្ឋានខ្លួនឯងរាល់ថ្ងៃ មិនចាំបាច់មក ព្រះវិហារក៏បានដែរមែនទេ?*

សំណួរទាំងអស់នេះ តើត្រូវរកចម្លើយយ៉ាងដូចម្តេចឱ្យបានសមរម្យ? តើត្រូវធ្វើដូចម្តេចដើម្បីថែរក្សាជីវិតខាងវិញ្ញាណរបស់ខ្ញុំបានរឹងមាំ?

បងប្អូនជាទីស្រលាញ់ ជាការពិត នៅក្នុងបរិបទ កូវីដ១៩ ម្នាក់ៗភ័យខ្លាច និងរក្សាជីវិតខាងរូបកាយយ៉ាងខ្លាំង ដូចជា ពាក់ម៉ាស បាញ់អាកុល លាងដៃញឹកញាប់ រក្សាគម្លាត។ល។ ក្នុងបំណងការពារខ្លួន កុំឱ្យមេរោគកូវីដ១៩ ចូលក្នុងខ្លួនរបស់យើងផ្ទាល់។ យើងភ័យខ្លាច តែគ្រីស្តបរិស័ទត្រូវយកពេលអធិដ្ឋាន ក្នុងពេលកំពុងមានទុក្ខព្រួយ និងភ័យខ្លាចនេះ។

យើងក្រឡេកមើល ការកសាងព្រះសហគមន៍ឡើងវិញក្នុងដើមទសវត្សន៍១៩៩០ ទោះគ្មានបូជាចារ្យ តែយើងនៅជួបជុំគ្នាបាន តែពេលនេះ យើងមានបូជាចារ្យ តែព្រះវិហារបិទទ្វារហើយ ដើម្បីប្រយុទ្ធនឹងជំងឺឆ្លងកូវីដ១៩។ នេះរំឭក មនុស្សពេញវ័យ ឬគ្រីស្តបរិស័ប្ទមួយចំនួនធំ ជាពិសេសមនុស្សវ័យចំណាស់បន្តិច ឱ្យធ្វើសក្ខីកម្ម អំពីអ្វីដែលលោកអ្នកធ្លាប់បានឆ្លងកាត់។ ការអធិដ្ឋាន អភិបូជាពិតណាស់ គ្រីស្តបរិស័ទត្រូវទៅវិហារ ដើម្បីរួមគ្នាជាព្រះសហគមន៍។ ប៉ុន្តែក្នុងកាលៈទេសៈនេះ យើងក៏ត្រូវទទួលស្គាល់។

ការអធិដ្ឋាន រួមគ្នារបស់សមជិក គ្រួសារនៅតាមផ្ទះក៏ជាព្រះសហគមន៍តូចមួយដែរ ជារូបកាយរបស់ព្រះគ្រីស្ត។ ព្រះយេស៊ូមានព្រះបន្ទូលថា«ដ្បិតនៅទីណាមានពីរឬ បីនាក់ជួបជុំគ្នាក្នុងនាមខ្ញុំ ខ្ញុំក៏ស្ថិតនៅទី នោះជាមួយគេដែរ»។ (ម៉ាថាយ ១៨,២០)។ យើងត្រូវរួមចិត្តគំនិតតែមួយ ប្រើប្រាស់សម្ភារដែល ព្រះសហគមន៍ បានរៀបចំ ដូចជា៖ អត្ថបទទី១ ទី២ ទំនុកតម្កើង ព្រះគម្ពីរដំណឹងល្អជាដើម ឬក៏យើងអាចចូលរួមការផ្សាយផ្ទាល់អភិបូជា តាមប្រព័ន្ធអ៊ីនធើណែត ដែលរៀបដោយព្រះវិហាររបស់បងប្អូន ឬភូមិភាគរបស់បងប្អូនផ្ទាល់។

### *តើចូលរួមអភិបូជាតាមប្រព័ន្ធអនឡាញមានប្រយោជន៍អ្វីទៅ?*

ពិតណាស់ការជួបជុំបែបនេះមិនអាចជំនួស នូវអភិបូជាផ្ទាល់នៅព្រះវិហារដែលយើងអាចទទួល ព្រះកាយបាននោះ។ ប៉ុន្តែក្នុងស្ថានភាពបែបនេះ យើងត្រូវទទួលស្គាល់និងត្រូវសម្របខ្លួនតាមបរិបទថ្មី។ មួយទៀត ថ្ងៃអាទិត្យជាថ្ងៃសម្រាប់ព្រះជាម្ចាស់ យើងត្រូវរក្សា ញែកថ្ងៃនេះសម្រាប់ព្រះជាម្ចាស់ជានិច្ច ទោះបីក្នុងស្ថានភាពបែបណាក៏ដោយ។ ពេលចូលរួមអភិបូជាផ្សាយផ្ទាល់ ត្រូវយកចិត្តទុកដាក់ និងរួមចិត្តគំនិត យ៉ាងពិតប្រាកដ ជាមួយបូជាចារ្យ និងបងប្អូនឯទៀតៗ ជាបុត្រធីតារបស់ព្រះជាម្ចាស់ ដែលចូលរួមដែរ។ ប្រការដូច្នេះហើយ ចូលរួមអភិបូជាក្នុងពេលផ្សាយផ្ទាល់ មិនមែនដូចយើងទស្សនាវីដេអូ តាមអនឡាញនោះទេ គឺត្រូវឆ្លើយ តាមដំណាក់កាលនីមួយៗ ស្តាប់ព្រះបន្ទូល សូត្រទំនុកតម្កើង ស្តាប់ទេសនា និងចូលរួមថ្វាយសក្ការបូជា។ យើងទទួលព្រះកាយក្នុងផ្លូវវិញ្ញាណ ក្នុងពេលនោះដែរ។

សូមយកចិត្តទុកដាក់ យកពេលអធិដ្ឋានរួមគ្នា ជាគ្រួសារតែមួយ៕

## តើត្រូវរៀបចំខ្លួនបែបណា?

ងាយស្រួលណាស់ បងប្អូនធ្លាប់បានរៀបចំខ្លួនដើម្បី ចូលរួមអភិបូជានៅព្រះវិហារ ទាំងសំលៀកបំពាក់ សមរម្យ ទាំងចិត្តគំនិតជ្រះថ្លា។

*រៀបចំកន្លែងឱ្យបានសមរម្យ ដើម្បីមានបរិយាកាសល្អ ឬមានកន្លែងអង្គុយល្អសម្រាប់សមាជិកគ្រួសារចូលរួមទាំងអស់គ្នា។

*ត្រូវរៀបចំចិត្តគំនិត ជាស្រេច ឱ្យបាន៥នាទីមុខការផ្សាយផ្ទាល់ចាប់ផ្តើម ។

*អុជទាន មុនអភិបូជាចាប់ផ្តើម

*ចូលរួមឆ្លើយ តាមពាក្យអធិដ្ឋាននីមួយៗ ឱ្យបានឮៗ

*ឆ្លើយ ឆ្លងពេលបានស្តាប់ព្រះបន្ទូល ទទួលព្រះបន្ទូលរបស់ព្រះជាម្ចាស់ យកចិត្តទុកដាក់ស្តាប់ ធម្មទេសនា។

*ចូលរួមច្រៀងឱ្យបានអស់ពីចិត្ត ។

កត្តាទាំងនេះហើយ ជួយឱ្យបងប្អូនអាចចូលរួមជាមួយព្រះសហគមន៍ ដែលជាគ្រួសារដ៏ធំរបស់បងប្អូនក្នុងផ្លូវវិញ្ញាណបាន និងអាចជួយគ្រួសារដ៏តូចរបស់បងប្អូនឱ្យរឹងមាំខាងផ្លូវវិញ្ញាណថែមទៀត។

យើងរួមគ្នាអធិដ្ឋាន សូមឱ្យជំងឺកូវីដ១៩ រលត់ចេញពីពិភពលោកនេះ៕

CSC
Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ចាងហ្វាង : លោក លី សុវណ្ណា
សេចក្តីប្រកាសលេខ៖ ០៦០/១៩ ព.ម.រ.ល.អ/ ១៥-មករា-២០១៩
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Tel/Fax : (855) 23 224 120
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh

# រដ្ឋមន្ត្រីការពារជាតិ៖ «ចូលរួមថែរក្សាសមិទ្ធផលខ្លួន ក្រោមនយោបាយឈ្នះឈ្នះ ដើម្បីទុកជូនមនុស្សជំនាន់ក្រោយសិក្សារៀនសូត្រ»

*អត្ថបទ៖ ផល សុផានិត*

លោក ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ បានអំពាវនាវឱ្យក្រសួងស្ថាប័នដទៃទៀត ផ្តល់សមិទ្ធផលខ្លួន ក្រោមនយោបាយឈ្នះឈ្នះ ដើម្បីទុកជូនមនុស្សជំនាន់ក្រោយសិក្សារៀនសូត្រ។

ការលើកឡើងរបស់លោកបានធ្វើឡើងនាព្រឹកថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២១ នៅវិមានឈ្នះឈ្នះជាទីដែលដំណក់ប្រេងលើកដំបូងរបស់កម្ពុជា ត្រូវបាននាំយកមកតម្កល់ទុក ដើម្បីទុកជាមរតកសម្រាប់កុលបុត្រខ្មែរ និងជាការចងចាំនូវសមិទ្ធផលកើតចេញម្លប់សុខសន្តិភាព ដែលរកបានមកដោយនយោបាយឈ្នះ-ឈ្នះ របស់សម្តេចតេជោ ហ៊ុន សែន។

លោក ទៀ បាញ់ បានបញ្ជាក់ដូច្នេះថា៖ «ខ្ញុំមានសង្ឃឹម និងរំពឹងទុកយ៉ាងមុតមាំថា ក្រសួងស្ថាប័ននានា នឹងបន្តចូលរួមឱ្យកាន់តែសកម្មផុលផុសថែមទៀត នៅក្នុងការផ្តល់វត្ថុតឹកតាង និងឯកសារប្រវត្តិសាស្ត្រ ដែលជាសមិទ្ធផលតាមរយៈនយោបាយឈ្នះឈ្នះ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ដើម្បីទុកជូនមនុស្សជំនាន់ក្រោយបានសិក្សារៀនសូត្រ»។



លោកក៏បានអំពាវនាវដល់ក្រសួងស្ថាប័នពាក់ព័ន្ធបន្តចូលរួមគាំទ្រអភិវឌ្ឍសារមន្ទីរមគ្គទេសក៍តេជោសែននេះ ទៅតាមតួនាទីភារកិច្ចរៀងៗខ្លួនឱ្យកាន់តែរីកចម្រើនថែមទៀត តាមរយៈការផ្តល់វត្ថុតឹកតាង និងឯកសារពាក់ព័ន្ធ ដែលជាសមិទ្ធផលសំខាន់ៗសម្រេចបានជាប្រវត្តិសាស្ត្រ តាមរយៈនយោបាយឈ្នះ ឈ្នះ ដើម្បីក្រុមការងារតម្កល់ទុកក្នុងសារមន្ទីរវិមានឈ្នះ ឈ្នះ សម្រាប់ទុកជូនមនុស្សជំនាន់ក្រោយសិក្សារៀនសូត្រ ដូចដែលក្រសួងរ៉ែ និងថាមពលបានប្រគល់ជូននាថ្ងៃនេះ ជាសក្ខីភាពស្រាប់។

លោក ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល បានថ្លែងឡើងផងដែរថា ដំណក់ប្រេងដំបូងរបស់កម្ពុជាក្នុងបរិបទសេដ្ឋកិច្ចពិភពលោកដ៏លំបាកដែលគំរាមកំហែងដោយមេរោគរាតត្បាតកូវីដ-១៩ គឺជាសក្ខីភាពនៃការខិតខំប្រឹងប្រែងអំណត់ព្យាយាម និងពុះពារសម្រេចជោគជ័យរបស់រាជរដ្ឋាភិបាលនិងវិនិយោគគិន ដែលទាំងអស់គ្នាសូមចូលរួមកោតស្ញប់ស្ញែង។

លោកបានមានប្រសាសន៍ថា៖ «កែវដំណក់ប្រេងដំបូងនេះ គឺជានិមិត្តរូបនៃធនធានប្រេងកាតរបស់ព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានរៀបចំឡើងតាមរចនាបទខ្មែរ និងសូមប្រគល់ជូនសម្តេចពិជ័យសេនាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង ការពារជាតិ និងជាប្រធានគណៈកម្មការសាងសង់វិមាននយោបាយឈ្នះឈ្នះ ដើម្បីតំកល់ទុកជាប្រវត្តិសាស្ត្រ»។

អត្ថន័យសំខាន់ៗ នៃកែវដំណក់ប្រេងដំបូងរបស់កម្ពុជានេះគឺ កែវដំណក់ប្រេងមានទម្រង់ក្រពុំឈូក ឬស្លឹកពោធិតំណាងឲ្យ ភាពរុងរឿងបរិសុទ្ធ ការចម្រើនលូតលាស់ដែលជាកំណប់ទ្រព្យរបស់កម្ពុជា។ កែវដំណក់ប្រេងមានកម្ពស់ ២៩ សង់ទីម៉ែត្រ តំណាងឲ្យថ្ងៃទី២៩ ដែលទទួលបានដំណក់ប្រេងដំបូងរបស់កម្ពុជា។

ជើងពានត្របកឈូក តំណាងឲ្យសេចក្តីខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំរហូតទទួលបាននូវលទ្ធផលផ្លែផ្កា គឺការទទួលបាននូវធនធានប្រេងកាតសម្រាប់អភិវឌ្ឍជាតិមាតុភូមិកម្ពុជា។ ជើងពានត្របកឈូក មានកម្ពស់ ១២ សង់ទីម៉ែត្រ តំណាងឲ្យខែ១២ ឬខែធ្នូ ដែលទទួលបានដំណក់ប្រេងដំបូងរបស់កម្ពុជា។

ចំណែកពានជើងសឹង្ហ និងឋានជើងបាត តំណាងឲ្យការជ្រោមជ្រែងរបស់ប្រជាជនកម្ពុជា និងមន្ត្រីរាជការដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល និងមន្ត្រីពាក់ព័ន្ធនានាក្នុងការខិតខំប្រឹងប្រែងធ្វើការងារ ទាញយកភោគផលនៃធនធានធម្មជាតិដើម្បីយកមកអភិវឌ្ឍសង្គមជាតិ។ ពានជើងសឹង្ហ និងឋាន ជើងបាត មានកម្ពស់ ២០ សង់ទីម៉ែត្រ តំណាងឲ្យឆ្នាំ២០២០ ដែលទទួលបានដំណក់ប្រេងដំបូងរបស់កម្ពុជា។

ក្បាច់កញ្ចាំងភ្លីភ្លើងលម្អដោយនាគក្បាលបី តំណាងឲ្យ តេជៈ ភាពចម្រុងចម្រើន សម្បូរសប្បាយ និងតំណាងឲ្យឆ្នាំរបស់សម្តេចតេជោ ហ៊ុន សែន ជាសម័យកាលដែលទទួលបាននូវដំណក់ប្រេងដំបូងរបស់កម្ពុជា។ ឯ និមិត្តរូបរួមនៃដំណក់ប្រេងដំបូងរបស់កម្ពុជាត្រូវបានប្រសិទ្ធនាមថា បឋមតេលពិន្ទុកម្ពុជា។ បឋមតេលពិន្ទុកម្ពុជា (ភាសាបាលី មកពីពាក្យ បឋម ប្រែថាដំបូង + តេល ប្រែថាប្រេង + ពិន្ទុប្រែថាដំណក់ + កម្ពុជា គឺប្រទេសកមជា។ ប្រែជារួមថា «ដំណក់ប្រេងដំបូងរបស់កម្ពុជា»៕

# ក្រុមសហជីពនិងសង្គមស៊ីវិលស្នើឱ្យដោះលែងអ្នកទោសមនសិកា ឯមន្ត្រីរដ្ឋាភិបាលថាការស្នើនេះខុសនឹងនីតិច្បាប់និងរដ្ឋធម្មនុញ្ញកម្ពុជា

*អត្ថបទ៖ អមរិន្ទ ដានុត*

សហជីពនិងអង្គការសង្គមស៊ីវិលចំនួន២០ ស្ថាប័ន បានស្នើសុំតុលាការ និងរាជរដ្ឋាភិបាលកម្ពុជាពិចារណាដោះលែងអ្នកទោសមនសិការទាំងអស់ដែលត្រូវបានឃុំខ្លួននៅក្នុងប្រទេសកម្ពុជាដោយសារស្ថានភាពនៃជំងឺកូវីដ-១៩ ក្នុងពន្ធនាគារកម្ពុជាមានការរីករាលដាលគួរឱ្យបារម្ភ ខណៈពេលដែលមន្ត្រីរាជរដ្ឋាភិបាលថាការស្នើនេះ មិនសមស្រប ខុសនឹងនីតិច្បាប់និងរដ្ឋធម្មនុញ្ញកម្ពុជា និងមានចរិតជានយោបាយ។

យោងតាមសេចក្តីថ្លែងការណ៍រួមរបស់សហជីពនិងសង្គមស៊ីវិល បានលើកឡើងថា អ្នកទោសមនសិការគឺជាបុគ្គលដែលត្រូវបានគេចាប់ដាក់គុកដោយសារតែការបញ្ចេញមតិដោយសន្តិវិធី ទាក់ទងនឹងបញ្ហានយោបាយ, សង្គម, ជំនឿសាសនាឬជំនឿផ្សេងទៀតតាមមនសិការឬអត្តសញ្ញាណរបស់ពួកគេ។ ស្នើរតែអ្នកទោសមនសិការទាំងអស់ដែលបានជាប់ពន្ធនាគារនៅក្នុងប្រទេសកម្ពុជាបានប្រឈមមុខនឹងការចោទ ប្រកាន់និងការដាក់ទោសពីបទញុះញង់ដូចគ្នា។

សហជីពនិងសង្គមស៊ីវិលទាំងនេះបានបញ្ជាក់ថា៖ «ដោយមើលឃើញពីរបាយការណ៍នៃករណីកើនឡើងនៃជំងឺវីដ-១៩ នៅក្នុងពន្ធនាគារកម្ពុជារួមផ្សំនឹងចំនួនអ្នកទោសច្រើនពេកនៅក្នុងពន្ធនាគារ, យើងខ្ញុំសូមអំពាវនាវដល់រដ្ឋាភិបាលឱ្យដោះលែងអ្នកទោសមនសិការ អហិង្សាទាំងអស់ ដែលជាវិធានការដើម្បីកាត់បន្ថយហានិភ័យបណ្តាលមកពីការរីករាលដាលនៃវីរុសក្លរ៉ូណា»។

ក្រុមសហជីពនិងសង្គមស៊ីវិល បានបន្ថែមថា ដោយសារតែហានិភ័យខ្ពស់នៃការឆ្លងជំងឺកូវីដ-១៩ អ្នកទោសទាំងអស់បានទទួលរងនូវការកើនឡើងនៃការ ជះឥទ្ធិពលជាអវិជ្ជមានដល់សុខភាពផ្លូវចិត្តនិងផ្លូវកាយរបស់ពួកគេ។

ការដោះលែងអ្នកទោសមនសិការទាំងនេះនឹងលើកកម្ពស់សិទ្ធិជាមូលដ្ឋានដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា និងឧបករណ៍សិទ្ធិមនុស្សអន្តរជាតិដទៃទៀតដើម្បីកាត់បន្ថយហានិភ័យសង្គមពីជំងឺកូវីដ-១៩ ហើយរួមចំណែក ក្នុងការផ្តល់សុភមង្គលដល់គ្រួសាររបស់ពួកគេនិងសង្គមទាំងមូល, កាត់បន្ថយភាពតានតឹងផ្នែកសង្គមនិងនយោបាយ និងលើកទឹកចិត្តពួកគេឱ្យបន្តការងារដ៏មានតម្លៃរបស់ខ្លួនសម្រាប់ជាប្រយោជន៍រួមដល់សង្គមកម្ពុជា ក៏ដូចជានាំមកនូវភាពល្អប្រសើរសម្រាប់ប្រជាជនកម្ពុជាផងដែរ។

សហជីពនិងសង្គមស៊ីវិល ដែលបានស្នើដល់រាជរដ្ឋភិបាល រួមមាន គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL), មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព (PDP Center), មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR), មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL), វិទ្យាស្ថានប្រជាធិបតេយ្យកម្ពុជា (CID ), សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC), សមាគមប្រជាធិបតេយ្យឯករាជ្យ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA) រួមនឹងសង្គមស៊ីវិលជាច្រើនទៀត។

ទាក់ទងនឹងការស្នើឡើងរបស់ក្រុមសហជីពនិងសង្គមស៊ីវិលឱ្យមានការដោះលែងអ្នកទោសមនសិកានេះ លោក ជិន ម៉ាលីន អ្នកនាំពាក្យក្រសួងយុត្តិធម៌ បានឱ្យដឹងថាសេចក្តីថ្លែងការណ៍រួមរបស់អង្គការទាំង២០ អំពាវនាវដល់រដ្ឋាភិបាលឱ្យដោះលែងអ្នកទោសមនសិការទាំងអស់ គឺមិនសមស្រប ខុសនឹងនីតិច្បាប់និងរដ្ឋធម្មនុញ្ញកម្ពុជា និងមានចរិតជានយោបាយ។

លោកថា ផ្អែកតាមរដ្ឋធម្មនុញ្ញនិងគោលការណ៍នៃការបែងចែកអំណាចក្នុងសង្គមប្រជាធិបតេយ្យរដ្ឋាភិបាលមិនមានអំណាចដោះលែងអ្នកជាប់ឃុំដែលស្ថិតក្រោមសមត្ថកិច្ចរបស់តុលាការនោះទេ ហើយក៏គ្មានបុគ្គលឬស្ថាប័នណាអាចបង្គាប់បញ្ជាតុលាការដែលជាស្ថាប័នឯករាជ្យបាននោះដែរ។

លោក ជិន ម៉ាលីន បានបន្ថែមថា៖ «នៅកម្ពុជាមិនមានអ្នកទោសនយោបាយ ឬអ្នកទោសមនសិការដូចការលើកឡើងរបស់អង្គការទាំង២០នេះទេ គឺមានតែអ្នកនយោបាយដែលមានទោសដោយសារតែបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ»។

នៅកម្ពុជា ការបញ្ចេញមតិដោយសន្តិវិធី គឺជាសិទ្ធិ មិនមែនជាបទល្មើសនោះទេ តែផ្ទុយទៅវិញការបញ្ចេញមតិដែលប៉ះពាល់ដល់សិទ្ធិអ្នកដទៃសន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈជាដើម។ល។ គឺជាបទល្មើស មិនមែនជាការអនុវត្តសិទ្ធិនោះទេ ចំណែកឯអ្នកដែលប្រព្រឹត្តអំពើល្មើសទាំងនេះ ក៏ត្រូវទទួលទោសតាមផ្លូវច្បាប់ផងដែរ និងមិនត្រូវបានចាត់ទុកជាអ្នកទោសមនសិការដូចការលើកឡើងរបស់អង្គការទាំង២០នេះទេ។

អ្នកនាំពាក្យរូបនេះ បានបន្តថា មានតែការដោះលែងដោយផ្អែកតាមនីតិវិធីច្បាប់ដែលមានជាធរមានទេ ហើយដែលបានអនុវត្តជាហូរហែនាពេលកន្លងមកផងដែរ ដូចជាវិធានការដោះលែងដែលបានប្រើប្រាស់ក្នុងយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងនៅតាមតុលាការរបស់ក្រសួងយុត្តិធម៌ និងវិធានការនៃការលើកលែងទោសនិងបន្ធូរបន្ថយទោសរបស់រដ្ឋាភិបាលដែលធ្វើជារៀងរាល់ឆ្នាំជាដើម។ល។ ទើបអាចធានាបាននូវសន្តិសុខសង្គម និងកាត់បន្ថយការកើនឡើងជាគំហុកនៃចំនួនអ្នកជាប់ឃុំក្នុងពន្ធនាគារ។

លោក ជិន ម៉ាលីន បានបញ្ជាក់ថា ចំណែកឯការដោះលែងអ្នកជាប់ឃុំតាមការអំពាវនាវរបស់អង្គការទាំង២០នេះ ដើម្បីដោះស្រាយបញ្ហានៃការឆ្លងកូវីដ-១៩ក្នុងពន្ធនាគារ ក៏មិនមែនជាវិធានការសមស្របនិងមានប្រសិទ្ធភាពនោះដែរ តែផ្ទុយទៅវិញ មានតែវិធានការសុខាភិបាល និងវិធានការរដ្ឋបាលនៃការគ្រប់គ្រងពន្ធនាគារឱ្យបានហ្មត់ចត់នោះទេ ដែលក្រសួងសុខាភិបាលនិងអគ្គនាយកដ្ឋានពន្ធនាគារបាននិងកំពុងអនុវត្តទើបជាវិធានការសមស្រប និងអាចធានាបាននូវសន្តិសុខសង្គមនិងប្រសិទ្ធភាពនៃទប់ស្កាត់ការឆ្លងរាលដាលកូវីដ-១៩នេះក្នុងពន្ធនាគារ។

លោកថា ៖ «ការអំពាវនាវដែលផ្ទុយទៅនឹងច្បាប់ និងមានចរិតជានយោបាយបែបនេះ នឹងមិនអាចជួយការពារដល់អ្នកជាប់ឃុំទាំងអស់នោះបានទេ តែផ្ទុយទៅវិញ មានតែការចូលរួមក្នុងដំណើរការនីតិរបស់តុលាការទេ ហើយធ្វើការការពារខ្លួនតាមផ្លូវច្បាប់ ទើបជាមធ្យោបាយស្របច្បាប់តែមួយគត់ក្នុងការការពារដល់ក្រុមគោលដៅទាំងនោះ នៅក្នុងសង្គមប្រជាធិបតេយ្យនីតិរដ្ឋ»៕

# ក្រសួងអប់រំ អនុញ្ញាតឱ្យគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា រៀបចំការប្រឡងបញ្ចប់សិក្សា របស់គ្រឹះស្ថានឯកជន

*អត្ថបទ៖ ផល សុផានិត*

ក្រសួងអប់រំយុវជននិងកីឡា បានយល់ព្រមឱ្យសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា រៀបចំការប្រឡងបញ្ចប់បឋមសិក្សាថ្នាក់ទី៦ និងប្រឡងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិថ្នាក់ទី៩ ឬឌីប្លូម ឆ្នាំសិក្សា២០២០-២០២១ សម្រាប់គ្រឹះស្ថានសិក្សាចំណេះទូទៅឯកជនដែលជាសមាជិករបស់សមាគម។



លោកបណ្ឌិត សភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា បានឱ្យដឹងនៅក្នុងសេចក្តីជូនដំណឹងថា៖ «ក្រសួងអប់រំយុវជននិងកីឡា យល់ព្រមតាមសំណើរបស់សមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា ដោយអនុញ្ញាតឲ្យគ្រឹះស្ថានសិក្សាចំណេះទូទៅឯកជនដែលជាសមាជិករបស់ សមាគម រៀបចំការប្រលងបញ្ចប់បឋមសិក្សាថ្នាក់ទី៦ និងប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិថ្នាក់ទី៩ឆ្នាំសិក្សា២០២០-២០២១ ដោយគ្រឹះស្ថានសិក្សានីមួយៗ ជាអ្នកទទួលខុសត្រូវទៅតាមប្រតិទិនប្រឡងរៀងៗខ្លួន»។

លោករដ្ឋមន្ត្រីបានបន្តថា ក្រសួងអប់រំយុវជននិងកីឡា នឹងផ្តល់ការទទួលស្គាល់ចំពោះលទ្ធផលនៃការប្រឡងនេះ និងធ្វើអធិការកិច្ចប្រសិនបើចាំបាច់។

ថ្លែងប្រាប់ក្រុមអ្នកសារព័ត៌មាន លោក រស់ សុវាចា អ្នកនាំពាក្យក្រសួងអប់រំយុវជននិងកីឡា បានមានប្រសាសន៍ថា ក្រសួងអប់រំ យុវជននិងកីឡា នៅតែបន្តលើកកម្ពស់គុណភាពអប់រំ និងគុណភាពប្រឡងឌីប្លូមនិងបាក់ឌុបដដែលដើម្បីឆ្លើយតបនឹងតម្រូវការសិក្សាក្នុងបរិបទកូវីដ-១៩។

លោក រស់ សុវាចា បានមានប្រសាសន៍បន្តថា ចំពោះការប្រឡងឌីប្លូម និងបាក់ឌុបនេះក្រសួងអប់រំ នឹងជម្រាបជូននាពេលក្រោយ។

យ៉ាងណាក៏ដោយ លោក រស់ សុវាចា បានបញ្ជាក់ថា ក្រសួងអប់រំសូមលើកទឹកចិត្តសិស្សានុសិស្សនិងបេក្ខជនប្រឡងទាំងអស់ បន្តខិតខំប្រឹងប្រែងរៀនសូត្រតាមអនឡាញ ថែរក្សាសុខភាព និងគាំទ្រគ្នាទៅវិញទៅមក ខណៈពេលដែលកម្ពុជានិងពិភពលោក កំពុងប្រឈមនឹងកូវីដ-១៩ នៅឡើយ។

ដោយសារព្រឹត្តិការណ៍សហគមន៍២០កុម្ភៈ នៅតែអូសបន្លាយយូរនោះ មាតាបិតាសិស្សដែលមានកូនចៅត្រូវប្រឡងឌីប្លូម និងប្រឡងបាក់ឌុបនៅឆ្នាំ២០២១ នេះ មានការព្រួយបារម្ភថា ឆ្នាំនេះនឹងអាចរៀបចំការប្រឡង ឬយ៉ាងណានោះទេ ខណៈកាលពីឆ្នាំ២០២០ កន្លងទៅ ប្រមុខរដ្ឋាភិបាលកម្ពុជា សម្តេចតេជោ ហ៊ុន សែន បានសម្រេចឱ្យបេក្ខជនប្រឡងឌីប្លូមដែលមិនបានចូលប្រឡង និងបេក្ខជនប្រឡងធ្លាក់ និងបេក្ខជនដែលបានដាក់ពាក្យប្រឡងបាក់ឌុបទាំងអស់ ឲ្យជាប់ដោយស្វ័យប្រវត្តិដោយមិនចាំបាច់ឆ្លងកាត់ការប្រឡងឡើយ ដោយសារតែវិបត្តិជំងឺកូវីដ ១៩៕

## គម្រោងដកស្រង់មេរៀនបទពិសោធន៍ពីប្រទេសចិន ដើម្បីលើកកម្ពស់ សមត្ថភាពឆ្លើយតបនឹងជំងឺកូវីដ-១៩ត្រូវបានប្រកាសដាក់ឱ្យអនុវត្ត

*អត្ថបទ៖ អមរិទ្ធ ដានុត*

ក្រសួងសុខាភិបាលនៅថ្ងៃសុក្រទី០៤ ខែមិថុនា បានសម្រេចប្រកាសដាក់ឱ្យអនុវត្តគម្រោងដកស្រង់មេរៀនបទពិសោធន៍ពីប្រទេសចិន ដើម្បីលើកកម្ពស់ សមត្ថភាពឆ្លើយតបនឹងជំងឺកូវីដ-១៩ នៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក ស្តីពីការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ។

នៅថ្ងៃដដែលនេះដែរ ក៏មានការប្រគល់-ទទួលឧបករណ៍បរិក្ខារវេជ្ជសាស្ត្រ តាមរយៈវីដេអូសន្និសីទ ជាជំនួយរបស់រដ្ឋាភិបាល និងប្រជាជនចិន តាមរយៈកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) ជូនរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា។

ពិធីប្រកាសអនុវត្ត និងការប្រគល់-ទទួលនេះ ត្រូវបានធ្វើឡើងរវាង លោក ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល រួមជាមួយលោក វ៉ាង វិនធាន ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោក Nick Beresford ប្រធានកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ ប្រចាំប្រទេសកម្ពុជា តាមរយៈប្រព័ន្ធវីដេអូ (Video Conference) នាព្រឹកមិញនេះ។

លោក ម៉ម ប៊ុនហេង បានលើកឡើងថា ក្នុងភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ កម្ពុជា-ចិន ជំនួយឥតសំណងជាច្រើន ត្រូវបានផ្តល់ជូនក្រសួងសុខាភិបាល ដើម្បីចូលរួមចំណែកពង្រឹងនិង ពង្រីកវិស័យសុខាភិបាលកម្ពុជា ដូចជា គម្រោងកែលម្អមន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិន ព្រះកុសុមៈ, គម្រោងសាងសង់មន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិន ខេត្តត្បូងឃ្មុំ, ការផ្តល់រថយន្តគ្លីនិកចល័ត រួមទាំងការបំពាក់ឧបករណ៍វេជ្ជសាស្ត្រទំនើបៗ និងសម្ភារៈបរិក្ខារផ្សេងៗ ចំនួន៤០គ្រឿង, ការផ្គត់ផ្គង់រថយន្តគិលានសង្គ្រោះ ចំនួន ២០០គ្រឿង, ការផ្គត់ផ្គង់ ម៉ាស៊ីនអេកូសាស្ត្រ ចំនួន ២០០គ្រឿង, គម្រោង "ដំណើរនៃក្តីស្រលាញ់ពីបេះដូង" នៅកម្ពុជា ដោយបាន បញ្ជូនកុមារមានជំងឺបេះដូងចំហរពីកំណើត ចំនួន២៤នាក់ ទៅធ្វើការវះកាត់នៅប្រទេសចិន ដោយឥតគិតថ្លៃ និងបានទទួលជោគជ័យ ទាំង២៤នាក់។

លោកបានបន្ថែមថា៖ «រដ្ឋាភិបាល និងប្រជាជនចិនបានផ្តល់ជំនួយជាបន្តបន្ទាប់ ទាំងជំនួយបច្ចេកទេស ទាំងឧបករណ៍បរិក្ខារវេជ្ជសាស្ត្រនិងមន្ទីរពិសោធន៍ ជូនរាជរដ្ឋាភិបាល និងប្រជាជន កម្ពុជា ក្នុងការទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-១៩ សរុបជាទឹកប្រាក់ប្រមាណជាង ១០លានដុល្លារអាមេរិក ចាប់តាំងពីការរាតត្បាតនៃជំងឺកូវីដ-១៩ នាខែមករា ឆ្នាំ២០២០»។

លោក ម៉ម ប៊ុនហេង បានបន្តទៀតថា តាមរយៈកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន បានផ្តល់នូវឧបករណ៍បរិក្ខារ វេជ្ជសាស្ត្រសម្រាប់ការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ ចំនួន១២មុខ ដើម្បីពង្រឹងសមត្ថភាពការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ៕

## អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ប្រាប់ឯកអគ្គរដ្ឋទូតឥណ្ឌាប្រចាំកម្ពុជា ពីតម្រូវការវ៉ាក់សាំង បន្ថែមទៀត

*អត្ថបទ៖ អមរិទ្ធ ដានុត*

ក្នុងកិច្ចពិភាក្សាការងារជាមួយនឹងលោកស្រី Dr. Devyani Khobragade ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋឥណ្ឌាប្រចាំនៅព្រះរាជាណាចក្រកម្ពុជា លោកអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានលើកឡើងថា កម្ពុជានៅតែមានតម្រូវការវ៉ាក់សាំងបន្ថែមទៀត ហើយសង្ឃឹមថា ឥណ្ឌានឹងបន្តផ្គត់ផ្គង់វ៉ាក់សាំងបន្ថែមមកកម្ពុជានាពេលដ៏ខ្លីខាងមុខ។

លោកអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ក៏បានធ្វើការកោតសរសើរចំពោះសាធារណរដ្ឋឥណ្ឌាដែលមានសមត្ថភាពក្នុងការផលិតវ៉ាក់សាំងជំងឺកូវីដ-១៩ និងនៅតែបន្តរក្សាការសន្យារបស់ខ្លួនក្នុងកិច្ចសហការប្រយុទ្ធទប់ស្កាត់ជំងឺកូវីដ-១៩ នៅកម្ពុជាផងដែរ។

> កម្ពុជាបានអនុវត្តនូវវិធានការរក្សាស្ថេរភាពសង្គម និងរក្សាភាពរស់រានមានជីវិតផ្នែកសេដ្ឋកិច្ច (Survival Economy) របស់ប្រជាជន តាមរយៈកម្មវិធី ជំនួយសង្គមជាសាច់ប្រាក់ក្រោយពេលបិទខ្ទប់ ដើម្បីជួយគាំទ្រប្រជាជនដែលមានកម្រិតជីវភាពទាប និងជួបប្រឈមនឹងការលំបាកក្រោយការអនុវត្តការបិទខ្ទប់

លោកបានលើកឡើងបន្តថា៖ «កម្ពុជាបានអនុវត្តនូវវិធានការ រក្សាស្ថេរភាពសង្គម និងរក្សាភាពរស់រានមានជីវិតផ្នែកសេដ្ឋកិច្ច (Survival Economy) របស់ប្រជាជន តាមរយៈកម្មវិធី ជំនួយសង្គមជាសាច់ប្រាក់ក្រោយពេលបិទខ្ទប់ ដើម្បីជួយគាំទ្រប្រជាជនដែលមានកម្រិតជីវភាពទាប និងជួបប្រឈមនឹងការលំបាកក្រោយការអនុវត្តការបិទខ្ទប់»។

លើសពីនេះ រាជរដ្ឋាភិបាលកម្ពុជា កំពុងគិតគូរអំពីការ ដាក់ឲ្យអនុវត្តកម្មវិធីប្រហាក់ប្រហែលគ្នានេះ នៅក្នុងអន្តរកាលក្រោយបិទបញ្ចប់ព្រឹត្តិការណ៍ ២០ កុម្ភៈ ដើម្បីជួយដល់ ប្រជាជនងាយរងគ្រោះអាចសម្របខ្លួនបានឡើងវិញក្នុងបរិបទនៃប្រក្រតីភាពថ្មី។

នាឱកាសនោះដែរ លោកស្រី Dr. Devyani Khobragade បានលើកឡើងផងដែរថា ទោះបីស្ថិតនៅក្នុងកាលៈទេសៈដ៏លំបាកដែលប្រទេសឥណ្ឌាកំពុងជួបប្រទះនូវការរីករាលដាលនៃវីរុសកូវីដ១៩ រដ្ឋាភិបាលឥណ្ឌានៅតែបន្តរក្សាការសន្យារបស់ខ្លួនចំពោះរាជរដ្ឋាភិបាលកម្ពុជាក្នុងកិច្ច សហការលើការប្រយុទ្ធទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ។

លោកស្រីបន្តថា រដ្ឋាភិបាលឥណ្ឌានឹងខិតខំបន្តពង្រឹងនិងធ្វើការជំរុញកិច្ចសហប្រតិបត្តិការលើវិស័យផ្សេងទៀតដូចជា ការសម្រួលពាណិជ្ជកម្មក្រៅប្រទេស ការជំរុញការវិនិយោគឯកជនពីឥណ្ឌាមកកម្ពុជា និង កិច្ចសហប្រតិបត្តិការហិរញ្ញប្បទានក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងវិស័យឌីជីថល តាមរយៈយន្តការនានាដូចជា យន្តការទ្វេភាគី, យន្តការតំបន់ និងយន្តការឥណ្ឌា-អាស៊ាន ជាដើម។

ជាមួយគ្នានេះ លោកស្រីឯកអគ្គរដ្ឋទូតក៏បានសំដែងនូវការកោតសរសើរ ចំពោះកម្ពុជាដែលសម្រេចបាននូវកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៧% ក្នុង១ឆ្នាំ នាពេលកន្លងមក និងបានប្រែក្លាយ កម្ពុជាជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប ហើយក្នុងស្ថានភាពដ៏លំបាកនេះ លោកស្រី មានបំណងចង់ស្វែងយល់អំពីវិធានការណ៍សង្គមនិងសេដ្ឋកិច្ចរបស់កម្ពុជាក្នុងការគ្រប់គ្រងវិបត្តិកូវីដ-១៩៕

# រដ្ឋមន្ត្រីក្រសួងការពារជាតិថា មិត្តចិនបានជួយអភិវឌ្ឍកំពង់ផែរាមរបស់កម្ពុជា ឱ្យទំនើបជាងមុនដោយគ្មានចំណងណាមួយឡើយ

*អត្ថបទ៖ ផល សុផានិត*

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិកម្ពុជា លោក ទៀ បាញ់ បានបញ្ជាក់ឱ្យដឹងថា ភាគីចិនដែលជាមិត្តដែកថែប បានជួយអភិវឌ្ឍកំពង់ផែរាមរបស់កម្ពុជា ឱ្យទំនើបជាងមុនដោយមិនមានចំណងឡើយ ហើយបន្ទាប់ពីសង់រួច ទុកឲ្យកម្ពុជាជាអ្នកប្រើប្រាស់ដោយអនុវត្តស្របតាមរដ្ឋធម្មនុញ្ញ មិនមែនសម្រាប់ផ្តាច់មុខឲ្យចិននោះទេ។





យោងតាមសារសម្លេង លោក ទៀ បាញ់ បានបញ្ជាក់ដូច្នេះថា ការរួមចំណែកក្នុងការអភិវឌ្ឍកំពង់ផែរាមនេះ ដើម្បីលើកកម្រិតវិស័យការពារជាតិកម្ពុជា ខាងផ្នែកសមុទ្រ ឬឱ្យកម្ពុជាមានមូលដ្ឋាន ដើម្បីមានកន្លែងសមរម្យ មានរោងជាងសម្រាប់ជួសជុលបណ្តានាវាខាងសមុទ្រ មានផែសម្រាប់ចតនាវាឱ្យបានសមរម្យ។

លោកបានមានប្រសាសន៍ថា ៖ «សព្វថ្ងៃនេះគឺឃើញច្បាស់ហើយ ទឹកវ៉ារ៉ាក់តូច អត់មានរោងជាងទេ ដូច្នេះគេមកជួយនេះ កម្ពុជាដឹងគុណណាស់ អរគុណគេ ហើយជំនួយនេះមានការជជែកវែកញែកគ្នាច្បាស់លាស់ គេជួយដោយអត់មានចំណងទេ»។



លោកបានបញ្ជាក់ថា រាល់ហេដ្ឋារចនាសម្ព័ន្ធសម្រាប់បម្រើការងារឲ្យកងទ័ពជើងទឹក មានតម្រូវការសាងសង់, ការអភិវឌ្ឍតំបន់រាមនេះ មិនមែនប្រាក់តិចតួចអាចធ្វើបាននោះទេ ហើយកម្ពុជាក៏មិនមានលទ្ធភាពក្នុងការអភិវឌ្ឍដោយខ្លួនឯងដែរ គឺមានចិនជាដៃគូបានផ្តល់ជំនួយ ហើយថាកម្ពុជាបានរំលឹកអំពីគុណបំណាច់របស់ភាគីចិនដែលបានជួយអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា។

សម្តេចពិជ័យសេនា ទៀ បាញ់ បានបញ្ជាក់ថា៖ «ឥឡូវនេះ (កំពង់ផែរាម) គឺចាប់ផ្តើមដំណើរការ (សាងសង់) ហើយ ដោយបញ្ជូន(សម្ភារៈ) មកដើម្បីកសាងតាមតម្រូវការកម្ពុជា ហើយកម្ពុជាទេជាអ្នកប្រើប្រាស់កម្ពុជាទេ អភិវឌ្ឍជាតិមាតុភូមិរបស់ខ្លួន, មិនមែនសម្រាប់ផ្តាច់មុខឲ្យចិននោះទេ»។

សម្តេចពិជ័យសេនា បានលើកជាសំណួរថា៖ «តើកម្ពុជាមានសិទ្ធិទេក្នុងការស្វះស្វែងរកជំនួយមកអភិវឌ្ឍប្រទេសខ្លួន? រដ្ឋធម្មនុញ្ញកម្ពុជា បានចែងច្បាស់ណាស់ ប្រទេសកម្ពុជារក្សាសិទ្ធិទទួលជំនួយបរទេសជាអាវុធ គ្រាប់រំសេវ ការហ្វឹកហ្វឺន និងបញ្ហាផ្សេងៗទៀត ដើម្បីការពារជាតិមាតុភូមិរបស់ខ្លួន និងការពារសណ្តាប់ធ្នាប់របស់ប្រទេស»។

លោកបានបន្តថា៖ «ពិតហើយថា សមុទ្រយើងតូច តែយើងក៏ត្រូវការមានដែរនូវកន្លែងសំចតនាវា រោងជាងសម្រាប់ជួសជុល យើងក៏មានដែរនូវនាវាតូចតាចមួយចំនួន ហើយបើយើងមានលទ្ធភាព យើងក៏ត្រូវអភិវឌ្ឍនាវារបស់យើងឱ្យមានទំហំធំជាងមុន»។

រដ្ឋមន្ត្រីក្រសួងការពារជាតិរូបនេះ ជឿជាក់ថា ការចោទប្រកាន់របស់សារព័ត៌មានអាមេរិក មកលើកម្ពុជា មិនមែនដោយសារតែការអភិវឌ្ឍតំបន់រាមនោះទេ ប៉ុន្តែអាចដោយសារកត្តាភូមិសាស្ត្រនយោបាយ។

លោកបានចាត់ទុកថា ការដែលផ្សាយថា កម្ពុជាបានប្រគល់កំពង់ផែរាមទៅឱ្យចិនគ្រប់គ្រងផ្តាច់មុខ គឺជាការនិយាយបែបងងើល ដែលធ្វើដូចជាថាកម្ពុជាគ្មានច្បាប់ ឬគ្មានសិទ្ធិធ្វើអ្វីទាំងអស់។ រដ្ឋធម្មនុញ្ញរបស់យើងបានចែងច្បាស់ហើយថា កម្ពុជាមិនអនុញ្ញាតឱ្យមានមូលដ្ឋានទ័ពបរទេសនៅក្នុងប្រទេសរបស់ខ្លួនទេ ហើយយើងមិនក៏មិនមានមូលដ្ឋានទ័ពនៅក្រៅប្រទេសដែរ ដែលបញ្ហានេះកម្ពុជាបានបញ្ជាក់ច្រើនលើកច្រើនសារហើយ ប៉ុន្តែគេមិនយកត្រចៀកស្តាប់។

ក្នុងជំនួបនាដើមខែមិថុនា រវាងលោកស្រី Wendy R. Sherman អនុរដ្ឋមន្ត្រីសហរដ្ឋអាមេរិក និងសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅវិមានសន្តិភាព លោកស្រី បានបង្ហាញក្តីកង្វល់យ៉ាងខ្លាំងអំពីវត្តមាន និងការកសាងបរិក្ខារយោធាចិននៅមូលដ្ឋានទ័ពជើងទឹករាម។

លោកស្រី បានបញ្ជាក់ថ្នាក់ដឹកនាំរដ្ឋាភិបាលកម្ពុជាអំពីការវាយកម្ទេចចោលអាគារពីរខ្នង ដែលជាជំនួយរបស់អាមេរិកនៅមូលដ្ឋានទ័ពជើងទឹករាម ដោយគ្មានការជូនដំណឹង ឬការពន្យល់ឱ្យបានត្រឹមត្រូវ។ លោកស្រី អនុរដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិក គូសបញ្ជាក់ថា មូលដ្ឋានកងទ័ពចិននៅកម្ពុជា នឹងប៉ះពាល់ដល់អធិបតេយ្យកម្ពុជា គំរាមកំហែងដល់សន្តិសុខតំបន់ និងប៉ះពាល់ជាអវិជ្ជមានដល់ទំនាក់ទំនងរវាងកម្ពុជា និងសហរដ្ឋអាមេរិក។ លោកស្រី Wendy R. Sherman ជំរុញថ្នាក់ដឹកនាំកម្ពុជា ឱ្យរក្សាគោលនយោបាយការបរទេសអព្យាក្រឹត្យ និងឯករាជ្យដោយតម្កល់ផលប្រយោជន៍ពលរដ្ឋខ្មែរជាធំ។

ជុំវិញរឿងសិទ្ធិមនុស្សវិញ លោកស្រី Wendy R. Sherman បានសង្កត់ធ្ងន់អំពីសារសំខាន់នៃសិទ្ធិមនុស្ស និងកិច្ចការពារសេរីភាពជាមូលដ្ឋាន ដែលជាគ្រឹះនៃទំនាក់ទំនងទ្វេភាគីរវាងប្រទេសទាំងពីរ។ លោកស្រីជំរុញឱ្យរដ្ឋាភិបាលកម្ពុជាគោរពតាមការប្តេជ្ញាចិត្តទាំងថ្នាក់ជាតិ និងអន្តរជាតិអំពីការគោរពសិទ្ធិមនុស្ស ហើយនិងធានាឱ្យបាននូវកិច្ចគាំពារដល់សិទ្ធិកម្មករផងដែរ។ ជាងនេះទៅទៀត លោកស្រី ក៏បានអំពាវនាវដល់អាជ្ញាធរឱ្យទម្លាក់ចោលបទចោទប្រកាន់ដែលមានចរិតនយោបាយលើអ្នកនយោបាយប្រឆាំង អ្នកសារព័ត៌មាន និងសកម្មជនជាបន្ទាន់។ ម្យ៉ាងវិញទៀត លោកស្រី ជំរុញឱ្យរដ្ឋាភិបាលបើកលំហនយោបាយ និងពលរដ្ឋឡើងវិញ នៅមុនការបោះឆ្នោតឃុំសង្កាត់ឆ្នាំ២០២២ និងការបោះឆ្នោតតំណាងរាស្ត្រឆ្នាំ២០២៣ ខាងមុខ៕

# រាជរដ្ឋាភិបាលអនុញ្ញាតឲ្យភាគីអាមេរិក ទៅមើលតំបន់មួយចំនួននៅសមុទ្ររាម ដើម្បីជម្រះមន្ទិល ដែលចោទកម្ពុជាថា ផ្តល់មូលដ្ឋានឲ្យកងទ័ពចិន

*អត្ថបទ៖ ផល សុផានិត*

សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារជាតិកម្ពុជា បានថ្លែងថា រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចអនុញ្ញាតឲ្យអនុព័ន្ធយោធា ឬមន្ត្រីទូតអាមេរិកប្រចាំនៅប្រទេសកម្ពុជា ទៅពិនិត្យតំបន់មួយចំនួននៅមូលដ្ឋានសមុទ្ររាម ដែលជាទីកន្លែងអាមេរិកបានចោទកម្ពុជាថា ផ្តល់មូលដ្ឋានឲ្យកងទ័ពចិននោះ។

សម្តេចពិជ័យសេនាទៀ បាញ់ បានលើកឡើងថា ក្រោយពីមានការឯកភាពរបស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី ក្រសួងការពារជាតិបានសម្រេចឲ្យខាងភាគីអាមេរិកចុះត្រួតពិនិត្យកន្លែងមួយចំនួននៅក្នុងមូលដ្ឋានសមុទ្ររាម ដែលគេបានចោទប្រកាន់កម្ពុជាម្តងហើយ ម្តងទៀតថា កម្ពុជាយើងបានអនុញ្ញាតឲ្យកងទ័ពចិន ដាក់មូលដ្ឋាននៅទីនោះ។ តែយ៉ាងណាក៏ដោយសម្តេចពិជ័យសេនា ទៀ បាញ់ មិនទាន់កំណត់ពេលវេលាច្បាស់លាស់ថា ភាគីអាមេរិកនឹងទៅមើលពេលណានោះទេ ខណៈភាគីអាមេរិកកំពុងធ្វើសំណើមកកម្ពុជានោះ។

សម្តេចពិជ័យសេនា ទៀ បាញ់ បានសង្កត់ធ្ងន់ថា៖ «យើងមិនបានហាមប្រាមក្នុងការស្នើសុំរបស់អាមេរិកទេ ហើយគេជាអ្នកចោទយើងខ្លួនឯង។ គេលើកគេដាក់អ្វីក៏ខ្លួនឯង ដូច្នេះដើម្បីឲ្យអស់សង្ស័យ យើងអនុញ្ញាតឲ្យគេទៅត្រួតពិនិត្យផ្ទាល់ ប៉ុន្តែមិនមែនឲ្យត្រួតគ្រប់ទីកន្លែងស្រេចតែចិត្តគេចង់បាននោះទេ ធម្មតាកន្លែងកងទ័ព នៃប្រទេសនីមួយៗមិនចេះតែបង្ហាញផ្តេសផ្តាសនោះឡើយ ហើយការចុះពិនិត្យនេះ គឺយើងបានកំណត់ច្បាស់លាស់ ពោលគឺឲ្យចំកន្លែងដែលគេសង្ស័យយើងតែប៉ុណ្ណោះ»។

ប្រមុខការពារជាតិរូបនេះ បានបញ្ជាក់ នាពេលនេះ ក្រុមការងារក្រសួងការពារជាតិកម្ពុជា និងក្រុមការងាររបស់ភាគីអាមេរិក កំពុងធ្វើកិច្ចការងារទាំងនេះហើយ ដូច្នេះវានឹងដំណើរការពេលឆាប់នេះ ដើម្បីជម្រះឲ្យអស់មន្ទិលសង្ស័យ និងឲ្យគេអស់ចិត្តកុំឲ្យពួកគេចេះតែចោទកម្ពុជាម្តងហើយម្តងទៀត ឥតឈប់ឈរនោះ។

ការអនុញ្ញាតឲ្យភាគីអាមេរិកចូលមើលតំបន់មួយចំនួននៅមូលដ្ឋានសមុទ្ររាមរបស់កម្ពុជានេះ គឺបានធ្វើឡើងបន្ទាប់ពីលោកស្រី Wendy Ruth Sherman អនុរដ្ឋមន្ត្រីការបរទេសអាមេរិក បានស្នើសុំសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា ចុះពិនិត្យមើលកំពង់ផែនេះ ក្នុងពេលជំនួបជាមួយសម្តេច ក្នុងអំឡុងពេលដែល លោកស្រីមកបំពេញទស្សនកិច្ចប្រទេសកម្ពុជា នាពេលកន្លងទៅនេះ៕

# ព្រៃឈើ ៤៣លានហិចតាត្រូវបាត់បង់ក្នុងរយៈពេល១៣ឆ្នាំ

*អត្ថបទ៖ ផល សុផានិត*

អង្គការមូលនិធិសកលដើម្បីធម្មជាតិ បានធ្វើការព្រមាននៅក្នុងរបាយការណ៍របស់ខ្លួនថា ការបញ្ឈប់ការបាត់បង់ស្ថានជីវចម្រុះ និងបញ្ឈប់ការិចរិលនៃភាវមានជីវិត គឺជារឿងដែលត្រូវដោះស្រាយថ្មីដោយខានមិនបាន។ អង្គការនេះបានព្យាករណ៍ថា នឹងមិនមានមនុស្សណាម្នាក់មានសុខភាពល្អនោះទេ បើគ្មានព្រៃឈើ។ វាគ្មានអ្វីភ្ញាក់ផ្អើលទេ ដែលមូលហេតុនៃការបាត់បង់ព្រៃឈើអាចត្រូវបានកំណត់ និងចាប់ផ្តើមហុចផលមហន្តរាយដែលយើងអាចដឹងបាន ដូចជារោគរាតត្បាតនានា។



យោងតាមរបាយការណ៍នៃមូលនិធិសកលដើម្បីធម្មជាតិ (WWF) បានឲ្យដឹងថា ឈើប្រមាណ ៤៣លាន ហិចតា ត្រូវបានបាត់បង់ចេញពីព្រៃសំខាន់ៗទាំង២៤ នៅក្នុងពិភពលោកនៅចន្លោះឆ្នាំ២០០៤ និងឆ្នាំ២០១៧ ។

យោងតាមអង្គការក្រៅរដ្ឋាភិបាលនេះបានឲ្យដឹងទៀតថា កសិកម្មតាមបែបពាណិជ្ជកម្មដែលមានការកាប់ឈើដើម្បីដាំដំណាំ និងចិញ្ចឹមសត្វពាហនៈ គឺជាហេតុផលសំខាន់នៃការបាត់បង់ ព្រៃឈើនេះមានជាអាទិ៍ នៅទ្វីបអាម៉េរិកខាងត្បូងជាដើម។ ចំណែកវិស័យរ៉ែ ការកសាង ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ឧស្សាហកម្មព្រៃឈើ និងកសិកម្មផលិតចំណីអាហារ មានជាអាទិ៍នៅទ្វីបអាហ្វ្រិក ក៏ជាកត្តាសំខាន់ដែលត្រូវបានគេកំណត់ជាមូលហេតុសម្រាប់ការបាត់បង់ព្រៃឈើនេះផងដែរ។

យោងតាមអង្គការក្រៅរដ្ឋាភិបាលនេះ តំបន់ក្តៅនៃការបាត់បង់ព្រៃឈើនេះ មាន ៩ស្ថិតនៅតំបន់អាម៉េរិកឡាទីន ៨ស្ថិតនៅទ្វីបអាហ្វ្រិក និង ៧ស្ថិតនៅតំបន់អាស៊ីប៉ាស៊ីហ្វិក។ ការបាត់បង់ឈើត្រូពិចពិភពលោកមានច្រើនជាងពាក់កណ្តាល គឺ ៥២%នៅតំបន់អស់ទាំងនេះ។ តំបន់ដែលរងផលប៉ះពាល់ខ្លាំងបំផុត គឺតំបន់អាម៉ាហ្សូន និងតំបន់សឺរ៉ាដូ នៅប្រទេសប្រេស៊ីល តំបន់អាម៉ាហ្សូននៅប្រទេសប៊ូលីវី ប៉ារ៉ាហ្គាយ អាហ្សង់ទីន ព្រមទាំងតំបន់ប្រទេសម៉ាដាកាស្កា និងនៅប្រជុំកោះស៊ូម៉ាត្រា និងប័រណេអូ នៃប្រទេសឥណ្ឌូនេស៊ី និងប្រទេសម៉ាឡេស៊ី។

ជាក់ស្តែងតំបន់សឺរ៉ាដូនៅប្រទេសប្រេស៊ីល ព្រៃឈើត្រូវរងផលប៉ះពាល់ជាសំខាន់ពីការអភិវឌ្ឍកសិកម្ម ដែលធ្វើឲ្យបាត់បង់ព្រៃឈើ ៣លាន ហិចតានៅចន្លោះឆ្នាំ២០០៤ និង ឆ្នាំ២០១៧ ហើយផ្ទៃដីគម្របព្រៃឈើនៅលើពិភពលោកត្រូវបាត់បង់ជាង ៣០%ជាសរុបចាប់តាំងពីឆ្នាំ២០០០មក។

លើសពីនេះទៀត ព្រៃឈើជិតពាក់កណ្តាល ៤៥% ដែលនៅសល់នៅតំបន់ចំនួន ២៤ នៅលើពិភពលោកបានទទួលរងការធ្លាក់ថយចុះគុណភាព ឬរិចរិល ដែលហុចទិន្នផលកាន់តែស្លួចស្តើង។ ហើយព្រៃឈើទាំងនេះក៏ទទួលរងភ្លើងឆេះជាច្រើនដែលអគ្គីភ័យចេះតែកើនឡើងនៅប៉ុន្មានឆ្នាំចុងក្រោយនេះ។ ភាពផុយស្រួយនេះធ្វើឲ្យគ្រោះថ្នាក់ដល់ប្រព័ន្ធជីវចម្រុះ ដែលងាយរងគ្រោះដែលយកព្រៃឈើជាទីជម្រក ហើយក៏ជាទីស្នាក់អាស្រ័យរបស់ពពួកពូជសត្វជាច្រើនផងដែរ។

ព្រៃឈើជួយអនុគ្រោះដល់ទំនាក់ទំនងរវាងពូជសត្វព្រៃ និងមនុស្ស ជួយរារាំងការចម្លងជំងឺដែលមានប្រភពពីសត្វព្រៃមកមនុស្ស។ ព្រៃឈើក៏ជាឃ្លាំងស្តុកដ៏មានសក្តានុពលនៃសារធាតុកាបូន ដែលជួយស្រូបយកបរិមាណដ៏ធំធេងនៃឧស្ម័នផ្ទះកញ្ចក់ដែលបញ្ចេញដោយសកម្មភាពរបស់មនុស្ស។

របាយការណ៍នេះបានអំពាវនាវឲ្យរដ្ឋនានានិងវិស័យសេដ្ឋកិច្ច ដើម្បីប្រយុទ្ធប្រឆាំងនឹងការកាប់បំផ្លាញព្រៃឈើ មានជាអាទិ៍ដូចជាការពង្រឹកសិទ្ធរបស់ប្រជាជនជនជាតិភាគតិចជាដើម។ គេក៏អំពាវនាវផងដែរឲ្យប្រជាជនជៀសវាងផលិតផលដែលជំរុញឲ្យមានការកាប់បំផ្លាញព្រៃឈើ ដោយផ្លាស់ប្តូររបបអាហារ ដោយកុំបរិភោគប្រូតេអ៊ីនសត្វច្រើនពេក។

លោក ម៉ាកកូឡុំបៃទីនី អគ្គនាយកអង្គការមូលនិធិសកលដើម្បីធម្មជាតិ បានព្រមានថា៖ «ការគ្រប់គ្រងមិនល្អនៃព្រៃឈើពិភពលោកជំរុញឲ្យមានការបំភាយឧស្ម័នកាបូនិច បំផ្លាញស្ថានជីវចម្រុះ បំផ្លាញប្រព័ន្ធបរិស្ថានរស់នៅ និងជះឥទ្ធពលលើចំណីអាហារ និងការរបស់នៅមានសេចក្តីសុខរបស់សហគមន៍តំបន់ និងសង្គមជាទូទៅ។

កាលពីខែកញ្ញាមុន របាយការណ៍មួយនៃអង្គការស្បៀងអាហារពិភពលោកនៃទីភ្នាក់ងាររបស់អង្គការសហប្រជាជាតិ ធ្លាប់បានព្រមានថា ព្រៃឈើបានបាត់បង់ជិត ១០០លានហិចតានៅលើផែនដីនៅពីរទសវត្សនេះ។ គម្របព្រៃឈើធ្លាក់ចុះ ៣១,២% ឬ៤,១លានហិចតាពីផ្ទៃផែនដីនៅឆ្នាំ២០២០ ដែលកាលពីឆ្នាំ២០១០ ធ្លាក់ចុះ ៣១,៥% និងឆ្នាំ២០០០ ធ្លាក់ចុះ៣១,៩%៕

## កិច្ចសហប្រតិបត្តិការកម្ពុជានិងស្វីស ឆ្នាំ ២០២២-២០២៥ ចាប់ផ្តើមពិភាក្សា

*អត្ថបទ៖ ផល សុផានិត*

កិច្ចពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសហព័ន្ធស្វីស លើសេចក្តីព្រាងកម្មវិធីសហប្រតិបត្តិការស្វីស សម្រាប់តំបន់មេគង្គ ឆ្នាំ២០២២-២០២៥ ត្រូវបានរៀបចំឡើងតាមរយៈប្រព័ន្ធបញ្ជូនរូបភាពនិងសម្លេង (Video Conference)។ នេះបើតាមសេចក្តីប្រកាសព័ត៌មានរបស់ក្រុមប្រឹក្សា អភិវឌ្ឍកម្ពុជា CDC កាលពីម្សិលមិញ។

កិច្ចពិគ្រោះយោបល់ខាងលើ ភាគីកម្ពុជា ដឹកនាំដោយលោក ឈៀង យ៉ាណារ៉ា រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ.ជ.នា/ក.អ.ក) រីឯ ភាគីស្វីស ដឹកនាំដោយលោក ម៉ាកឃីស ប៊ីលី នាយកទីភ្នាក់ងារស្វីសសម្រាប់កិច្ចអភិវឌ្ឍន៍ និងសហប្រតិបត្តិការ (SDC) ប្រចាំព្រះរាជាណាចក្រកម្ពុជា និងមន្ត្រីជំនាញនៃទីភ្នាក់ងារ SDC សរុបទាំងអស់ប្រមាណ ៦០ រូប។

សេចក្តីប្រកាសព័ត៌មាន បានឱ្យដឹងថា គោលដៅនៃកិច្ចពិគ្រោះយោបល់នេះ ដើម្បីពិភាក្សា និងប្រមូលធាតុចូល ក៏ដូចជាអនុសាសន៍ ពីក្រសួងស្ថាប័នពាក់ព័ន្ធ លើសេចក្តីព្រាងកម្មវិធីសហប្រតិបត្តិការស្វីសសម្រាប់តំបន់មេគង្គឆ្នាំ ២០២២-២០២៥ (សម្រាប់ប្រទេសកម្ពុជា និងឡាវ) ដោយផ្តោតចម្បងលើកម្មវិធីសហប្រតិបត្តិការរបស់ស្វីសសម្រាប់កម្ពុជា ក្នុងរយៈ៤ឆ្នាំខាងមុខ។

ភាគីទាំងពីរក៏បានផ្លាស់ប្តូរបទពិសោធនៃកិច្ចសហប្រត្តិការ និងសម្លឹងមើលទៅមុខរួមគ្នា ដើម្បីសម្រេចនូវកម្មវិធីអភិវឌ្ឍនេះ។

ជាមួយគ្នានេះ ភាគីស្វីសក៏បានសន្យាផ្តល់នូវទឹកប្រាក់សរុប ១៣ លានដុល្លាអាមេរិក ជារៀងរាល់ឆ្នាំ សម្រាប់រយៈពេល ៤ឆ្នាំ ពោលគឺចាប់ពីឆ្នាំ ២០២២-២០២៥ ក្នុងគម្រោងអភិវឌ្ឍក្នុងកិច្ចសហប្រតិបត្តិការរួមគ្នានេះ។

យោងតាមប្រព័ន្ធទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការកម្ពុជា ចន្លោះឆ្នាំ២០០២-២០២០ ភាគីស្វីសបានបើកផ្តល់ហិរញ្ញប្បទានឥតសំណង សរុបប្រមាញ ១៤២ លានដុល្លាអាមេរិក ដើម្បីគាំទ្រការអនុវត្តគម្រោង អភិវឌ្ឍនានានៅកម្ពុជា៕

## កូនកន្ធាយក្បាលកង្កែបចំនួន ១០០ក្បាលត្រូវបានព្រលែងចូលក្នុងទីជម្រកធម្មជាតិ ក្នុងទិវាអណ្តើកពិភពលោក

*អត្ថបទ៖ អមរិន្ទ ដានុត*

កូនកន្ធាយក្បាលកង្កែបចំនួន ១០០ក្បាលចូលក្នុងទីជម្រកធម្មជាតិតាមដងទន្លេមេគង្គ ស្ថិតក្នុងស្រុកសំបូរ ខេត្តក្រចេះក្នុងពិធី អបអរសាទរទិវាអណ្តើកពិភពលោក ២៣ ឧសភា ២០២១នេះ ដោយអង្គការ WCS សហការជាមួយរដ្ឋបាលជលផល និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តក្រចេះ។



យោងតាមអង្គការ WCS បានឱ្យដឹងថា នៅក្នុងរដូវពងកូនឆ្នាំ២០២១នេះ ក្រុមសហគមន៍ការពារសម្បុកមេគង្គ ដែលគាំទ្រដោយសហភាពអឺរ៉ុបនិងគម្រោងព្រៃឡង់បៃតង គាំទ្រដោយទីភ្នាក់ងារជំនួយអាមេរិក USAID បានរកឃើញសម្បុកកន្ធាយក្បាលកង្កែបចំនួន ៦៦សម្បុក មានពងសរុប ២.៥២៨ពង។



អង្គការដដែលនេះបានបន្តថា ៖ «ចំនួនសម្បុកនិងពងកន្ធាយក្បាលកង្កែបដែលបានរកឃើញក្នុងឆ្នាំនេះ ច្រើនជាងឆ្នាំ ២០២០ ដែលបានរកឃើញតែ ៤៩សម្បុកនិងមាន១.៧៥៦ពងប៉ុណ្ណោះ»។

ប្រភពដដែលបានបន្តថា គិតចាប់ពីខែមករាហូតដល់ត្រឹមថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០២១ កូនកន្ធាយចំនួន ១.០៨១ក្បាល បានញាស់ចេញពីសម្បុកចំនួន ៤៩សម្បុកក្នុងចំណោម ៦៦សម្បុក ហើយក្រុមការងារបានលែងកូនកន្ធាយចំនួន ៩៦៨ក្បាលចូលក្នុងទីជម្រកធម្មជាតិរបស់វាវិញ។ ចំណែកឯកូនកន្ធាយក្បាលកង្កែបនៅសល់ ក្រុមការងារកំពុងមើលថែទាំនិងគ្រោងលែងចូលក្នុងទីជម្រកធម្មជាតិរបស់វាវិញក្នុងពេលឆាប់ៗខាងមុខ៕

# កម្ពុជាបន្តរៀបចំកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប លើកទី១៣ នៅចុងខែវិច្ឆិកា

*អត្ថបទ៖ ផល សុផានិត*

ក្នុងនាមជាម្ចាស់ផ្ទះ រៀបចំកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប លើកទី១៣ (ASEM13) នៅថ្ងៃទី២៥-២៦ ខែវិច្ឆិកា ឆ្នាំ២០២១ ខាងមុខនេះ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈលេខាធិការដ្ឋាន នៃគណៈកម្មការជាតិរៀបចំកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប កំពុងបន្តប្រឹងប្រែងរៀបចំកិច្ចប្រជុំដ៏សំខាន់ខាងលើ ជាលក្ខណៈទល់មុខ (Physical)។




លោក លុយ ដាវីត ដែលជាឧត្តមមន្ត្រីទទួលបន្ទុកកិច្ចការអាស៊ី-អឺរ៉ុបផងនោះ បានថ្លែងថា សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បានឯកភាពក្នុងការកំណត់យកកាលបរិច្ឆេទថ្មី គឺថ្ងៃទី២៥-២៦ ខែវិច្ឆិកា ឆ្នាំ២០២១ ដើម្បីរៀបចំកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប លើកទី១៣ ហើយកាលបរិច្ឆេទថ្មីកំណត់ដោយកម្ពុជា ត្រូវបានការឯកភាពគ្នារវាងប្រទេសដៃគូ ASEM ទាំងអស់ផងដែរ។ ប៉ុន្តែលោកអះអាងថា បើសិនជានៅថ្ងៃកំណត់ប្រជុំ ស្រាប់តែស្ថានភាពជំងឺកូវីដ១៩ មានសភាពធ្ងន់ធ្ងរ គណៈកម្មការជាតិនឹងជ្រើសរើសការប្រជុំតាមវីដេអូវិញ។

លោក លុយ ដាវីត បានឲ្យដឹងបន្ថែមទៀតថា «យើងគ្រោងបន្តរៀបចំកិច្ចប្រជុំនេះតាមរបៀប Physical (ទល់មុខ) តែបើស្ថានភាពកូវីដមិនធូរស្បើយទេ យើងមានជម្រើសផ្សេងទៀត។ ថ្នាក់ដឹកនាំ ASEM ដទៃទៀត ក៏គេចង់បានការប្រជុំនេះជាលក្ខណៈទល់មុខដែរ ហេតុដូច្នេះហើយ បានជាគេឯកភាពតាមសំណើកម្ពុជា លើកកិច្ចប្រជុំកំពូលនេះ ២ដងមកហើយ។ អញ្ចឹងហើយ បានជាយើងខំរុញកិច្ចប្រជុំនេះទៅចុងឆ្នាំ ដោយសង្ឃឹមថាអាចគ្រប់គ្រងជំងឺកូវីដ-១៩ បាន»។

លោកបន្តថា «ការរៀបចំកិច្ចប្រជុំជាលក្ខណៈទល់មុខ គឺជាឱកាសសម្រាប់ថ្នាក់ដឹកនាំដៃគូ ASEM ទាំងអស់ មិនមែនត្រឹមតែប្រជុំទេ ក៏ជាឱកាសឲ្យពួកគាត់ជួបគ្នាទ្វេភាគីដែរ។ អញ្ចឹងប្រទេសកម្ពុជាដែលជាទីតាំងសម្រាប់ថ្នាក់ដឹកនាំដទៃទៀតចូលរួមប្រជុំនេះ ជាកន្លែងសម្រាប់ជំនួបទ្វេភាគីសម្រាប់ថ្នាក់ដឹកនាំនីមួយៗដែរបាទ។ ហើយសម្ដេចតេជោនាយករដ្ឋមន្ត្រី ក៏គ្រោងជួបទ្វេភាគីជាមួយថ្នាក់ដឹកនាំដៃគូ ASEM មួយចំនួនធំដែរ»។

សូមបញ្ជាក់ថា កន្លងមកកម្ពុជាគ្រោងរៀបចំកិច្ចប្រជុំកំពូល ASEM លើកទី១៣នេះ នៅថ្ងៃទី១៦-១៧ ខែវិច្ឆិកា ឆ្នាំ២០២០ ប៉ុន្តែដោយសារបញ្ហារាតត្បាតជំងឺកូវីដ១៩ រាជរដ្ឋាភិបាលក៏បានស្នើលើកពេលម្ដងរួចទៅហើយ ដោយគ្រោងនឹងរៀបចំកិច្ចប្រជុំដ៏ធំនេះ មកពាក់កណ្ដាលឆ្នាំ២០២១ ហើយក៏មិនអាចរៀបចំបាន និងរហូតសម្រេចចុងក្រោយ នៅចុងខែវិច្ឆិកា ឆ្នាំ២០២១ ខាងមុខនេះតែម្ដង។

កម្ពុជាបានក្លាយជាសមាជិករបស់កិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប នៅឆ្នាំ២០០៤ និងត្រូវបានផ្ដល់សេចក្ដីទុកចិត្តឲ្យធ្វើជាម្ចាស់ផ្ទះ រៀបចំកិច្ចប្រជុំនេះ លើកទី១៣ ក្រោមប្រធានបទ៖ «ការពង្រឹងពហុភាគីនិយម ដើម្បីកំណើនរួម» ដោយនឹងមានការចូលរួមពីសំណាក់ថ្នាក់ដឹកនាំកំពូល នៃប្រទេសនៅតំបន់អឺរ៉ុប និងអាស៊ី ជាង ៥០ប្រទេស លេខាធិការដ្ឋានអាស៊ាន និងសហភាពអឺរ៉ុប។

ASEM ត្រូវបានបើកកិច្ចប្រជុំជាលើកដំបូងកាលពីឆ្នាំ១៩៩៦ ក្នុងទីក្រុងបាងកក ប្រទេសថៃ ដោយមានការចូលពីប្រទេសចំនួន១៥ នៃសហភាពអឺរ៉ុប និងប្រទេសចំនួន៧ នៃសមាជិកអាស៊ាន បូកថែមប្រទេសចិន ជប៉ុន កូរ៉េខាងត្បូង និងស្នងការអឺរ៉ុបប៉ុណ្ណោះ។ នៅពេលនោះអឺរ៉ុប បានទទួលស្គាល់ពីការ អភិវឌ្ឍការលូតយ៉ាងរហ័ស និងសក្ដានុពលនៅក្នុងតំបន់អាស៊ី ហើយគេចង់ពង្រឹងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ តាមរយៈការពង្រឹង និងការធ្វើទំនើបកម្មទំនាក់ទំនងលើវិស័យ ឬសរសរស្ដម្ភបីគឺ៖ នយោបាយ សេដ្ឋកិច្ច និងវប្បធម៌។

កិច្ចប្រជុំកំពូល ASEM គឺជាការជួបគ្នារវាង ២ឆ្នាំម្ដង របស់ប្រមុខដឹកនាំរដ្ឋ និងរដ្ឋាភិបាល, ប្រធាន នៃក្រុមប្រឹក្សាអឺរ៉ុប, ប្រធាននៃស្នងការអឺរ៉ុប និងអគ្គលេខាធិការ នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ហៅកាត់ថាអាស៊ាន។ វាបានក្លាយជាវេទិកាមួយយ៉ាងសំខាន់ សម្រាប់កិច្ចសហប្រតិបត្តិការជាដៃគូ ក្នុងការថែរក្សាសន្តិភាព ស្ថេរភាព ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចប្រកបដោយចីរភាព៕

# ក្រសួងទេសចរណ៍បង្ហាញម្ហូបខ្មែរក្នុងវីដេអូ ផ្សព្វផ្សាយទេសចរណ៍





*អត្ថបទ៖ ផល សុផានិត*

ក្រោមក្របខណ្ឌ «កម្មវិធីពង្រឹងសមត្ថភាពពាណិជ្ជកម្មក្នុងវិស័យទេសចរណ៍» (TCBP) ដែលទទួលបានជំនួយហិរញ្ញប្បទានពីទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD) ដឹកនាំអនុវត្តដោយក្រសួងទេសចរណ៍ មានសកម្មភាពជាយុទ្ធសាស្ត្រជាច្រើន ដែលបាននិងកំពុងផ្ដល់ផ្លែផ្កាជាបន្តបន្ទាប់ ចូលរួមទ្រទ្រង់ដល់ការអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជា ពិសេសនៅក្នុងដំណាក់កាលចុងក្រោយនេះ ដែលទេសចរណ៍កម្ពុជា បាននិងកំពុងទទួលរងឥទ្ធិពលអវិជ្ជមានយ៉ាងខ្លាំងពីវិបត្តិជំងឺកូវីដ-១។

នៅក្នុងកិច្ចប្រជុំត្រួតពិនិត្យវឌ្ឍនភាពការងារ រវាងក្រុមអង្គភាពគ្រប់គ្រងគម្រោងរបស់ក្រសួងទេសចរណ៍ ដឹកនាំដោយលោក អាំង សុវណ្ណរ័ត្ន នាយកគម្រោង TCBP ជាមួយទីភ្នាក់ងារ AFD ដឹកនាំដោយលោកស្រី Anne Chapalain នាយករងទីភ្នាក់ងារ AFD ប្រចាំកម្ពុជា មានការបង្ហាញពីសមិទ្ធផលសកម្មភាពនានា ទាំងរបាយការណ៍សិក្សា, ការវិភាគវាយតម្លៃ, ការជំរុញពិពិធកម្មផលិតផល និងគោលដៅទេសចរណ៍, ការធ្វើទំនើបកម្មការផ្សព្វផ្សាយ និងការធ្វើទីផ្សារទេសចរណ៍, ការពង្រឹងសមត្ថភាព ស្ថាប័នរដ្ឋ និងវិស័យឯកជន, ជំនួយផ្នែកច្បាប់ និងការអភិវឌ្ឍវិស័យទេសចរណ៍វៃឆ្លាតជាដើម។ ជាក់ស្ដែងនៅក្នុងកិច្ចប្រជុំនេះ ក៏មានការបង្ហាញវីដេអូផ្សព្វផ្សាយស្ដីពី «ការលើកកម្ពស់កិត្តិនាមទេសចរណ៍កម្ពុជា តាមរយៈរសជាតិ និងភាពទាក់ទាញ ដ៏ល្អបំផុតនៃម្ហូបអាហារខ្មែរ» ដែលត្រូវបានផលិតឡើងជា ២ភាសា ខ្មែរ និងអង់គ្លេស ដើម្បីត្រៀមជាស្រេចក្នុងការជំរុញ ការងើបឡើងវិញនៃសកម្មភាពទេសចរណ៍ ក្នុងស្រុក ក៏ដូចជាត្រៀមទាក់ទាញភ្ញៀវទេសចរអន្តរជាតិនៅពេលខាងមុខ។

តាមរយៈវីដេអូបានបង្ហាញពីម្ហូបអាហារខ្មែរ ជាមួយគ្រឿងផ្សំសំខាន់ៗក្នុងស្រុក ផ្សារភ្ជាប់ជាមួយសក្ដានុពល និងភាពទោលនៃគោលដៅទេសចរណ៍នៅទូទាំងប្រទេស ដើម្បីផ្សព្វផ្សាយពីសកម្មភាពទេសចរណ៍សម្រាប់ភ្ញៀវជាតិ និងអន្តរជាតិ ដោយផ្ដោតលើវិសាលភាពចំនួន២គឺ៖ ម្ហូបអាហារជាផលិតផលទេសចរណ៍ និងការធ្វើទីផ្សារទេសចរណ៍ដោយផ្ដោតលើម្ហូបអាហារ ជាចំណែកទីផ្សារទេសចរណ៍ប្រកបដោយសក្ដានុពល៕

# កម្ពុជានាំចេញអង្ករបានជាង ២៣ម៉ឺនតោន ធ្លាក់ចុះ៣៤% នៅ៥ខែដំបូងឆ្នាំនេះ

*អត្ថបទ៖ ផល សុផានិត*

នៅរយៈពេល៥ខែឆ្នាំ២០២១នេះ កម្ពុជាបាននាំចេញអង្ករចំនួន ២៣៣ ០៣១តោន ថយចុះចំនួន ១២៣ ០៦៦ តោន ស្មើនឹង -៣៤.៥៦% បើធៀបនឹងបរិមាណនាំចេញ ក្នុងរយៈពេល ៥ខែឆ្នាំ២០២០ ដែលមានចំនួន ៣៥៦ ០៩៧ តោន។ នេះបើតាមរបាយការណ៍របស់លោក វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ការនាំចេញអង្ករមានការថយចុះចំនួន -៣៤.៥៦% ត្រូវបានរដ្ឋមន្ត្រីកសិកម្មអះអាងថា ដោយសារតម្លៃដឹកជញ្ជូន មានការកើនឡើងខ្ពស់។

របាយការណ៍បានបន្តថា ការនាំចេញអង្ករក្នុងខែឧសភា ឆ្នាំ២០២១ មានចំនួន ៤០ ៥៣៦ តោន ថយចុះចំនួន ១៥ ៣០៩ តោន ស្មើនឹង -២៧.៤១% បើធៀបនឹងខែឧសភា ឆ្នាំ២០២០ ដែលមានចំនួន ៥៥ ៨៤៥ តោន។

សម្រាប់ប្រភេទអង្ករនាំចេញវិញ នៅ៥ខែមកនេះ ~អង្ករក្រអូបគ្រប់ប្រភេទមានចំនួន ១៦០ ៤៥៣ តោន ស្មើនឹង ៦៨.៨៦% អង្ករសគ្រប់ប្រភេទមានចំនួន ៦៧ ៨៤៣ តោន ស្មើនឹង ២៩.១១% និងអង្ករចំហុយមានចំនួន ៤ ៧៣៥ តោន ស្មើនឹង២.០៣% ។

អង្ករបាននាំចេញទៅកាន់ទិសដៅសហភាពអឺរ៉ុបចំនួន២០ ប្រទេស មានបរិមាណសរុបចំនួន ៥៥ ១៨៨តោន ស្មើនឹង ២៣.៦៦% ទិសដៅប្រទេសចិនមានបរិមាណសរុបចំនួន ១២០ ៨៣៤តោន ស្មើនឹង ៥១.៨៦% ទិសដៅអាស៊ានចំនួន ៥ប្រទេស មានបរិមាណសរុបចំនួន ២១ ៨៤៨តោន ស្មើនឹង ៩.៣៨% និងទិសដៅដទៃទៀតចំនួន១៩ប្រទេស មានបរិមាណសរុប ៣៥ ១៦១តោន ស្មើនឹង ១៥.១% ។

ដោយឡែកសម្រាប់ការនាំចេញស្រូវវិញ ក្នុងរយៈពេល៥ខែឆ្នាំ២០២១ កម្ពុជានាំចេញស្រូវចំនួន ១ ៦១៤ ២១១តោន ទៅកាន់ប្រទេសវៀតណាម និងប្រទេសអារ៉ាប់រួម (មានវិញ្ញាបនបត្រភូតគាមអនាម័យចំនួន ៨៥៥ ២០២.៥២ តោន) ដែលមានការកើនឡើងចំនួន ៧៤៨ ១២៩តោន (៨២%) បើធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ២០២០ ដែលមានចំនួន ៨៨៥ ១៨៦តោន៕

# ឯកអគ្គរាជទូតកម្ពុជាស្នើក្រុមហ៊ុនអេឡិចត្រូនិចកូរ៉េផលិតម៉ូតូកង់បីប្រើអគ្គិសនីនៅកម្ពុជា

*អត្ថបទ៖ អរិយបុត្រ*

លោក ឡុង ឌីម៉ង់ ឯកអគ្គរាជទូតកម្ពុជាប្រចាំនៅសាធារណរដ្ឋកូរ៉េ បានស្នើឲ្យក្រុមហ៊ុន អេឡិចទ្រិច អែលអេស( LS Electric) ពិនិត្យលទ្ធភាពសហការជាមួយ ក្រុមហ៊ុន អាញៀន (Onion) ដើម្បីផលិតម៉ូតូកង់បី ដែលប្រើប្រាស់អគ្គិសនី ដំបូងបំផុតនៅកម្ពុជា។



ការស្នើបែបនេះបានធ្វើឡើងនៅក្នុងអំឡុងពេលដែល លោក និងបណ្ដាឯកអគ្គរាជ អគ្គរដ្ឋទូតអាស៊ានទាំង១០ ប្រចាំនៅសាធារណរដ្ឋកូរ៉េ បានចុះទៅធ្វើទស្សនកិច្ចចំនួន២លើកនៅទីស្នាក់ការកណ្ដាលក្រុមហ៊ុន អេឡិចទ្រិច អែលអេស នាទីក្រុងសេអ៊ូល និងនៅរោងចក្រផលិតរបស់ក្រុមហ៊ុន នាទីក្រុង ចុងយ្យូ (Cheongju) ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យការទូតសេដ្ឋកិច្ច និង ស្វែងយល់ដំណើរការផលិតគ្រឿងអេឡិកត្រូនិក នៃរោងចក្រវៃឆ្លាត (Smart factory) ដែលអាចជំរុញល្បឿនចង្វាក់ផលិតកម្ម និងមានប្រសិទ្ធភាពខ្ពស់។

ក្នុងឱកាសនៃដំណើរទស្សនកិច្ចនោះ លោក ឡុង ឌីម៉ង់ បានយកឱកាសនេះដោយជំរុញក្រុមហ៊ុន អេឡិចទ្រិច អែលអេស នេះសហការជាមួយក្រុមហ៊ុនផលិតម៉ូតូកង់បី ដែលប្រើប្រាស់អគ្គិសនីដំបូងបំផុតនៅកម្ពុជា ដែលកន្លងមកស្ថានទូតបានសម្របសម្រួលជាមួយស្ថាប័ននានានៅកម្ពុជា ដើម្បីបានសហការវិនិយោគលើផ្នែកបច្ចេកវិទ្យា និងការផលិតម៉ូតូកង់បី បែបឆ្លាតវៃយនៅកម្ពុជា។

ជាលទ្ធផលក្រុមហ៊ុន អេឡិចទ្រិច អែលអេស នឹងយកមកសំណើនេះទៅសិក្សា ហើយពិនិត្យលទ្ធភាពក្នុងការសហការជាមួយស្ថានទូត ដើម្បីបាននាំយកបច្ចេកវិទ្យាផលិតដ៏ទំនើបនេះទៅបំពាក់នៅរោងចក្រផលិតនានានៅកម្ពុជានាពេលអនាគតផងដែរ។ នេះបើតាមសេចក្ដីរាយការណ៍តាមបណ្ដាញសង្គមរបស់ លោកអគ្គរាជទូត។

សូមបញ្ជាក់ថា ក្រុមហ៊ុនអេឡិចទ្រិច អែលអេស ជាក្រុមហ៊ុនធំលំដាប់ពិភពលោក មានរោងចក្រចំនួន៨ មជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍចំនួន៤ ដៃគូ ចំនួន ១៣ និងមានសាខាចែកចាយចំនួន ១៦ នៅទូទាំងពិភពលោក។ ផលិតផលសំខាន់ៗរបស់ក្រុមហ៊ុន មានឧបករណ៍បំបែកសៀគ្វី និងកុងតាក់ភ្លើង ហើយមានទំហំផលិតកម្មប្រចាំឆ្នាំដល់ទៅ ២.៦លានគ្រឿងឯណោះ។ ឧបករណ៍ទាំងនេះអាចប្រើប្រាស់បានសម្រាប់ជាមុខងារប្រព័ន្ធបច្ចេកវិទ្យាតម្លើងរោងចក្រ និងក៏ដូចជាឧបករណ៍ដទៃទៀតដែលពឹងផ្អែកលើប្រព័ន្ធបច្ចេកវិទ្យាទំនើបដូចជា Cyber Physical System (CPS), ប្រព័ន្ធ Internet of Things (IoT) និងប្រព័ន្ធ Internet of Service (IoS) ជាដើម។

លោក កូ ចា យ៉ុន (Koo Ja-kyun ) ប្រធានក្រុមហ៊ុន បានលើកឡើងក្នុងដំណើរទស្សនកិច្ចនោះដែរ ថា ទាំងចំណេះដឹង និងបទពិសោធដ៏សំបូរបែបផ្នែកបច្ចេកវិទ្យា និងការវិនិយោគរបស់ក្រុមហ៊ុននៅលើពិភពលោកអាចបង្កើតភាពជាដៃគូជាមួយប្រទេសអាស៊ាន ដើម្បីបង្កើតតម្លៃថ្មី និងឱកាសប្រកួតប្រជែងក្នុងវិស័យឧស្សាហកម្មដ៏សំបូរបែប ជាពិសេសអាចសហការលើការផលិតឧបករណ៍អគ្គីសនីផ្សេងៗ រួមទាំងឧបករណ៍នៅក្នុងឧស្សាហកម្មរថយន្ត គ្រឿងសំភារៈជណ្ដើរយន្ត ឧស្សាហកម្មប្លាស្ទិក និងកៅស៊ូគ្រប់គ្រងទឹក ឧស្សាហកម្មឱសថ ជាដើម។ល។

លោកប្រធានក្រុមហ៊ុន ក៏បាននាំបណ្ដាអ្នកការទូតអាស៊ានទៅពិនិត្យមើលទីតាំងផលិតផ្សេងៗ ដែលជាផ្នែកសំខាន់នៃខ្សែផលិតកម្មវៃឆ្លាតរបស់រោងចក្រ។

បើតាមការបញ្ជាក់របស់លោកប្រធានក្រុមហ៊ុន ក្រោយពីរោងចក្រនេះត្រូវបានបង្កើតឱ្យដំណើរការតាមប្រព័ន្ធវៃឆ្លាត ពេលវេលាផលិតកម្ម ត្រូវបានកាត់បន្ថយដល់ពាក់កណ្ដាល ផលិតកម្មកើនឡើងរហូតដល់ ៦០ភាគរយ រីឯការប្រើប្រាស់ថាមពលបានថយចុះ ៦០ភាគរយ អត្រាផលិតផលដែលមានការខូចខាតក្នុងដំណើរការផលិតកាត់បន្ថយមកនៅត្រឹមតែ ៧ ឯកតាប៉ុណ្ណោះក្នុង១លានឯកតាផលិត៕

# កម្ពុជា-វៀតណាម ប្ដេជ្ញាធ្វើការយ៉ាងជិតស្និទ្ធ ក្នុងការពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ

*អត្ថបទ៖ ផល សុផានិត*

ប្រមុខការទូតកម្ពុជា-វៀតណាម បានបញ្ជាក់សារជាថ្មីនូវការប្ដេជ្ញាចិត្តរបស់ខ្លួន ដើម្បីធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្នា ក្នុងការពង្រីកបន្ថែមទៀតនូវទំនាក់ទំនងទ្វេភាគី និងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ ដើម្បីជាប្រយោជន៍រួមសម្រាប់ប្រជាជាតិ និងប្រជាជនទាំងពីរ។ នេះបើតាមការប្រកាសរបស់ក្រសួងការបរទេសកម្ពុជា នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២១។

ការប្ដេជ្ញាចិត្តនេះ បានធ្វើឡើងក្នុងជំនួបទ្វេភាគីរវាង លោកឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាមួយលោក ប៊ូយ ថាញ់សឺន រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ក្នុងឱកាសនៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសពិសេស អាស៊ាន-ចិន នៅប្រទេសចិន នាថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២១ ដើម្បីផ្លាស់ប្ដូរទស្សនៈ ស្ដីពីកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគី ដែលជាប្រយោជន៍រួម ជាពិសេសការរៀបចំប្រារព្ធខួបលើកទី៥៥ នៃការបង្កើតទំនាក់ទំនងការទូតរវាងកម្ពុជា និងវៀតណាម ក្នុងឆ្នាំ២០២២ ខាងមុខ។

តាមសេចក្ដីប្រកាសរបស់ក្រសួងការបរទេស, ក្នុងជំនួបនេះ រដ្ឋមន្ត្រីការបរទេសទាំងពីរ បានសម្ដែងការពេញចិត្តចំពោះទំនាក់ទំនងមិត្តភាពជាប្រពៃណីដ៏ល្អ និងកិច្ចសហប្រតិបត្តិការប្រកបដោយផ្លែផ្កាដែលត្រូវបានពង្រីកនៅក្នុងវិស័យជាច្រើនរួមមានពាណិជ្ជកម្ម ការវិនិយោគ សុខាភិបាល ការអប់រំ ទេសចរណ៍ និងការតភ្ជាប់រវាងប្រទេសទាំងពីរ ដែលត្រូវបានកសាងឡើង តាមរយៈមូលដ្ឋានទំនុកចិត្តដ៏រឹងមាំ ការយោគយល់គ្នា សាមគ្គីភាព និងភាពជាអ្នកជិតខាងល្អ។

លោកឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន បានសម្ដែងនូវការកោតសរសើរយ៉ាងខ្ពស់ចំពោះការផ្ដល់ជំនួយ និងការឧបត្ថម្ភរបស់រដ្ឋាភិបាល និងប្រជាជនវៀតណាម ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ នៅកម្ពុជា។ រដ្ឋមន្ត្រីការបរទេសទាំងពីរ បានសម្ដែងការពេញចិត្តចំពោះកំណើនគួរឱ្យកត់សម្គាល់នៃទំហំពាណិជ្ជកម្មទ្វេភាគី ទោះបីជួបប្រទះនូវបញ្ហាប្រឈមដែលបណ្ដាលមកពីជំងឺកូវីដ-១៩ ក៏ដូចជាកិច្ចប្រតិបត្តិការនៅច្រកព្រំដែនអន្តរជាតិ ម៉ឺនជ័យ-តាន់ណាម កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២១ ដោយអាជ្ញាធរខេត្តព្រៃវែងរបស់កម្ពុជា និងអាជ្ញាធរខេត្តតៃនិញរបស់វៀតណាម ដែលនឹងជួយសម្រួលពាណិជ្ជកម្មឆ្លងដែន និងការតភ្ជាប់រវាងប្រជាជន និងប្រជាជន។



«រដ្ឋមន្ត្រីការបរទេសទាំងពីរក៏បានបញ្ជាក់សារជាថ្មីនូវការប្ដេជ្ញាចិត្តរបស់ខ្លួន ដើម្បីធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្នា ក្នុងការពង្រីកបន្ថែមទៀតនូវទំនាក់ទំនងទ្វេភាគី និងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ ដើម្បីជាប្រយោជន៍រួមសម្រាប់ប្រជាជាតិ និងប្រជាជនទាំងពីរ»។ នេះបើតាមការអះអាងក្នុងសេចក្ដីប្រកាស។

ក្រសួងការបរទេសកម្ពុជា បានបញ្ជាក់ថា ក្នុងន័យនេះ រដ្ឋមន្ត្រីការបរទេសទាំងពីរបានឯកភាពដើម្បីរៀបចំកិច្ចប្រជុំលើកទី១៩ នៃគណៈកម្មាធិការរួមសម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគីដោយមានការចូលរួមផ្ទាល់ និងកិច្ចប្រជុំលើកទី៧ នៃកិច្ចពិគ្រោះយោបល់នយោបាយ រវាងក្រសួងការបរទេសនៃប្រទេសទាំងពីរ នៅចុងឆ្នាំ ២០២១ ឬដើមឆ្នាំ ២០២២។

លោកឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ក៏បានទទួលការអញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការនៅប្រទេសវៀតណាម ពីសំណាក់ឯកឧត្តម ប៊ូយ ថាញ់សឺន ក្នុងពេលវេលាសមស្របផងដែរ។ លោកក៏បានអញ្ជើញសមភាគីវៀតណាមមកធ្វើជាសហប្រធានដឹកនាំកិច្ចប្រជុំលើកទី-១៩ នៃគណៈកម្មាធិការរួមសម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគី និងទស្សនកិច្ចផ្លូវការមកកាន់កម្ពុជាផងដែរ៕

# ថវិកាសរុបចំនួន ៣២២,៨១ លានដុល្លារអាមេរិកត្រូវបានរាជរដ្ឋាភិបាលផ្ដល់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩




*អត្ថបទ៖ អមរិទ្ធ ដានុត*

រាជរដ្ឋាភិបាលកម្ពុជាបានចំណាយថវិកាសរុបចំនួន ៣២២,៨១ លានដុល្លារអាមេរិកទៅដល់គ្រួសារក្រីក្រ និងងាយរងគ្រោះចំនួន ៦៩៣ ៩៣៣គ្រួសារ ឬស្មើនឹងសមាជិកចំនួន ២ ៧៥០ ៥០១ នាក់ តាមរយៈកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ចាប់ពីថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០២០ រហូតដល់ថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០២១ ។

នៅក្នុងសេចក្ដីប្រកាសព័ត៌មាន របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី០៤ ខែមិថុនា ពីលទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាជាតិគាំពារសង្គមកាលពីថ្ងៃទី០១ កន្លងមកនេះ ដែលដឹកនាំដោយអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម បានឱ្យដឹងថា គ្រួសារក្រីក្រ និងងាយរងគ្រោះដែលបានមកផ្ទៀងផ្ទាត់ឈ្មោះ និងទទួលប្រាក់ឧបត្ថម្ភទាំងអស់នេះគឺរួមទាំងកុមារអាយុក្រោម ៥ឆ្នាំ, ជនមានពិការភាព, ចាស់ជរាអាយុចាប់ពី ៦០ឆ្នាំឡើង, និងគ្រួសារដែលមានសមាជិកផ្ទុកមេរោគអេដស៍ផងដែរ។

បើគិតត្រឹមខែ មិថុនា ឆ្នាំ ២០២១ នេះ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ត្រូវអនុវត្តបានរយៈពេលពេញ១ឆ្នាំ និងទទួលបានលទ្ធផលល្អប្រសើរ ដោយគ្រួសារក្រីក្រ និងងាយរងគ្រោះ បាន និងកំពុងទទួលបានការគាំពារ និងទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃ ពីរាជរដ្ឋាភិបាល។

ដើម្បីត្រៀមខ្លួនអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់នេះក្នុងជំហានបន្ទាប់ ដោយយោងតាមបរិបទ និងស្ថានភាពជាក់ស្ដែងនៃការរីករាលដាលនៃជំងឺកូវីដ-១៩, អង្គប្រជុំបានពិនិត្យ ពិភាក្សា និងផ្ដល់ការណែនាំបន្ថែម លើការគិតគូរអំពី ជំហានដែលត្រូវអនុវត្តបន្ត ដោយផ្ដោតការយកចិត្តទុកលើការរក្សាបាននូវលំនឹង ផ្នែកជីវភាពរស់នៅរបស់គ្រួសារ ក្រីក្រ និងងាយរងគ្រោះ ទាំងក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ-១៩ និងនៅពេលដែលស្ថានភាពមានភាពប្រសើរឡើង។

ជាមួយគ្នានេះដែរ អង្គប្រជុំក៏បានពិនិត្យលើសេចក្ដីព្រាងអនុក្រឹត្យស្ដីពីការកំណត់ប្រាក់ឈ្នួល ឬប្រាក់បៀវត្សជាប់ភាគទាន ដែលជាលទ្ធផល កិច្ចប្រជុំបានសម្រេចផ្ដល់នូវធាតុចូលបន្ថែម ដើម្បីឱ្យសេចក្ដីព្រាងអនុក្រឹត្យនេះកាន់តែមាន ភាពពេញលេញ មុននឹងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ អាចយកសេចក្ដីគោរពស្នើសុំការសម្រេចពីរាជរដ្ឋាភិបាល ដើម្បីដាក់ចេញឱ្យអនុវត្ត៕








## រដ្ឋាភិបាលចិនសន្យាថា នឹងនាំចូលផលិតផលកសិកម្មបន្ថែមទៀតពីកម្ពុជា ជាពិសេសអង្ករ និងស្វាយ

*អត្ថបទ៖ ផល សុផានិត*

រដ្ឋាភិបាលចិន បានសន្យាថា ខ្លួននឹងនាំចូលផលិតផលកសិកម្មបន្ថែមទៀតពីកម្ពុជា ជាពិសេសអង្ករ និងស្វាយ។ នេះបើយោងតាមសេចក្ដីប្រកាសព័ត៌មាន របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជា។

ការសន្យាខាងលើ បានបង្ហាញឡើង នៅព្រឹកថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២១ ក្នុងឱកាសដែល លោកឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជា ជួបពិភាក្សាទ្វេភាគីជាមួយ ជាមួយ លោក វ៉ាង យី ទីប្រឹក្សារដ្ឋ និងជារដ្ឋមន្ត្រីក្រសួងការបរទេសចិន ដែលជាផ្នែកមួយនៃទស្សនកិច្ចការងារ ដើម្បីផ្លាស់ប្ដូរទស្សនៈស្ដីពីការលើកតម្កើងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការកម្ពុជា-ចិន។

ក្រសួងការបរទេស បានស្រង់លទ្ធផលជំនួបនេះថា «លោក វ៉ាង យី បានរំលឹកឡើងវិញនូវការបន្តគាំទ្ររបស់ចិនដល់ការអភិវឌ្ឍជាតិរបស់កម្ពុជា និង ការពារឯករាជ្យ អធិបតេយ្យភាព និងបូរណភាពទឹកដី។ ចិនក៏បានសន្យាថា នឹងនាំចូលផលិតផលកសិកម្មបន្ថែមទៀតពីកម្ពុជា ជាពិសេសអង្ករ និងស្វាយ»។

ភាគីទាំងពីរបានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ រវាងកម្ពុជា និងចិន។ ភាគីទាំងពីរបានបញ្ជាក់ជាថ្មី នូវការប្ដេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការពង្រឹង និងធ្វើឱ្យកាន់តែស៊ីជម្រៅ នូវចំណងមិត្តភាពដូចដែកថែប ព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការបន្ថែមទៀត លើវិស័យជាច្រើន ដើម្បីជាប្រយោជន៍ដល់ប្រជាជននៃប្រទេសទាំងពីរ និងសំដៅកសាងសហគមន៍វាសនារួមកម្ពុជា-ចិន ។

តាងនាមឱ្យរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា លោក ប្រាក់ សុខុន បានសម្ដែង នូវអំណរគុណ យ៉ាងជ្រាលជ្រៅជូនដល់ថ្នាក់ដឹកនាំចិនចំពោះជំនួយដ៏សប្បុរស និងទាន់ពេលវេលា រួមមានឧបករណ៍ វេជ្ជសាស្ត្រ និងវ៉ាក់សាំង ដើម្បីជួយកម្ពុជាប្រយុទ្ធប្រឆាំងនឹងការផ្ទុះឡើងនៃជំងឺកូវីដ-១៩ ។

លោកឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ក៏បានសម្ដែងនូវការអបអរសាទរយ៉ាងស្មោះស្ម័គ្រ ចំពោះថ្នាក់ដឹកនាំ និងប្រជាជនចិន ក្នុងឱកាសប្រារព្ធខួប ១០០ឆ្នាំ នៃការបង្កើតគណបក្សកុម្មុយនីស្តចិន (១៩២១ -២០២១)។ លោកបានសម្ដែងនូវការកោតសរសើរខ្ពស់ចំពោះប្រទេសចិន ដែលសម្រេចបាននូវសមិទ្ធផលដ៏ធំធេងក្នុងការអភិវឌ្ឍជាតិរបស់ខ្លួន ជាពិសេសការសម្រេចបាននូវគោលដៅសតវត្សរ៍ទី១ ក្នុងការកសាងសង្គមប្រកបដោយវិបុលភាពមធ្យម។

រដ្ឋមន្ត្រីការបរទេសទាំងពីរ ក៏បានឯកភាពពន្លឿននីតិវិធីផ្ទៃក្នុង សម្រាប់ការផ្ដល់សច្ចាប័នលើ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន ដើម្បីជំរុញពាណិជ្ជកម្មវិនិយោគ ក៏ដូចជាទេសចរណ៍រវាង ប្រទេសទាំងពីរផងដែរ៕

# កុមារគ្មានទីពឹងនៅតែទទួលបានអាហារគ្រប់គ្រាន់ក្នុងពេលវិបត្តិកូវីដ



*លោក ងូវ ឆេវ (ឆ្វេង) និងកុមារនានាដែលបានមកទទួលយកបាយអាហារពីអង្គការផ្ទះបាយកុមារ។ សហការី*



*រូបភាព៖ UNICEF Cambodia២០២0Miguel Jeronimo*

*អត្ថបទ៖ ផល សុផានិត*

«ផ្ទះបាយកុមារ» គឺជាទីកន្លែងមួយសម្រាប់ផ្ដល់អាហារពេលព្រឹកមួយពេល ដល់កុមារក្រីក្រ និងរើសអេតចាយ នៅតាមចិញ្ចើមថ្នល់ដែលមានទីតាំងស្ថិតនៅផ្ទះលេខ ២៤ ផ្លូវ៤៥៤ សង្កាត់ទូលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ។

លោក ងូវ ឆេវ ប្រធានគ្រប់គ្រងផ្ទះបាយកុមារ បានឱ្យដឹងថា ផ្ទះបាយកុមារនេះបានបង្កើតឡើងរយៈពេល ជិត១១ឆ្នាំ ពោលនៅក្នុងកំឡុងឆ្នាំ២០១០។ លោកបានឱ្យដឹងទៀតថា មូលហេតុចម្បងដែលធ្វើឱ្យលោកបង្កើតផ្ទះបាយកុមារឡើងដោយសារតែមានចិត្តអាណិតអាសូរ ដល់កុមារក្រីក្រ កុមាររើសអេតចាយ នៅតាមចិញ្ចើមផ្លូវទាំងអស់ ដើម្បីឱ្យពួកគេទទួលបានអាហារពេលព្រឹក ឆ្ងាញ់មួយពេល ព្រោះថាពួកកុមារទាំងនោះ មិនមានលទ្ធភាពរកអាហារ ឱ្យបានគ្រប់គ្រាន់។

ប្រធានគ្រប់គ្រង បានបញ្ជាក់ថា៖ «បច្ចុប្បន្ននេះទោះបីជាស្ថិតនៅក្នុងបរិបទនៃជំងឺកូវីដ-១៩ ក៏ផ្ទះបាយកុមារនៅតែបន្តទទួលបានអំណោយពីសប្បុរសជនជាតិ និងអន្តរជាតិ ជាបន្តបន្ទាប់ ទោះបីតិចឬច្រើនក្ដី ដើម្បីជួយទំនុកបម្រុងដល់កុមារ ដែលងាយរងគ្រោះនៅក្នុងប្រទេសកម្ពុជា»។

ជាការពិតមិនអាចប្រកែកបាន ស្ថិតក្នុងវិបត្តិជំងឺកូវីដ-១៩ កុមារទាំងអស់នោះ តែងតែខ្វះនូវអាហារូបត្ថម្ភ សម្រាប់ទ្រទ្រង់រាងកាយ ព្រោះតែកុមារទាំងនោះតែងតែបរិភោគ អាហារដែលគ្មានជីវជាតិ។ បច្ចុប្បន្ននេះ ផ្ទះបាយកុមារតែងតែ ស្វះស្វែងរកជំនួយពីបណ្ដាសប្បុរសជននានា ជាបន្តបន្ទាប់ ដើម្បីផ្ដល់ម្ហូបអាហារជូនដល់ពួកគាត់ ព្រោះតែជារៀងរាល់ព្រឹកមានកុមារជាង១០០នាក់ បានទទួលទានអាហារនៅទីនេះ។

ក្រៅពីផ្ដល់អាហារពេលព្រឹក អង្គការខាងលើក៏បានផ្ដល់ជាកន្លែងបត់ជើង និងងូតទឹកសំអាតខ្លួនដល់កុមារនៅទីនេះផងដែរ។ កាយវិការសប្បុរសទាំងនេះ ក៏ជាការរួមចំណែក យ៉ាងសំខាន់ដើម្បីជួយដល់កុមារក្រីក្ររបស់កម្ពុជា ឱ្យទទួលបានអនាគតល្អប្រសើរនៅថ្ងៃខាងមុខ ជាពិសេសគឺការលើកទឹកចិត្តដល់កុមារ ឱ្យខិតខំរៀនសូត្រនៅសាលារៀន ដើម្បីឆ្ពោះទៅអនាគត ដ៏ភ្លឺស្វាង។

ជាមួយគ្នានេះផងដែរ ក្រសួងអប់រំ យុវជន និងកីឡា ក៏មានទិសដៅសម្រាប់ឆ្នាំ២០២១ និងឆ្នាំបន្តបន្ទាប់ទៀត សម្រាប់កម្មវិធីផ្ដល់ស្បៀងអាហារតាមរយៈសាលារៀន។ ក្រសួងអប់រំ កំពុងពិនិត្យលទ្ធភាពនូវការ គៀងគរថវិការ សម្រាប់កសាងផ្ទះបាយ កន្លែងទទួលទានអាហារដល់សិស្ស កន្លែងសម្អាតលាងដៃ និងបន្តសហការណ៍ ជាមួយកម្មវិធីស្បៀងអាហារពិភពលោក គណៈកម្មាធិការប្រតិបត្តិគាំពារសង្គម និងគ្រប់ដៃគូរ ដើម្បី អនុវត្តកម្មវិធីអាហារតាមសាលារៀន៕

# ចំនួនសត្វខ្សឹបនៅកម្ពុជាបានថយចុះយ៉ាងគំហុក

*អត្ថបទ៖ ផល សុផានិត*

ចំនួនសត្វខ្សឹបនៅកម្ពុជា បានថយចុះយ៉ាងគំហុកក្នុងអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ខណៈបច្ចុប្បន្នសត្វខ្សឹបមានវត្តមានភាគច្រើននៅក្នុងខេត្តកំពង់ធំ ប៉ុន្តែមានតិចតួចនៅក្នុងខេត្តសៀមរាប និងមានតិចតួចបំផុតនៅខេត្តបន្ទាយមានជ័យ បាត់ដំបង និងខេត្តពោធិ៍សាត់។ នេះបើតាមការផ្សាយរបស់អង្គការ WCS.

សត្វខ្សឹបរស់នៅតាមតំបន់វាលស្មៅធម្មជាតិដែលមានលាយឡំជាមួយហ្វូងគុម្ពោតព្រៃដុះរាយប៉ាយ។ ប្រទេសកម្ពុជាបានក្លាយជាទីជម្រកសម្រាប់វត្តមាននៃអនុប្រភេទ Houbaropsis bengalensis blandini ដែលនៅសេសសល់នៅលើពិភពលោក។

កត្តាគំរាមកំហែងធំៗដល់ការរស់នៅរបស់សត្វខ្សឹប រួមមាន៖ការបាត់បង់ទីជម្រកពាក់ព័ន្ធទៅនឹងការបំប្លែងតំបន់វាលស្មៅ និងតំបន់ដាំដុះស្រូវបែបយថាផល ទៅជាតំបន់ដាំដុះស្រូវបែបប្រពលវប្បកម្ម (ពីរទៅបីដងក្នុងមួយឆ្នាំ) ការប្រមាញ់ខុសច្បាប់ និងការហើរបុកទង្គិចជាមួយខ្សែបណ្ដាញអគ្គិសនី។

នៅក្នុងឆ្នាំ២០០៩ អង្គការ WCS និងដៃគូ បានបោះពុម្ពផ្សាយលទ្ធផលនៃការស្រាវជ្រាវរយៈពេលជាង១០ឆ្នាំ។ លទ្ធផលនៃការស្រាវជ្រាវនោះបានបង្ហាញថា ចំនួនសត្វខ្សឹបឈ្មោលដែលលោតបង្អួតខ្លួននៅរដូវបន្តពូជ តាមរយៈទិន្នន័យជំរឿនឆ្នាំ ២០១៨ មានតែ ១០៤ក្បាល ប៉ុណ្ណោះនៅកម្ពុជា។

ដើម្បីការពារនិងអភិរក្សប្រភេទសត្វដ៏កម្រនេះ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចបង្កើតតំបន់អភិរក្សសត្វខ្សឹបនៅជុំវិញបឹងទន្លេសាប ដែលបច្ចុប្បន្ននេះត្រូវបានកំណត់ឈ្មោះថា «តំបន់ការពារទេសភាពទំនាបខាងជើងទន្លេសាប» គ្រប់ដណ្ដប់លើផ្ទៃដីទំហំ ៣១.១៥៩ហិកតា ក្រោមអនុក្រឹត្យលេខ ៨៨.អនក្រ.បក លាតសន្ធឹងឆ្លងកាត់ខេត្តកំពង់ធំ និងខេត្តសៀមរាប។ អង្គការ WCS ធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួងបរិស្ថានដើម្បីអភិរក្សតំបន់នេះ និងការពារសត្វខ្សឹប ព្រមទាំងប្រភេទសត្វស្លាបកម្រៗដទៃទៀត ដូចជា ចាបព្រៃវែង ជាដើម។

សកម្មភាពអភិរក្សសំខាន់ៗរួមមាន៖ ការគាំទ្រដល់ការអនុវត្តច្បាប់ ការគ្រប់គ្រងតំបន់វាលស្មៅដោយមានការចូលរួមពីសហគមន៍ ការផ្សព្វផ្សាយបង្កើនការយល់ដឹងដល់សហគមន៍ ការការពារសម្បុកសត្វខ្សឹប ការលើកកម្ពស់គម្រោងស្រូវបែបនិរន្តរភាព ដែលជាយន្តការមួយគាំទ្រដល់និរន្តរភាពកសិកម្ម សម្រាប់ការអភិរក្សសត្វខ្សឹប និងការបង្កើតតំបន់ការពារធម្មជាតិថ្មីមួយនៅក្នុងខេត្តពោធិ៍សាត់។

សត្វខ្សឹបជាប្រភេទសត្វតំបន់វាលស្មៅ មានដើមកំណើតនៅឧបទ្វីបឥណ្ឌា ប្រទេសកម្ពុជា និងក៏ធ្លាប់មាននៅប្រទេសវៀតណាម ផងដែរ។ វាត្រូវបានចុះក្នុងបញ្ជីជាប្រភេទបក្សីជិតផុតពូជបំផុតនៅលើពិភពលោក នៅក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ហើយវាត្រូវបានប៉ាន់ប្រមាណថាមានចំនួនតិចជាង ៥០០ក្បាល នៅលើពិភពលោក។

យោងតាមប្រកាសលេខ ០២០ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សត្វខ្សឹបត្រូវបានធ្វើចំណាត់ថ្នាក់ជាប្រភេទសត្វ«ក្រម»។ ច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ នៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៥៦ និង ៦១ ស្ដីពីបទល្មើសធនធានធម្មជាតិថ្នាក់ទី៣ ជនទាំង ឡាយណាដែលចាប់ដាក់អន្ទាក់ ប្រមាញ់ ធ្វើឱ្យរបួស បំពុល សម្លាប់ យកចេញ ប្រមូលពងកូន និងសត្វព្រៃ ដែលជាប្រភេទងាយរងគ្រោះ ប្រភេទកម្រ ឬប្រភេទជិតផុតពូជបំផុត នឹងត្រូវទទួលទោសទណ្ឌជាប់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ និងពិន័យជាប្រាក់ចាប់ពី ១៥លានរៀល ដល់ ១៥០លានរៀល៕



# យុវជនប្រមាណជា ២០០ នាក់ ចូលរួមការប្រជុំយុវជនអាស៊ាន លើកទី១ ដោយគ្មានប្រធានបទ




*អត្ថបទ៖ អរិយបុត្រ*

ក្រុមយុវជននៅក្នុងតំបន់ប្រមាណជា ជាង ២០០ នាក់ បានជួបជុំគ្នាជាលើកទីមួយ តាមប្រព័ន្ធវីដេអូខុនហ្វេរ៉េន (Video Conference) ដើម្បីជជែកគ្នាអំពីបញ្ហាជាច្រើន នៅក្នុងតំបន់ជាពិសេស គឺបញ្ហាសុខុមាលភាពផ្លូវចិត្ត បំរែបំរួលអាកាសធាតុ ការរួបរួមគ្នាក្នុងសង្គម នៅក្នុងបរិបទនៃការរីករាលដាលនៃមេរោគកូវីដ ១៩ ប៉ុន្តែជំនួបនោះ គឺគ្មានប្រធានបទផ្លូវការឡើយ។

បណ្តាញព័ត៌មានស្រ្តេតថៃម ដែលមានមូលដ្ឋាននៅសិង្ហបុរីបានអះអាងថា នេះគឺជាជំនួបតាមអនឡាញ ដែលត្រូវបានរៀបចំឡើងដើម្បីឲ្យយុវជននៅក្នុងតំបន់ជជែកគ្នាអំពីបញ្ហាដែលកំពុងតែ ប្រឈមសម្រាប់ពួកគេនៅពេលដែលតំបន់កំពុងតែផ្ទុះនូវការរីករាលដាលនៃមេរោគកូវីដ ១៩ ។

ប្រភពដដែលបានអះអាងថា ជំនួបតាមប្រព័ន្ធអនឡាញនេះ គឺជាជំនួបដំបូងដែលត្រូវបានរៀបចំឡើងកាលពីចុងខែ ឧសភា កន្លងទៅ ដែលនេះគឺជាវេទិកាបង្រួបបង្រួមយុវជនអាស៊ានលើកទី ១ ដោយប្រមូលផ្តុំយុវជននិងយុវនារីជាង ២២០ នាក់មកពីបណ្តាប្រទេសអាស៊ានទាំង១០ ដើម្បីពិភាក្សានិងដោះស្រាយបញ្ហាសង្គម ដែលកំពុងតែកើតមានឡើងនៅក្នុងតំបន់។

ប្រភពដដែលបានបន្តថា ព្រឹត្តិការណ៍រយៈពេលពីរថ្ងៃនេះ បានរៀបចំដោយអង្គការសុខុមាលភាពស្ម័គ្រចិត្ត សិង្ហបុរី ដែលមានឈ្មោះថា ចាមីយ៉ាស (Jamiyah) អនុញ្ញាតឱ្យក្រុមយុវជននិងយុវនារីអាស៊ានចូលរួម ក្រុមពិភាក្សាដោយផ្អែកលើប្រធានបទដែលពួកគេចាប់អារម្មណ៍។

អ្នករៀបចំកម្មវិធីបាននិយាយថា ជំនួបនោះវាត្រូវបានគេហៅថា «អង្គសន្និសិទដែលគ្មានរបៀបវារៈ» ពីព្រោះវាជាអង្គសន្និសិទយុវជនដែលរៀបចំឡើងដោយគ្មានប្រធានបទដែលបានកំណត់ជាមុនហើយអ្នកចូលរួមត្រូវសំរេចថាត្រូវពិភាក្សាអ្វីតាមដែលពួកគេចង់ តាមដែលពួកគេបានលើកឡើង ដោយសេរី ដោយគ្មានការតម្រង់ទិសអ្វីទាំងអស់។

ប្រភពដដែលបានបន្តថា ក្រុមយុវជននិងយុវនារីដែលបានចូលរួមគឺ មានអាយុចន្លោះពី ១៨ ដល់ ៣៥ ឆ្នាំហើយភាគច្រើនគឺជាអ្នកដែលបានចូលរួមក្នុងការងារសហគមន៍ក៏ដូចជាការងារស្ម័គ្រចិត្តនានា ឬមានចំណង់ចំណូលចិត្តក្នុងការលើកកម្ពស់ភាពជាពលរដ្ឋសកម្ម និងចេះជួយគ្នាទៅវិញទៅមក។

ថ្លែងនៅក្នុងពិធីបើកកម្មវិធីនេះលោកម៉ាលីគី អូស្មាន ( Maliki Osman) រដ្ឋមន្រ្តីនៃទីស្តីការគណៈរដ្ឋមន្រ្តី សិង្ហបុរីបាននិយាយថា អាស៊ានប្រឈមនឹងបញ្ហាដែលមិនធ្លាប់មានពីមុនដែលបណ្តាលមកពីរោគរាតត្បាតកូវីដ១៩ ។

លោកថា សេដ្ឋកិច្ចអាស៊ានជារួមបានធ្លាក់ចុះ ៣,៤ ភាគរយកាលពីឆ្នាំមុនបើប្រៀបធៀបនឹងឆ្នាំ ២០១៩ ជាមួយនឹងភាពអត់ការងារធ្វើនៅក្នុងរដ្ឋសមាជិកអាស៊ានមានចាប់ពី ៣,១ ភាគរយដល់ ១៧,៧ ភាគរយ។

ពាក់ព័ន្ធនឹងបញ្ហាយុវជននិងយុវនារីវិញ លោកម៉ាលីគី បានបន្តថា សម្រាប់យុវជននិងយុវនារីផលប៉ះពាល់ដែលបណ្តាលមកពីជំងឺរាតត្បាតអាចមានលក្ខណៈច្រើនយ៉ាងច្រើនរូបភាព ហើយវាតែងតែកើតមាន នៅក្នុងប្រទេសមួយចំនួនដែលបានអនុវត្តការបិទខ្ទប់ប្រទេស ។

លោកបានសង្កត់ធ្ងន់ទៅលើបញ្ហាមួយចំនួន ដែលយុវជននិងយុវនារីបានប្រឈម ដូចជា ផលប៉ះពាល់នៃភាពឯកោសង្គម ហើយដោយសារតែភាពឯកោនេះហើយទើបវាអាចនាំឱ្យមានការព្រួយបារម្ភអំពីសុខភាពផ្លូវចិត្តក្នុងចំណោមយុវវ័យ។

លោកបានបន្ថែមថា ការបន្តកំណើនសន្តិភាពនិងវិបុលភាពនៅក្នុងតំបន់អាស៊ានគឺត្រូវតែពឹងផ្អែកលើការបង្កើតចំណងពហុភាគីនិងទ្វេភាគីរឹងមាំក្នុងចំណោមយុវជនអាស៊ាន ដូចនេះការជជែកគ្នាដើម្បីដោះស្រាយដែលប្រឈមគឺវាចាំបាច់បំផុត។

គណៈកម្មការរៀបចំកម្មវិធីបានអះអាងថា បន្ទាប់ពីការបើកការពិភាក្សាយុវជននិងយុវនារីដែលបានចូលរួមគឺបានជជែកគ្នាច្រើនលើសារៈសំខាន់នៃភាពជាពលរដ្ឋសកម្មនិងបញ្ហាប្រឈមនៃការតស៊ូមតិសង្គម។

បញ្ហាពីរនេះ គឺជាប្រធានបទពេញនិយមបំផុតដែលត្រូវបានពិភាក្សាដោយអ្នកចូលរួមរួម ក្រៅពីនោះក៏មានប្រធានបទមួយចំនួនទៀតទាក់ទងនឹងបញ្ហាសុខុមាលភាពផ្លូវចិត្ត ការប្រែប្រួលអាកាសធាតុ និងការលើកកម្ពស់ភាពស្អិតរមួតក្នុងសង្គម។

នាឱកាសនោះ កញ្ញា សេលីណា ហ្វេង យូន (Celina Feng Yuan) ជាអ្នកជំនាញខាងថតរូបជនជាតិសិង្ហបុរី អាយុ ១៧ ឆ្នាំមួយរូបដែលបានបង្កើតឡើងនូវកម្មវិធី មួយដែលជាគំនិតផ្តួចផ្តើមដើម្បីផ្សារភ្ជាប់សហគមន៍ក្នុងស្រុកនិងជនចំណាកស្រុកនៅសិង្ហបុរីបាននិយាយអំពីបទពិសោធន៍របស់កញ្ញាក្នុងនាមជាអ្នកដឹកនាំយុវជន។

កញ្ញាបាននិយាយថា៖ «សម្រាប់ខ្ញុំនរណាដែលមកដល់ប្រទេសសិង្ហបុរីការទទួលខុសត្រូវរបស់ខ្ញុំមិនត្រឹមតែចំពោះប្រជាជនសិង្ហបុរីប៉ុណ្ណោះទេវាគឺសម្រាប់មនុស្សគ្រប់គ្នាដែលនៅជុំវិញខ្ញុំនៅក្នុងសហគមន៍ដែលខ្ញុំរស់នៅ»។

កញ្ញាជានិស្សិតឆ្នាំទី ៥ នៃវិទ្យាស្ថានរ៉ាហ្វល (Raffles) បានចាប់ផ្តើមកម្មវិធីមួយ កាលពីឆ្នាំមុនក្នុងអំឡុងពេលមានការផ្ទុះឡើងនៃករណីកូវីដ១៩ នៅក្នុងអន្តេវាសិកដ្ឋានរបស់កម្មករចំណាកស្រុក។

តាមកម្មវិធីនោះ កញ្ញាបានជួយរៃអង្គាស់ប្រាក់សម្រាប់ពលករចំណាកស្រុកនិងរៀបចំការប្រកួតប្រជែងតន្ត្រីដែលបង្ហាញពីកិច្ចសហការរវាងប្រជាជនសិង្ហបុរីនិងពលករចំណាកស្រុក។

អារីហ្សា នូឃ្យូម ( Arizza Nocum) អាយុ ២៦ ឆ្នាំ ជាអ្នកនាំពាក្យមកពីប្រទេសហ្វីលីពីនបានអះអាង ថា មនុស្សគ្រប់គ្នាមានទំនួលខុសត្រូវនិងបន្ទុកដើម្បីក្លាយជាពលរដ្ឋសកម្មក្នុងការដោះស្រាយបញ្ហានានានៅក្នុងសង្គម។

អារីហ្សា បានអះអាងថា៖ «វាពិតជាចាំបាច់ណាស់នៅពេលនេះពីព្រោះយើងមានវិបត្តិត្រួតស៊ីគ្នាដែលធ្វើឱ្យវាពិបាកសម្រាប់មនុស្សគ្រប់គ្នាក្នុងការរស់នៅប្រចាំថ្ងៃដូចជាជំងឺរាតត្បាត ការប្រែប្រួលអាកាសធាតុ និងវិសមភាព»។

ឆ្លើយតបនឹងបញ្ហានេះ អារីហ្សា បានបង្កើតក្រុមការងារមួយ ដែលជាអង្គការក្រៅរដ្ឋាភិបាលមួយដែលសាងសង់បណ្ណាល័យនិងផ្តល់អាហារូបករណ៍ដល់កុមារដែលរស់នៅតំបន់ដែលរងផលប៉ះពាល់ដោយអំពើហិង្សានិងភាពក្រីក្រ។

អារីហ្សាបានបន្ថែមថា៖ «ភាពជាពលរដ្ឋសកម្មមិនមែនគ្រាន់តែដើម្បីមើលឃើញបញ្ហាដែលកំពុងកើតឡើងនៅជុំវិញខ្លួនយើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចជួយដោះស្រាយតាំងពីរឿងតូចតាចដើម្បីកាត់បន្ថយបន្ទុកនោះសម្រាប់អ្នកដទៃ»៕

## UN ប្រចាំកម្ពុជា គាំទ្ររាជរដ្ឋាភិបាល ក្នុងការប្រយុទ្ធនឹងជំងឺកូវីដ-១៩

*អត្ថបទ៖ ផល សុផានិត*

លោកស្រី Pauline Tameis អ្នកសម្របសម្រួលរបស់អង្គការសហប្រជាជាតិ ប្រចាំប្រទេសកម្ពុជាបានបញ្ជាក់ថា អង្គការសហប្រជាជាតិ ប្រចាំកម្ពុជា គាំទ្ររាជរដ្ឋាភិបាលកម្ពុជា ពិសេសក្រសួងសុខាភិបាល ក្នុងការប្រយុទ្ធ នឹងជំងឺកូវីដ-១៩ ។

ការថ្លែងរបស់លោកស្រី Pauline Tameis យ៉ាងដូច្នេះ ក្នុងឱកាសដែលទទួលបានអនុញ្ញាតពីឯកឧត្តម សាស្ត្រាចារ្យ ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល ឲ្យចូលជួបសម្តែងការគួរសម និងពិភាក្សាការងារនាទីស្តីការក្រសួង រសៀលថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២១ នេះ ដោយមានការចូលរួមលោកស្រីវេជ្ជបណ្ឌិត Li Ailanប្រធានអង្គការសុខភាពពិភពលោក ប្រចាំកម្ពុជា និង លោកស្រី Kristin Parcoប្រធានបេសកកម្ម អង្គការអន្តរជាតិទទួលបន្ទុកទេសន្តប្រវេសន៍ និង លោកជំទាវវេជ្ជបណ្ឌិត យក់ សម្បត្តិ រដ្ឋលេខាធិការក្រសួងសុខាភិបាល និងជាប្រធានក្រុមការងារប្រតិបត្តិការបច្ចេកទេស និងផ្គត់ផ្គង់នៃគណៈកម្មការអន្តរក្រសួង ដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ ។

លោកស្រី Pauline Tameis ក៏បានសម្តែងនូវការកោតសរសើរ និងថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជា និងក្រសួងសុខាភិបាល ចំពោះការងារគ្រប់គ្រងការរាតត្បាតនៃជំងឺកូវីដ-១៩ នៅប្រទេសកម្ពុជា។ អង្គការសហប្រជាជាតិក៏បានប្តេជ្ញាបន្តកិច្ចសហការ និងគាំទ្ររាជរដ្ឋាភិបាលកម្ពុជា ជាពិសេសក្រសួងសុខាភិបាលក្នុងការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ។

ជាមួយគ្នានោះដែរ លោក ម៉ម ប៊ុនហេង ក៏បានសម្តែងការកោតសរសើរដោយស្មោះ ចំពោះកិច្ចសហការ និងការគាំទ្ររបស់អង្គការសហប្រជាជាតិ ជាពិសេសអង្គការសុខភាពពិភពលោក និងដៃគូទាំងអស់ដែលតែងតែសហការ និងគាំទ្រយ៉ាងពេញទំហឹងដល់កិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងសុខាភិបាលក្នុងការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ៕



# ប្រជាជនដែលរុះរើផ្ទះបណ្តែតទឹក ត្អូញត្អែរអំពីទីលំនៅនិងមុខរបរ

*អត្ថបទ៖ កែវ កញ្ញា*

«បើមាន មិនមែនមករស់នៅលើទូកឲ្យគេដេញទេ មកពីអត់» អ្នកស្រី ស្នួញ សុភា បានស្រែកពីចម្ងាយ នៅពេលឮសំណួរអ្នកសារព័ត៌មានរបស់យើង សួរនាំអ្នកនៅក្បែរនោះអំពីការរុះរើផ្ទះបណ្តែតទឹកនៅតាមទន្លេ ដែលសាលារាជធានីភ្នំពេញបានចេញសេចក្តីប្រកាសឲ្យរុះរើចេញកាលពីថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២១ ។

កំពុងរើរបស់របរចេញពីទូកតូចល្មមដែលគាត់និងគ្រួសារបានរស់នៅ៩ឆ្នាំមកហើយនៅតាមដងទន្លេសាប ក្នុងភូមិកណ្តាល សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ អ្នកស្រីសុភា បានឲ្យថាការរស់នៅលើទូកមិនស្រួលនោះទេ គ្មានកន្លែងរស់នៅត្រឹមត្រូវ គ្មានកន្លែងបន្ទោបង់ «ខ្យល់មកម្តងៗមិនដឹងធ្វើម៉េច... ក្រ។ គេអ្នកមាន(រស់នៅ)សុទ្ធតែផ្ទះថ្ម សសរតេដ្ឋ ដូចខ្ញុំក្រ អត់មានលុយអត់មានកាក់ធ្វើផ្ទះនៅ... ដូចថា រស់តែម៉ាគែៗ បានព្រឹកអត់ល្ងាច បានល្ងាចអត់ព្រឹក។ ជួនណាទៅរកទៅ មានលុយទៅ បើអត់ទៅរកមានលុយណាចាយ? ខ្ចីលុយគេខ្ចីលុយឯងចាយទៅ កាលណារកបានទៅ សងបងប្អូនវិញ»។

ស្ត្រីវ័យ៥១ឆ្នាំរូបនេះ បន្តទៀតថា អនាគតទៅមុខទៀត មិនដឹងគិតយ៉ាងណានោះទេ។ អ្នកស្រីក៏មិនចេះអក្សរ ហើយគ្រួសារជាជនអន្តោប្រវេសន៍ដែលពឹងលើរបរនេសាទ និងរស់នៅលើទឹកប៉ុណ្ណោះ។ អ្នកស្រីបានពោលថា «អនាគត បើគេ (រដ្ឋាភិបាល) មានធម៌មេត្តាទៅ គេឲ្យដីមួយដុំនៅទៅ ហើយរកស៊ីខ្លួនឯងទៅ តែបើអត់លុយមិនដឹងទៅរកអី។ បើមានលុយ ចង់ធ្វើអីក៏បានដែរ ចង់ធ្វើប៉ូលិស ចង់ធ្វើប៉េអឹមក៏បាន»។

ក្នុងលិខិតរបស់សាលាក្រុងស្តីអំពីការរុះរើឬបែចល័តចិញ្ចឹមត្រី ផ្ទះបណ្តែតទឹក ផ្ទះទូកតូចៗ និងសំណង់មិនរៀបរយនៅលើផ្ទៃទន្លេ ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ បានទុកពេល១សប្តាហ៍ ដើម្បីឲ្យអ្នកដែលរស់នៅ និងធ្វើអាជីវកម្មរុះរើចេញ និងបានបញ្ជាក់ថា ការតាំងទីលំនៅទាំងនេះ គឺខុសនឹងច្បាប់របស់កម្ពុជា ដែលធ្វើឲ្យប៉ះពាល់ដល់ប្រព័ន្ធអេកូឡូហ្ស៊ី មានចរន្តទឹកហូរ គោករាក់ ពិសេសការប្រើប្រាស់ចំណីត្រី និងការបញ្ចេញកាកសំណល់ ការបន្ទោបង់ពាសវាលពាសកាលក្នុងទន្លេ ដែលធ្វើឲ្យខូចខាតធ្ងន់ធ្ងរដល់ជីវៈចម្រុះនៅក្នុងទឹក ខូចគុណភាពទឹក បំពុលបរិស្ថាន និងប៉ះពាល់ដល់សោភណ្ឌភាពរាជធានីភ្នំពេញ និងប៉ះពាល់ដល់សុខភាពប្រជាជនដែលប្រើប្រាស់ទឹកមិនស្អាត។

ជាមួយគ្នានេះដែរ រដ្ឋបាលរាជធានី ក៏បានឲ្យដឹងទៀតថា អ្នកដែលរឹងទទឹងមិនព្រមរុះរើ នឹងត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការតាមផ្លូវច្បាប់។

បុរសម្នាក់ឈ្មោះវីញ យឹងវ៉ាង អាយុ៣៦ឆ្នាំ បាននិយាយថា ទូករបស់គាត់ត្រូវបានសមត្ថកិច្ចអូសយកទៅទីណាក៏មិនដឹងទេ កាលពីថ្ងៃទី១៥ ខែមិថុនានេះ។ ហើយបែត្រីរបស់គាត់ក៏ខូចខាតច្រើនដែរ។ លោកយឹងវ៉ាង បន្ថែមថា «កូនត្រីទើបដាក់បាន២-៣អាទិត្យ ងាប់ចង់អស់ហើយ។ បែរត្រីអស់២លាន(រៀល) ត្រីប្រា ត្រីពោរ»។

លោកយឹងវ៉ាង ឲ្យដឹងទៀតថា ការទុកពេលរបស់អាជ្ញាធរឲ្យពួកគាត់គឺខ្លីពេក។ «ម៉ាអាទិត្យក៏រើមិនទាន់ដែរ មើលឥវ៉ាន់អាញ៉ែអាញ៉ៃពេញហ្នឹង»។ លោកវ៉ាងបានរៀបចំធ្វើផ្ទះនៅលើគោកក្បែច្រាំងទន្លេ ដោយប្រក់តង់និងស័ង្កសី២ គុណនឹង៣ម៉ែត្ររស់នៅបណ្តោះអាសន្ន ព្រោះគាត់គ្មានដីផ្ទាល់ខ្លួនឡើយ។ គាត់ប្រាប់ថា គាត់រស់នៅលើទូកក្នុងទឹកនៅក្នុងតំបន់នេះតាំងពីតូច គឺជាង៣០ឆ្នាំមកហើយ លោកបានបញ្ជាក់ថា «ធ្វើផ្ទះនៅ(លើដីក្បែរទន្លេ) បើមិនឲ្យនៅទៀតមិនដឹងទៅណាទេ»។

ភ្លាមៗក្រោយពីសាលារាជធានីភ្នំពេញបានចេញសេចក្តីប្រកាសឲ្យម្ចាស់បែចិញ្ចឹមត្រីនិងផ្ទះបណ្តែតរុះរើ ឬអូសចេញពីដងទន្លេក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ក្នុងរយៈពេលមួយសប្តាហ៍។ នៅថ្ងៃទី៤ ខែមិថុនាតំណាង ស្ថានទូតវៀតណាមប្រចាំនៅកម្ពុជា លោក វូ ក្វាងមីញ បានប្រតិកម្ម





ដោយបានលើកឡើងថា «រយៈពេលមួយសប្ដាហ៍សម្រាប់រុះរើ ទៅកាន់ទីតាំងថ្មី ជាការសម្រេចចិត្តភ្លាម មិនអាចអនុវត្តទៅរួចឡើយ គ្រួសារភាគច្រើនក្រីក្រណាស់»។ តាមលោក ក្វាងមីញ ប្រជាជនរស់លើផ្ទះបណ្ដែតទឹកនៅតាមដងទន្លេនេះ មានជនជាតិចាម ខ្មែរ ហើយភាគច្រើនគឺវៀតណាម ប្រមាណ ១០០០ គ្រួសារ។ ពួកគេរស់នៅជាង ៤០ឆ្នាំមកហើយ។

ចំណែក លោក ស៊ឹម ជី ប្រធានសមាគមវៀតណាម ប្រចាំនៅកម្ពុជា កាលពីថ្ងៃទី៨ ខែមិថុនា ក៏បានដាក់សំណើរទៅសាលារាជធានីភ្នំពេញ «ដើម្បីទីមួយស្នើសាលារាជធានីភ្នំពេញពិនិត្យឡើងវិញ អំពីរយៈពេលដែលបងប្អូនផ្លាស់ទៅទីតាំងផ្សេង រកពេលវេលាមួយណាដែលសមស្របបំផុត ដើម្បីឱ្យបងប្អូន ត្រៀមលក្ខណៈត្រឹមត្រូវសិន។ ក្នុងរយៈពេលខ្លីអីចឹងទៅ បងប្អូនមិនអាចរៀបចំ លក្ខណៈត្រឹមត្រូវ។ ទី២ ស្នើសុំឱ្យ សាលារាជធានីភ្នំពេញរកទីតាំងថ្មីឱ្យគាត់ដើម្បីឱ្យពួកគាត់ចិញ្ចឹមត្រីក្នុងបែ ដើម្បីចិញ្ចឹមជីវិតគ្រួសារ ព្រោះអីភាគច្រើនបងប្អូនបានរស់នៅចិញ្ចឹមគ្រួសារដោយចិញ្ចឹមត្រីជាច្រើនឆ្នាំមកហើយ។ ទី៣ ស្នើឱ្យមាន ថវិកាដើម្បីជួយផ្គត់ផ្គង់ឱ្យគាត់មានលទ្ធភាពនៅពេលចេញទៅនេះ»។

ចំណែកកិច្ចការផ្លូវទូតឯណោះវិញ តាមការចុះផ្សាយរបស់សារព័ត៌មានវៀតណាម ថាញ់នៀន បានឲ្យដឹងថា លោករដ្ឋមន្ត្រីការបរទេសវៀតណាម ប៊ូយ ថាញ់សឺន បានជួបដោយផ្ទាល់ជាមួយ លោក ប្រាក់ សុខុន រដ្ឋមន្ត្រីការបរទេសកម្ពុជា នៅទីក្រុងចុងឈីង ប្រទេសចិន កាលពីថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២១។ ក្នុងជំនួបនេះកាសែត ថាញ់នៀនបានចុះផ្សាយថា លោកប៊ូយ ថាញ់សឺន បានទទូចឲ្យអាជ្ញាធរមានសមត្ថកិច្ចកម្ពុជា ត្រូវសិក្សាឲ្យបានត្រឹមត្រូវធានាសិទ្ធិ និងសុវត្ថិភាពរបស់ជនជាតិវៀតណាម មុននឹងអនុវត្តគោលនយោបាយអ្វីមួយ។

លោក ប៊ូយ ថាញ់សឺន ៖ «ក្នុងពេលដែលអនុវត្តិគោលនយោបាយ ត្រូវតែមានផែនការឲ្យបានត្រឹមត្រូវ មិនឲ្យប៉ះពាល់ដល់សិទ្ធិ និងការរស់នៅរបស់ជនជាតិវៀតណាម ផ្ដល់លក្ខណៈងាយស្រួលដើម្បីជួយឲ្យអ្នករងផលប៉ះពាល់អាចមានជីវភាពរស់នៅធម្មតាឡើងវិញឲ្យបានឆាប់បំផុត រក្សា ឬផ្លាស់ប្ដូរមុខរបរឲ្យបានសមរម្យ និងទទួលបានសេវាកម្មចាំបាច់ បានគ្រប់គ្រាន់»។

ប្រភពដដែលបានបន្តថា ជាការឆ្លើយតបលោក ប្រាក់ សុខុន បញ្ជាក់ថា កម្ពុជានឹងបន្តយកចិត្តទុកដាក់ បង្កលក្ខណៈងាយស្រួលឲ្យនិស្សិត និយោជិកវៀតណាម រៀនសូត្រ និងរកស៊ី ក៏ដូចជាជនជាតិវៀតណាមអាចរស់នៅប្រទេសកម្ពុជាដោយស្ថិរភាព។

ទោះបីជាយ៉ាងណាក៏ដោយ អាជ្ញាធររាជធានីភ្នំពេញ នៅតែបន្តអនុវត្តតាមសេចក្ដីជូនដំណឹងរបស់ខ្លួន ដោយពន្យាពេល៣ថ្ងៃបន្ថែមឲ្យរុះរើដោយស្ម័គ្រចិត្តរហូតដល់ថ្ងៃទី១២ ខែមិថុនា ជាថ្ងៃកំណត់។ ជារួម ផ្ទះ និងបែរចិញ្ចឹមត្រីស្ទើរ១០០ភាគរយ បានរុះរើ។ មានម្ចាស់មួយចំនួន បានអូសផ្ទះ និងបែចេញទៅតាមទន្លេមេគង្គក្រោម ទៅកាន់ប្រទេសវៀតណាម តែត្រូវទើនៅត្រឹមព្រំដែន ក្នុងខេត្តកណ្ដាល ដោយសារ ប្រទេសទាំងពីរបិទ ព្រំដែនមិនឲ្យឆ្លងកាត់ក្រោមហេតុផលការពារការឆ្លងរីករាលដាលជំងឺកូវីដ-១៩ ។

អាជ្ញាធរខេត្តកណ្ដាលក៏បាន បណ្ដេញបន្តចំពោះផ្ទះ និងបែដែលអូសចេញពីរាជធានីភ្នំពេញ តាមដងទន្លេក្នុងខេត្តរបស់ខ្លួនបន្តទៀត។ រហូតមកដល់ថ្ងៃទី១៧ ខែមិថុនា នេះគឺមិនទាន់សេចក្ដីរាយការណ៍ណាមួយបញ្ជាក់នៅឡើយថាពួកគេនឹងត្រូវតាំងទីលំនៅបណ្ដោះអាសន្ននៅកន្លែងណានោះទេ។





" ត្រូវតែមានផែនការឲ្យបានត្រឹមត្រូវ មិនឲ្យប៉ះពាល់ដល់សិទ្ធិ និងការរស់នៅរបស់ជនជាតិវៀតណាម ផ្ដល់លក្ខណៈងាយស្រួលដើម្បីជួយឲ្យអ្នករងផលប៉ះពាល់អាចមានជីវភាពរស់នៅធម្មតាឡើងវិញឲ្យបានឆាប់បំផុត រក្សា ឬផ្លាស់ប្ដូរមុខរបរឲ្យបានសមរម្យ និងទទួលបានសេវាកម្មចាំបាច់ បានគ្រប់គ្រាន់ "



ពេលប្រជាជនវៀតណាមមានការជ្រួលច្របល់ និងសំរុះទៅប្រទេសវៀតណាមវិញ ប្រធានសមាគមវៀតណាម នៅកម្ពុជា លោក ស៊ឹម ជី នៅថ្ងៃទី១៣ខែមិថុនា បានអំពាវនាវ កុំឲ្យប្រជាជនវៀតណាមទៅវៀតណាមវិញ នៅពេលនេះ ។ ដោយសារកូវីដ-១៩ កំពុងផ្ទុះនៅប្រទេសវៀតណាម។ និងសូមឲ្យរក្សាភាពស្ងប់ស្ងាត់ គោរពតាមគោលនយោបាយរបស់រដ្ឋាភិបាល ដោយស្ម័គ្រចិត្តផ្លាស់ប្ដូរ ទៅកន្លែងថ្មី តាមបទបញ្ញត្តិ កុំភ័យស្លន់ស្លោ កុំវង្វេងស្មារតី កុំជជែក កុំស្ដាប់ពាក្យប្រទ្បោត និងមួលបង្កាច់ពីខាងក្រៅ។

សមាគមខ្មែរ - វៀតណាម នៅកម្ពុជា តែងតែឈរនៅក្បែរប្រជាជន។ សមាគមនឹងផ្ដល់ជំនួយស្បៀង និងជំនួយស្បៀងអាហារចាំបាច់ ដល់ប្រជាជន ដើម្បីឱ្យពួកគេមានអារម្មណ៍ថា មានសុវត្ថិភាពក្នុងការធ្វើឱ្យជីវិតមានស្ថេរភាព និងកាត់បន្ថយការលំបាកក្នុងការយកឈ្នះលើគ្រាលំបាកនេះ។

ចំណែកបែចិញ្ចឹមត្រីប្រមាណជា៣០០ កាលពីថ្ងៃទី ១៦ខែមិថុនា រដ្ឋបាលរាជធានីភ្នំពេញអនុញ្ញាតបណ្ដោះអាសន្ន ឲ្យទៅសំចតនៅតាមដងទន្លេសាប ក្នុងសង្កាត់សំរោង ខណ្ឌព្រែកព្នៅ។

ក្នុងរបាយការណ៍របស់អគ្គស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ដែលបានចុះផ្សាយកាលពីថ្ងៃទី១៥ ខែមិថុនានេះ បានឲ្យដឹងថា ក្នុងរយៈពេលបីថ្ងៃតាំងពីថ្ងៃទី១២-១៤ ខែមិថុនានៃការចុះរុះរើទីតាំងនៅលើទឹកនេះ បានធ្វើឡើងនៅក្នុងខណ្ឌចំនួន៥ ដែលសរុបមានប្រមាណ១៣៨១កន្លែង។

របាយការណ៍ដដែលបានឲ្យដឹងថា ក្នុងអំឡុងពេលនៃការរុះរើ «គេមិនឃើញមានការតវ៉ាប្រឆាំងណាមួយពីសំណាក់ក្រុមប្រជាពលរដ្ឋរស់នៅរស់នៅខុសច្បាប់នៅលើផ្ទៃទឹកនោះទេ គឺពួកគាត់បានចូលរួមអនុវត្តតាមការណែនាំរបស់សាលារាជធានីភ្នំពេញ»។

យោងតាមរបាយការណ៍ដដែលនេះឱ្យដឹងថា រយៈពេល០៣ថ្ងៃនៃការអនុវត្តវិធានការរុះរើនេះ មានបែចិញ្ចឹមត្រី៧៦៣បែត្រូវបានរុះរើ ចំណែកផ្ទះបណ្ដែតទឹក៦២៨ខ្នងក៏ត្រូវបានរុះរើផងដែរ។

# ក្នុងចំណោមប្រាសាទបុរាណ ទូទាំងប្រទេស មាន៨៥៧កន្លែង ស្ថិតក្នុងតំបន់ការពារធម្មជាតិ

*អត្ថបទ៖ ផល សុផានិត*

មន្ត្រីជំនាញនៃក្រសួងបរិស្ថាន បានបញ្ជាក់ថា ក្នុងចំណោមប្រាង្គប្រាសាទបុរាណដ្ឋាន សរុបជាង ៥៣០០ កន្លែងនៅទូទាំងប្រទេសកម្ពុជា ក្នុងនោះ មានបុរាណដ្ឋាន ប្រាង្គប្រាសាទ ស្ថិតក្នុង តំបន់ការពារធម្មជាតិសរុបមានចំនួន ៨៥៧ ទីតាំង។ ក្នុងនោះដែរគ្រាន់តែបុរាណដ្ឋានស្ថិតនៅក្នុង ឧទ្យានជាតិព្រះជ័យវរ្ម័ន «ភ្នំគូលែន» មានចំនួន ៤២៦ ទីតាំង ។

ក្រសួងបរិស្ថានបានបញ្ជាក់ទៀតថា ចំនួនបុរាណដ្ឋាននៅក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះអាច នៅមាន ច្រើនទៀតដែលស្ថិតក្នុងព្រៃជ្រៅមិនទាន់រកឃើញ។

លោក នេត្រ ភក្ត្រា រដ្ឋលេខាធិការនិងជាអ្នកនាំពាក្យនៃក្រសួងបរិស្ថាន បានអះអាងថា ប្រព័ន្ធតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សចម្រុះកម្ពុជាបច្ចុប្បន្នមានសរុបមានចំនួនជាង ៧០ ទីតាំងនៅក្នុងខេត្តចំនួន ២១ ក្នុងចំណោមខេត្តរាជធានី ២៥ របស់កម្ពុជាមានផ្ទៃដីសរុបទំហំ ៧៣លានហិកតា ស្មើប្រមាណ ៤១%នៃផ្ទៃដីប្រទេសកម្ពុជា។

លោកថាតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះមិនត្រឹមតែសម្បូណ៌ ដោយធនធានធម្មជាតិ ព្រៃឈើ សត្វព្រៃ និងរុក្ខជាតិតូចធំដែល







រូបភាព៖ ស៊ីអេសស៊ី

មានតម្លៃផ្នែកប្រព័ន្ធអេកូឡូស៊ី និងការអភិរក្សជីវៈចម្រុះនោះទេ តែក៏មានបុរាណដ្ឋានដែលជាជង្រុកនៃ វប្បធម៌ ប្រពៃណីទំនៀម ទំលាប់របស់ជាតិសាសន៍ខ្មែរ ដ៏សម្បូណ៌បែប។

ក្រសួងបរិស្ថានបានសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈក្នុងការការពារ និងអភិរក្សបុរាណដ្ឋានទាំងនេះ។ ក្រសួងបរិស្ថានមានយុត្តាធិការលើការគ្រប់គ្រង និងអភិរក្សធន

ធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្ស ។ ចំណែកក្រសួងវប្បធម៌និងវិចិត្រសិល្បៈ មានតួនាទីក្នុងការអភិរក្សការពារបុរាណដ្ឋាននិងប្រាង្គប្រាសាទក្នុងតំបន់ការពារធម្មជាតិទាំងនោះ ដូចជា ការជួសជុល ថែទាំជាដើម។ នេះគឺជាកិច្ចសហការមួយប្រកបដោយការទទួលខុសត្រូវក្នុងនាមរាជរដ្ឋាភិបាលដើម្បី ការពារ និងអភិរក្សសម្បត្តិធម្មជាតិផង និងការពារសម្បត្តិបេតិកភណ្ឌវប្បធម៌ផងដែលមានតម្លៃមហាសាលសម្រាប់ជាតិ និងប្រជាជនកម្ពុជា។

ប្រាង្គប្រាសាទនិងបុរាណដ្ឋានដែលស្ថិតក្នុងតំបន់ការពារធម្មជាតិបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធនឹង ធនធានធម្មជាតិ។ បុរាណដ្ឋានទាំងនេះ បាននិងកំពុងក្លាយជាតំបន់ទេសចរណ៍យ៉ាងសំខាន់ផ្សារ ភ្ជាប់នឹងទេសចរណ៍ធម្មជាតិ និងបានកំពុងទាក់ទាញការចាប់អារម្មណ៍របស់ភ្ញៀវទេសចរជាតិ និងអន្តរជាតិដូចជាប្រាសាទជាំស្រម ក្នុងដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព ដែលជាការផ្សារភ្ជាប់រវាងទេសចរណ៍សត្វស្លាបនិងវប្បធម៌ប្រពៃណីទំនៀមទម្លាប់ពលរដ្ឋខ្មែរ។

ក្រសួងបរិស្ថានក៏បានអំពាវនាវដល់ពលរដ្ឋទាំងឡាយដែលរស់នៅក្នុងតំបន់ការពារធម្មជាតិដែលមាន បុរាណដ្ឋាន និងប្រាសាទបុរាណ សូមចូលរួមការពារ និងអភិរក្សឱ្យបានល្អដើម្បីថែរក្សាកេរមរតកដូនតា ខ្មែរឱ្យនៅគង់វង្ស និងអាចផ្តល់ផលប្រយោជន៍ទាំងការសិក្សាស្រាវជ្រាវផ្នែកបុរាណវិទ្យា និងការសិក្សា ស្វែងយល់ពីប្រពៃណីវប្បធម៌ទំនៀមទម្លាប់ប្រជាពលរដ្ឋនៅតំបន់នោះ៕

# ត្រីមាសទី១ ឆ្នាំនេះ មនុស្ស៣១នាក់ស្លាប់ដោយសារពុលស្រា ខណៈក្រសួងឱ្យមានការគ្រប់គ្រង និងទប់ស្កាត់ការលក់ បិត ឬលាយគ្មានបច្ចេកទេសត្រឹមត្រូវ

*អត្ថបទ៖ អមរិន្ទ ដានុត*

ក្រសួងសុខាភិបាលបានឱ្យដឹងនៅថ្ងៃសុក្រ ទី ០៤ ខែមិថុនានេះថា ករណីពុលស្រានៅក្នុងប្រទេសកម្ពុជាក្នុងត្រីមាសទី១ ឆ្នាំ ២០២១នេះ មានចំនួន៣១នាក់ក្នុងខេត្តបីផ្សេងគ្នា ដែលករណីចុងក្រោយនេះបានកើតឡើងនៅក្នុងស្រុកក្រគរ ខេត្តពោធិ៍សាត់ ដែលបានធ្វើឱ្យមនុស្សជិត១០នាក់បានស្លាប់ និងជាច្រើននាក់ទៀតឈឺ។



ក្រសួងសុខាភិបាលបានប្រកាសមូលហេតុនៃករណីស្លាប់បណ្ដាលមកពីការពុលស្រា នៅស្រុកក្រគរ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី០១ ខែមិថុនាកន្លងមកនេះ ដោយសារការពិសារស្រាដែលមានជាតិមេតាណុលខ្ពស់ និងមានការយឺតយ៉ាវក្នុងការស្វែងរកការព្យាបាលនៅមន្ទីរពេទ្យ ។

យោងតាមសេចក្ដីប្រកាសព័ត៌មានរបស់ក្រសួងសុខាភិបាល នៅថ្ងៃសុក្រនេះបានឱ្យដឹងថា តាមរយៈការចុះទៅពិនិត្យនិងស្រាវជ្រាវផ្ទាល់ដល់ទីកន្លែងកើតហេតុ ហើយនិងការសាកសួរបានរកឃើញថា មានការស្លាប់ដោយសារសង្ស័យពុលស្រាស និងស្រាថ្នាំ ជាបន្តបន្ទាប់ សរុបចំនួន៧នាក់ ដោយចាប់ផ្ដើមស្លាប់ពីថ្ងៃទី២៨ ខែឧសភា ដល់ថ្ងៃទី០២ ខែមិថុនា នៅក្នុងស្រុកក្រគរ។

ក្រសួងបានបន្តទៀតថា រហូតមកដល់ថ្ងៃទី៣ ខែមិថុនា ក្រុមស្រាវជ្រាវបានរកឃើញអ្នកប៉ះពាល់សរុប ៩៦ នាក់ បានបញ្ជូនទៅមន្ទីរពេទ្យបង្អែកស្រុកក្រគរ មន្ទីរពេទ្យបង្អែកខេត្ត និងមន្ទីរពេទ្យរាជធានីភ្នំពេញ ដោយផ្អែកលើស្ថានភាពសុខភាពរបស់គាត់មួយចំនួនបានជាសះស្បើយ និងមួយចំនួនទៀតបាននិងកំពុងសម្រាកនៅមន្ទីរពេទ្យនៅឡើយ។

មន្ត្រីសុខាភិបាលនិងអាជ្ញាធរមូលដ្ឋានបានយកសំណាកស្រាថ្នាំ និងស្រាស ពីទីតាំង៣កន្លែង សម្រាប់ធ្វើការវិភាគ និងបានផ្ញើរមកក្រសួងសុខាភិបាល ហើយលទ្ធផលពីមជ្ឈមណ្ឌលជាតិមន្ទីរពិសោធន៍សុខាភិបាល នៅថ្ងៃទី២ ខែមិថុនា បង្ហាញថាមន្ទីរពិសោធន៍ទទួលបានសំណាកស្រាថ្នាំ និងស្រាស ៤សំណាក មាន២សំណាក ស្រាស និងស្រាថ្នាំ ដែលមានសារធាតុមេតាណុលលើសកម្រិតខ្ពស់ពី៩,៥ដល់១៥ភាគរយដែលធ្វើឱ្យពុល ដែលកម្រិតមិនពុលនោះមិនត្រូវលើសពី០,១% ឡើយ។

ពាក់ព័ន្ធនឹងករណីឈឺនិងស្លាប់នេះ ក្រសួងសុខាភិបាលសន្និដ្ឋានថា៖ «ហេតុការណ៍ស្លាប់ នៅភូមិទាំង២នៃស្រុកក្រគរ ខេត្តពោធិ៍សាត់ បានកើតឡើងដោយសារពួកគាត់បានពិសាស្រាស ឬស្រាថ្នាំ ដែលមានអេតាណុលខ្ពស់ បញ្ជាក់តាមលទ្ធផលបានមកពីមន្ទីរពិសោធន៍»។

ក្រសួងបានបន្តថា ដោយហេតុថាករណីស្លាប់ដោយសារតែការបរិភោគស្រា មានសារធាតុមេតាណុលនេះ នៅបន្តកើតមានឡើងជាដដែលៗនៅក្នុងត្រីមាសទី១ នៃឆ្នាំ ២០២១ នេះ សរុបរួមមានអ្នកស្លាប់ចំនួន៣១នាក់ហើយ ដោយសារតែពុលស្រា ។

មានជាអាទិ៍ នៅស្រុកល្វាឯម ខេត្តកណ្ដាល ករណីពុលស្លាប់ចំនួន ១៤នាក់ ករណស្លាប់នៅស្រុកកំពង់ត្រាច ខេត្តកំពត ចំនួន១០នាក់ និងករណីស្លាប់នៅ ស្រុកក្រគរ ខេត្តពោធិ៍សាត់ ចំនួន៧នាក់។

លោកម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល បានក្រើនរំលឹក និងអំពាវនាវដោយទទូចដល់បងប្អូនប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ នៅទូទាំងរាជធានី-ខេត្តទាំងអស់មិនត្រូវចូលរួមកុំពិសាស្រា ដែលបិតឬលាយគ្មានបច្ចេកទេសត្រឹមត្រូវ និងគ្មានការត្រួតពិនិត្យ ជាពិសេសគឺ ពិសាស្រាស ឬស្រាថ្នាំ ដែលយកមេតាណុលមកលាយនេះតែម្ដង។

លោកបានបន្តថា ៖ «ចំពោះអ្នកប្រកបអាជីវកម្ម ហាមដាច់ខាត កុំយកសារធាតុមេតាណុលមកលាយធ្វើស្រាស ដែលបង្កឱ្យពុលនិងស្លាប់បាត់បង់ជីវិត ចំណែក បងប្អូនអាជ្ញាធរខេត្ត ស្រុក ក្រុង ខណ្ឌ រដ្ឋបាលឃុំ/សង្កាត់ ត្រូវចាត់តាំងកម្លាំងគ្រប់គ្រង ឃ្លាំមើល និងទប់ស្កាត់ការលក់ស្រាបិត ឬលាយគ្មានបច្ចេកទេសត្រឹមត្រូវ និងណែនាំប្រជាពលរដ្ឋ ជៀសវាងយកសារធាតុមេតាណុលលាយធ្វើស្រាសដែលបង្កឱ្យពុលនិងស្លាប់បាត់បង់ជីវិត។

លោក ម៉ម ប៊ុនហេង បានបន្ថែមថាប្រសិនបើប្រជាពលរដ្ឋមានបញ្ហាសុខភាព ឬមានរោគសញ្ញានៃការពុលសាដូចជាឈឺក្បាល ក្អួត ឈឺពោះ វិលមុខស្រវាំងភ្នែក សន្លប់ ប្រកាច់ ពិបាកដកដង្ហើម ឬសង្ស័យថាមាការឆ្លងជំងឺដទៃទៀត សូមប្រញាប់ទៅស្វែងរកការពិនិត្យ ពិគ្រោះនៅមន្ទីរពេទ្យរដ្ឋដែលនៅជិតផ្ទះរបស់អ្នក៕







# ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ផ្តល់ម៉ាស់ចំនួន៥ម៉ឺនម៉ាស់ជូនដល់ក្រសួងធម្មការនិងសាសនា





*អត្ថបទ៖ កែវ កញ្ញា*

ក្នុងអំឡុងពេលរីករាលដាលនៃកូវីដ១៩ក្នុងរាជធានី និងខេត្ត ព្រះសហគមន៍កាតូលិកភូមិភាគ ភ្នំពេញបានជូនម៉ាស់ដល់ក្រសួងធម្មការនិងសាសនាដើម្បីចូលរួមប្រយុទ្ធប្រឆាំងនិងការឆ្លងរាលដាលនៃជំងឺនេះ។

កម្មវិធីនេះ ធ្វើឡើងក្រោមអធិបតីភាពលោក ផ្លោក ផន រដ្ឋលេខាធិការប្រចាំការនៃក្រសួងធម្មការ និងសាសនា និងលោកបូជាចារ្យ សិលា សួន ហង្សលី ជាតំណាងពេញសិទ្ធិលោកអភិបាលអូលីវីយេ៉ ផ្មិតហាស្លេរនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ។

លោកបូជាចារ្យសួន ហង្សលី បានអានលិខិតរបស់លោកអភិបាលអូលីវីយេ៉ អំពីចំនួនម៉ាស់ដែលបានផ្តល់ជូន និងសកម្មភាពមនុស្សធម៌មួយចំនួនដែលព្រះសហគមន៍កាតូលិកបានធ្វើក្នុងអំឡុងពេលនៃការបិទខ្ទប់រាជធានី និងក្រុងតាខ្មៅនៃខេត្តកណ្តាលនាពេលកន្លងមក។

គួរបញ្ជាក់ថា នាពេលកន្លងមកនេះ ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ក្រោមការដឹកនាំរបស់លោកអភិបាលអូលីវីយេ៉ ចាប់ពីថ្ងៃទី១៤ ខែមេសាមក អង្គការការីតាសបានចែកកញ្ចប់ស្បៀងអាហារដល់ប្រជាពលរដ្ឋជាង៤០០០គ្រួសារមកហើយ ឯព្រះសហគមន៍កាតូលិក បានចែកដល់គ្រួសារចំនួន១០០០គ្រួសារ មានទាំងអង្ករ សាច់ជ្រូក និងបន្លែ នៅក្នុងភូមិសាស្រ្តរាជធានីភ្នំពេញ និងតាខ្មៅ៕

# ក្រុមយុវជនរបស់ព្រះសន្តយ៉ូសែបក្តុលលើ ចែកម៉ាសជូនគ្រួសារចំនួន៥០គ្រួសារ





*អត្ថបទ៖ ហៀម សុកខុន*

ក្រុមយុវជនរបស់ព្រះសន្តយ៉ូសែបក្តុលលើ បានចាប់ផ្តើមសកម្មភាពរបស់ខ្លួនជាថ្មីម្តងទៀត ដោយការដើរសុខទុក្ខបងប្អូនគ្រីស្តបរិស័ទ នៅតាមផ្ទះ រួមទាំងបានចែកម៉ាសចំនួន៥០គ្រួសារថែមទៀតផង កាលពីថ្ងៃទី២៦ ឧសភា ២០២១ កន្លងទៅនេះ។

កញ្ញា ឌី សុខលី តំណាងក្រុមយុវជនបានឲ្យដឹងថា ជាធម្មតា ក្រុមយុវជនបានធ្វើសកម្មភាពសួរសុខទុក្ខនេះជាប្រចាំខែ ឬសប្តាហ៍ តែដោយសារកូវីដ-១៩ រាល់សកម្មភាពរបស់ក្រុមត្រូវបានផ្អាក ព្រោះដើម្បីរក្សារគម្លាតរវាងគ្នា ដើម្បីចៀសឆ្ងាយពីជំងឺកូវីដ-១។ កញ្ញា បន្តថា ទោះបីព្រះវិហារត្រូវបានផ្អាកមិនឲ្យជួបជុំគ្នាមនុស្សច្រើនជាច្រើនខែមកហើយ ប៉ុន្តែក្រុមយុវជនក៏ដូចជាគ្រីស្តបរិស័ទនៅតែបន្តជំនឿរបស់ខ្លួន ដោយការអធិដ្ឋាន និងថ្វាយអភិបូជា ក៏ដូចជាចែករំលែកក្តីស្រឡាញ់ឲ្យគ្នាទៅវិញទៅមក ដោយការសួរសុខទុក្ខគ្នាជាធម្មតា តែក៏ត្រូវចូលរួមការពារនិងរក្សារគម្លាតជាដាច់ខាត។

កញ្ញា សុខលី បានប្រាប់ទៀតថា ម៉ាសដែលពួកគាត់ យកមកចែក ជូនគ្រីស្តបរិស័ទ គឺទទួលបានមកពីលោក អភិបាល ប៊្រុយណូ កូសម៍ ជាអភិបាលភូមិភាគកំពង់ចាម ដើម្បីទុកប្រើប្រាស់ក្នុងព្រះសហគមន៍ និងដើម្បីជាចំណែកមួយទប់ស្កាត់ពីជំងឺកូវីដ-១៩ នាពេលបច្ចុប្បន្ន។

រោយមកលោកបូជាចារ្យ ដានីញែល លី រួមនិងយុវជនបានសម្រេចយកម៉ាសមួយចំនួននេះមកចែកជូនដល់គ្រួសារអ្នកភូមិ ចំនួន៥០ ដែលក្នុងមួយគ្រួសារទទួលបាន១ប្រអប់ ដែលមានចំនួន៥០ម៉ាស់។

ព្រះសហគមន៍ក្តុលលើស្ថិតនៅក្នុងភូមិ ក្តុលលើ ឃុំទ្រា ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ៕

# ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញបង្កើតយុទ្ធនាការ សម្រាប់ទិវាកុមារអន្តរជាតិពេញមួយខែមិថុនា នេះ

*អត្ថបទ៖ ដាលីស*

ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញគ្រោងនឹងរៀបចំយុទ្ធនាការទិវាសិទ្ធិកុមារអន្តរជាតិ នាថ្ងៃអាទិត្យខាងមុខនេះ។ យុទ្ធនាការនេះ ខុសប្លែកពីព្រឹត្តិការណ៍ដែលធ្លាប់តែធ្វើឡើងជារៀងរាល់ឆ្នាំ ដោយសារតែប្រទេសកម្ពុជាក៏ដូចជាពិភពលោកកំពុងជួបនឹងបញ្ហាការរីករាលដាលនៃវីរុសកូវីដ-១៩។

ព្រះសហគមន៍ភូមិភាគភ្នំពេញ ដែលដឹកនាំដោយការិយាល័យយុវជនជំទង់ និងកុមារ ចាប់ផ្តើមរៀបចំយុទ្ធនាការ១មិថុនាស្តីពីសិទ្ធិកុមារអន្តរជាតិចំពោះកុមារដែលមានអាយុចាប់ពី៥ឆ្នាំដល់១៣ឆ្នាំ រយៈពេលជិតមួយខែ ដោយគិតចាប់ពីថ្ងៃអាទិត្យសប្តាហ៍ទីមួយនៃខែមិថុនានេះ រហូតដល់ថ្ងៃអាទិត្យចុងខែមិថុនា ឆ្នាំ ២០២១ នេះ។



យុទ្ធនាការនេះនឹងធ្វើដោយមេក្រុមកាយឫទ្ធិនៅតាមតំបន់រៀងៗខ្លួន តាមរយៈការចុះទៅសួរសុខទុក្ខ និងអប់រំតាមផ្ទះកុមារផ្ទាល់។

លោក ស៊ាន់ សារឿន ប្រធានការិយាល័យយុវជនជំទង់ និងកុមារ បានឱ្យដឹងថា ឆ្នាំនេះការិយាល័យលោកបានរៀបចំយុទ្ធនាការ ដោយមានសម្ភារៈអប់រំដល់កុមារឱ្យមានការយល់ដឹងពីសិទ្ធិ និងសេរីភាពរបស់ខ្លួននៅក្នុងសង្គម។

លោកថា ៖ «ក្នុងរយៈពេល៤សប្តាហ៍នេះតាមរយៈមេកាយឫទ្ធិនឹងទៅអប់រំកុមារកាយឫទ្ធិតាមផ្ទះជារៀងរាល់ថ្ងៃ ដើម្បីលើកទឹកចិត្តកុមារព្រមទាំងចែកកញ្ចប់អនុស្សាវរីយ៍ដល់កុមារផងដែរ ដោយពួកគាត់ប្រកាន់ខ្ជាប់នូវការអនុវត្តន៍ជានិច្ចតាមវិធានសុខាភិបាល»។

លោកសារឿន បានបន្ថែមថា គោលបំណងរបស់ព្រះសហគមន៍ គឺធ្វើឡើងដើម្បីធ្វើយ៉ាងណាជួយឱ្យកុមារយល់ពីតម្លៃ និងសិទ្ធិធំៗរបស់ពួកគាត់ទាំង៤ច្បាស់ ព្រមទាំងឱ្យកុមារទទួលបានអំណរសប្បាយតាមរយៈការបង្កើតកម្មវិធីនេះផងដែរ ជាពិសេសចង់បង្ហាញពីការយកចិត្តទុកដាក់ពីព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញចំពោះកុមារ។

ប្រធានការិយាល័យយុវជនជំទង់ និងកុមាររូបនេះ បានឱ្យដឹងទៀតថា ៖ «អ្វីដែលសំខាន់ជាងនេះគឺចង់បញ្ជ្រាបកុមារឱ្យយល់ដឹងអំពីការអប់រំរបស់លោកអភិបាលអូលីវីយេ នៅក្នុងបរិបទកូវីដ-១៩នេះដោយផ្តោតសំខាន់លើ៣ចៃរក្សាគឺ ការទទួលខុសត្រូវ សាមគ្គីភាព និងអធិដ្ឋាន»។

លោកបន្តថា ព្រះសហគមន៍នឹងអប់រំ កុមារឱ្យដឹងថា ក្នុងនាមជាកុមារត្រូវធ្វើអ្វីខ្លះនៅក្នុង៣ចៃរក្សានេះ ជាពិសេសសម្រាប់កុមារដែលនៅក្នុងគ្រួសារកាតូលិក ត្រូវចូលរួមអធិដ្ឋានជាមួយនឹងឪពុកម្តាយ ហើយឪពុកម្តាយក៏ត្រូវណែនាំនិងរំឭកកូនៗ និងធ្វើជាគំរូសម្រាប់កូនផងដែរ។

លោក សារឿន បានបញ្ជាក់ទៀតថា ការអប់រំពីសិទ្ធិរបស់កុមារនេះមានសារសំខាន់ ដើម្បីឱ្យពួកគេយល់ដឹងពីសិទ្ធិផ្ទាល់ខ្លួនរបស់ពួកគេទាំងការរៀនសូត្រ ការថែទាំព្យាបាល អំណរសប្បាយ និងមានជីវិត គឺឱ្យកុមារយល់ថាគេមានតម្លៃនៅក្នុងការរស់នៅ និងនៅក្នុងគ្រួសារ ដោយស្ថិតក្នុងក្របខណ្ឌជាកុមារ។

ជាងនេះទៅទៀត ទិវាកុមារអន្តរជាតិនេះធ្វើឱ្យកុមារទទួលបានប្រយោជន៍ជាច្រើន ដោយជួយឱ្យកុមារទទួលបានការការពារថែរក្សាពីមនុស្សជុំវិញខ្លួន ចៀសវាងការបិទសិទ្ធិកុមារក្នុងការរៀនសូត្រតាមរយៈការអប់រំនេះ។ នេះបើតាមការលើកឡើងរបស់លោក សារឿន។ លោកសារឿនបានបន្ថែមថា ការគាំពារថែរក្សាកុមារ មិនមែនមានត្រឹមតែនៅក្នុងគ្រួសារទេ ប៉ុន្តែនៅគ្រប់កន្លែង គឺអ្នកដែលនៅជុំវិញកុមារ ដោយសង្គមទាំងមូលត្រូវយកចិត្តទុកសាក់លើកុមារជាអាទិភាព ព្រោះកុមារជាទំពាំងមួយដែលត្រូវការថែទាំដើម្បីអនាគតសង្គម៕

# គណៈកម្មការសង្គហៈព្រះវិហារសន្តប៉ូលនៃព្រះសហគមន៍ កោះស្លា មណ្ឌលសកម្មភាពកំពត ចែកគ្រឿងបរិភោគ

*អត្ថបទ៖ ដាលីស*

ក្នុងខែឧសភា ២០២១នេះ គ្រីស្តបរិស័ទនៅព្រះសហគមន៍ សន្តប៉ូលកោះស្លានៃមណ្ឌលសកម្មភាពកំពត រួមមានតំណាងក្រុមសង្គហៈ តំណាងក្រុមយុវជន និងតំណាងក្រុមកាយឫទ្ធិ ដែលដឹកនាំដោយលោកបូជាចារ្យ យ៉ាំង លូកា បាននាំយក ស្បៀងអាហារមួយចំនួនទៅចែករំលែកដល់បងប្អូនចំនួន៩គ្រួសារ ដែលកំពុងតែស្រេកដង្ហោយហៅឱ្យពួកយើងជួយក្នុងគ្រាដ៏លំបាកនេះ ចំនួន ៣ គ្រួសារ ដែលរស់នៅក្នុងភូមិស្រែលាវ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពតដើម្បីឱ្យពួកគាត់មានចិត្តសង្ឃឹម អាចតស៊ូ អត់ធ្មត់នឹងដំណើរជីវិតរបស់ពួកគាត់នាសម័យកូវីដ១៩នេះ។







លោកបូជាចារ្យទទួលបន្ទុកមណ្ឌលសកម្មភាពកំពត យ៉ាំង លូកា បានមានប្រសាសន៍ថា៖ ព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់គឺធំធេងខ្លាំងណាស់ដល់ពួកកូនម្នាក់។ លោកបន្ថែមថា វិន័យរបស់ខ្ញុំគឺ ត្រូវស្រលាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ ហើយការចែករំលែកសេចក្តីស្រឡាញ់ទៅដល់អ្នកតូចតាច ក៏ដូចជាបានធ្វើតាមវិន័យនេះដែរ។

លោក សិលា ចាន់ម៉ានុត តំណាងគណៈកម្មការចម្រុះនៃព្រះវិហារសន្តប៉ូល កោះស្លា បានឱ្យប្រាប់ថា ព្រះសហគមន៍បានសម្តែងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់នេះ ជាសកម្មភាពមួយដ៏ល្អសម្រាប់បងប្អូនដែលកំពុងតែពិបាក អស់សង្ឃឹម ឱ្យមានការតស៊ូ និងមានក្តីសង្ឃឹមឡើងវិញ។ ម៉ានុតបន្ថែមថា ទោះបីជាមិនបានច្រើនក៏អាចដោះទាល់បានមួយគ្រាដែរ។ ប្រធានក្រុមយុវជន ម៉ានុត បញ្ជាក់ថា ម្យ៉ាងទៀត ការសម្តែងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់នេះ គឺជាសកម្មភាពមួយដ៏ល្អវិសេសចំពោះបងប្អូនដែលកំពុងអស់សង្ឃឹមនិងស្រេកដង្ហោយឱ្យជួយ។ ដូច្នេះតួនាទីរបស់ពួកយើងជាគ្រីស្តបរិស័ទត្រូវចេះចែករំលែកសេចក្តីស្រឡាញ់ដែលទទួលពីព្រះជាម្ចាស់ ដើម្បីធ្វើឱ្យពួកគាត់មានអំណរសប្បាយ មានការតស៊ូប្រឹងប្រែងក្នុងគ្រាដ៏លំបាកនេះ។ យុវជនម៉ានុត ស្នើដល់គ្រីស្តបរិស័ទទាំងអស់ សូមកុំបង្អង់ដៃក្នុងការជួយដល់បងប្អូនដែលមានការលំបាកក្នុងសម័យកូវីដ១៩នេះ។





ដោយសារស្ថានភាពបច្ចុប្បន្ននេះមិនអំណោយផលចំពោះការជួបជុំគ្នាច្រើនបាន ព្រះសហគមន៍កោះស្លា បានចែកគ្នាទៅចែកស្បៀងអាហារតាមផ្ទះដោយចែកជាក្រុមតូចៗមានគ្នាតិច។ សកម្មភាពនេះធ្វើឡើងរៀងរាល់សប្តាហ៍ ដើម្បីចូលរួមជាមួយរាជរដ្ឋាភិបាល ក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ។

ជនក្រីក្រទាំងនោះទទួលបានអង្ករដែលជាអង្ករក្នុងព្រះសហគមន៍ និងធ្វើដោយបងប្អូនគ្រីស្តបរិស័ទផ្ទាល់២០គីឡូក្រាមក្នុងមួយគ្រួសារ ទឹកត្រី ២ដប មីមួយកេស ត្រីខមួយយួរ និងម៉ាសផងដែរ៕

# លោកអភិបាលអូលីវីយេ ចុះសួរសុខទុក្ខ បងប្អូនកំពុងធ្វើចត្តាឡីស័ក និងអាជ្ញាធរមូលដ្ឋាន





*អត្ថបទ៖ ដាលីស*

លោកអភិបាល អូលីវីយេ អភិបាលព្រះសហគមន៍កាតូលិកកម្ពុជាភូមិភាគភ្នំពេញបានអញ្ជើញទៅសួរសុខទុក្ខដល់បងប្អូនដែលកំពុងចត្តាឡីស័កចំនួន២កន្លែងនារសៀលថ្ងៃទី ១០ ខែឧសភា ឆ្នាំ២០២១។

មណ្ឌលចត្តាឡីស័កទាំងពីររួមមាន៖ ទី១ មណ្ឌលចត្តាឡីស័ក វិទ្យាល័យសម្តេចក្រុមព្រះអង្គរនាប ស្ថិតនៅឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ។ ទី២.មណ្ឌលចត្តាឡីស័ក សាលាបឋមសិក្សាសំណាប ស្ថិតនៅឃុំញ៉ៀងញ៉ង ស្រុកត្រាំកក់ ខេត្តតាកែវ។

ក្នុងពេលជាមួយបងប្អូនប្រជាពលរដ្ឋ និងអាជ្ញាធរ លោកអភិបាល បានមានប្រសាសន៍លើកទឹកចិត្តដល់បងប្អូនដែលកំពុងជាប់ចត្តាឡីស័កឱ្យយកចិត្តទុកដាក់ថែរក្សាអនាម័យរស់នៅចេះការពារខ្លួន និងគោរពនូវវិធានការ «៣កុំ ៣ការពារ» ឱ្យបានខ្ជាប់ខ្ជួន។ ចំពោះអាជ្ញាធរ លោកបានថ្លែងអំណរគុណដល់លោកមេឃុំ ក្រុមប្រឹក្សាឃុំ កម្លាំង ប្រជាការពារទាំងអស់ដែលបានចូលរួម និងខិតខំរួមគ្នាទប់ស្កាត់ជំងឺកូវីត-១៩ នេះ។ លោកអភិបាលក៏បានជូនពរ និងប្រទានពរដល់បងប្អូនទាំងអស់ឱ្យមានសេចក្តីសុខ កម្លាំងកាយចិត្តមាំមួន និងជៀសផុតពីកូវីដ-១៩ ទាំងអស់គ្នា។

ក្នុងឱកាសដ៏ថ្លៃថ្លានេះផងដែរ លោកអភិបាលបានពាំនាំសម្ភារមួយចំនួនជូនដល់បងប្អូនដែលកំពុងជាប់ចត្តាឡីស័ក មានមីកញ្ចប់ម៉ាម៉ា ១យួរ សាប៊ូ (បោកខោអាវ ដុសខ្លួន កក់សក់) ម៉ាស់១ប្រអប់ និងថវិការ២ម៉ឺនរៀល។ ឧបត្ថម្ភដល់ឃុំទាំងពីរគឺឃុំត្រាំកក់ និងឃុំញ៉ៀងញ៉ង មានម៉ាសចំនួន៥០០០ ម៉ាសទឹកសុទ្ធចំនួន២០០យួរ ភេសជ្ជៈចំនួន៦កេស និងថវិការចំនួន៤០ម៉ឺនរៀល។

អាជ្ញាធរឃុំទាំង២ បានថ្លែងអំណរគុណលោកអភិបាលអូលីវីយេដែលបានយកចិត្តទុកដាក់សុខទុក្ខរបស់ប្រជាពលរដ្ឋ ព្រមទាំងបានជួយឧបត្ថម្ភជាសម្ភារសម្រាប់ជួយសម្រួលការលំបាករបស់ប្រជាពលរដ្ឋក៏ដូចអាជ្ញាធរផង ក្នុងពេលប្រយុទ្ធប្រឆាំងនឹងកូវីដ-១៩នាពេលនេះ៕








# កូវីដ-១៩ បង្កឲ្យមានអ្នកក្រីក្រច្រើន ទាំងជីវភាព និងផ្លូវវិញ្ញាណ





*អត្ថបទ៖ ដាលីស*

«ខ្ញុំឃើញអ្នកក្រីក្រមានច្រើន ទាំងជីវភាព និងផ្លូវវិញ្ញាណ» នេះជាប្រសាសន៍របស់លោក យ៉ុង បូជាចារ្យទទួលខុសត្រូវព្រះសហគមន៍ទួលក្រសាំង ព្រះវិហារសន្តយ៉ូសែប នៃព្រះសហគមន៍មណ្ឌលសកម្មភាពទន្លេបាសាក់។

លោកមានប្រសាសន៍ដូចនេះ បន្ទាប់ពីលោកបានចុះទៅសួរសុខទុក្ខប្រជាពលរដ្ឋដែលកំពុងតែជួបទុក្ខលំបាកក្នុងបរិបទកូវីដ-១៩ ដែលកំពុងតែរាតត្បាតនៅក្នុងប្រទេសកម្ពុជា ជាពិសេសក្នុងរាជធានីភ្នំពេញ និងខេត្តកណ្ដាល កាលពីពេលថ្មីៗនេះ។

លោកបូជាចារ្យរូបនេះ មានប្រសាសន៍បន្តថា អ្នកខ្លះក្រ ពួកគេខ្វះខាតស្បៀងអាហារច្រើនណាស់។ ប្រសិនបើស្ថានភាពកូវីដនៅបន្តយូរទៀត មិនដឹងថាមានវិធីណាដើម្បីជួយពួកគាត់ឱ្យបានប្រសើរនោះទេ។

ក្នុងអំឡុងពេលកូវីដ-១៩ កំពុងរាតត្បាតតាំងពីកន្លងមក និងសព្វថ្ងៃ ព្រះវិហារសន្តយ៉ូសែប នៃព្រះសហគមន៍មណ្ឌលសកម្មភាពទន្លេបាសាក់ ក្នុងភូមិរការខ្ពស់ ស្រុកស្អាង ខេត្តកណ្ដាល នៅតែបន្តសកម្មភាពមេត្តាករុណា និងចុះទៅសួរសុខទុក្ខប្រជាជននៅក្នុងតំបន់ ដោយនាំយកស្បៀងអាហារដើម្បីជួយជនក្រីក្រកដោះទ័លក្នុងរយៈពេលខ្លីផងដែរ។

លោកបូជាចារ្យ យ៉ុង មានប្រសាសន៍ទៀតថា «ខ្ញុំឃើញទៀតថាអ្នកក្រីក្រយើងមានច្រើន មានទាំងក្រីក្រខាងជីវភាព និងក្រីក្រខាងជីវិតផ្លូវវិញ្ញាណ»។

លោកបានបន្តថា៖«សម្រាប់គ្រីស្តបរិស័ទដែលទីទាល់ក្រ នៅពេលដែលយើងជួយដល់ពួកគាត់ជាអ្នកក្រីក្រ ធ្វើឱ្យជំនឿរបស់គាត់មិនបាត់បង់នោះទេ ទោះបីពួកគាត់ខ្វះខាតក៏ដោយ ហើយសព្វថ្ងៃពួកគាត់កំពុងតែស្រេកឃ្លានអាហារខាងផ្លូវវិញ្ញាណពិសេស ពួកគាត់ចង់ចូលព្រះវិហារដើម្បីចូលរួមថ្វាយអភិបូជា ចង់ចួបមុខព្រះជាម្ចាស់តាមព្រះសហគមន៍»។

លោកបូជាចារ្យ បង្ហាញក្ដីរំពឹងដោយមានប្រសាសន៍ថា សង្ឃឹមថាបញ្ហាកូវីដនឹងអាចបញ្ចប់ក្នុងពេលឆាប់ៗខាងមុខនេះ ដើម្បីឱ្យអ្នកដែលខ្វះខាតអាចទទួលបានក្ដីសង្ឃឹមជាថ្មី ទាំងការប្រកបរបរអាជីវកម្ម និងទទួលបានអាហារខាងផ្លូវវិញ្ញាណផងដែរ៕

# គ្រួសាររងគ្រោះដោយធាក់ផ្ទះ ទទួលសង្គ្រោះបន្ទាន់ពីព្រះសហគមន៍កាតូលិក

*អត្ថបទ៖ ដាលីស*



គ្រួសារជនរងគ្រោះជាង១០គ្រួសារ ទទួលជំនួយសង្គ្រោះបន្ទាន់ពីព្រះវិហារសន្តអង់ទន់ ព្រែកដាច់ បន្ទាប់ពីការបាក់ដី និងលំនៅឋានចូលក្នុងទន្លេ ក្នុងភូមិព្រែកដាច់ ស្រុកលើកដែក ខេត្តកណ្ដាល នាថ្ងៃ ២៥ ឧសភា ២០២១ តាមរយៈលោកបូជាចារ្យ ទទួលខុសត្រូវព្រះសហគមន៍ ដានីញ៉ែល យ៉ុន ជាអ្នកសម្របសម្រួល។

លោកបូជាចារ្យ ដានីញ៉ែល មានប្រសាសន៍ថា ព្រះសហគមន៍ព្រែកដាច់តែងតែស្វាគមន៍បងប្អូនទាំងអស់ដែលមានទុក្ខលំបាក ជាពិសេសចំពោះបងប្អូនដែលបាត់បង់ផ្ទះសម្បែងកាលពីពេលថ្មីៗកន្លងមកនេះ។ លោកបន្តថា ព្រះសហគមន៍តែងតែបើកទ្វារចំហររង់ចាំទទួលពួកគាត់ជានិច្ច។

តាមការបញ្ជាក់របស់លោកបូជាចារ្យដានីញ៉ែល បានឱ្យដឹងថា ក្នុងចំណោមក្រុមគ្រួសាររងគ្រោះទាំងនោះមាន៤គ្រួសារជាគ្រីស្តបរិស័ទកាតូលិក និងបច្ចុប្បន្នកំពុងរស់នៅបណ្ដោះអាសន្ននៅក្នុងព្រះវិហារសន្តអង់ទន់ និងប៉ុន្មានគ្រួសារផ្សេងទៀតកំពុងស្នាក់អាស្រ័យបណ្ដោះអាសន្នជាមួយបងប្អូនសាច់ញាតិរបស់ពួកគេ។

ផ្ទះរបស់ប្រជាពលរដ្ឋជាង១០គ្រួសារ ត្រូវបានបាក់ចូលក្នុងទឹកទន្លេ នាថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២១ កន្លងទៅនេះ។

លោកដានីញ៉ែលខណៈពេលនេះព្រះសហគមន៍កំពុងតែពិភាក្សាគ្នារកកន្លែងថ្មី ដើម្បីឲ្យពួកគាត់ស្នាក់នៅបណ្ដោះអាសន្ន។ លោកបន្ថែមថា «ខ្ញុំក៏បានធ្វើវីដេអូអំពីស្ថានភាពទាំងនេះជាភាសាកូរ៉េនៅក្នុងបណ្ដាញសង្គម ដើម្បីស្វែងរកជំនួយផងដែរ ទោះបីជាមានអ្នកមើលតិចតួច ប៉ុន្តែពួកគេមានចំណាប់អារម្មណ៍។ ដូច្នេះខ្ញុំសង្ឃឹមថា យើងនឹងអាចដោះស្រាយដោយអធិដ្ឋាន ពឹងផ្អែកលើជំនឿរបស់យើង និងបងប្អូនក្នុងព្រះសហគមន៍»។

លោកបូជាចារ្យ បន្ថែមថា មិត្តភក្តិខ្ញុំជាបូជាចារ្យកូរ៉េ កំពុងតែពិភាក្សាគ្នា ដើម្បីជួយតាមស្ថានភាពជាក់ស្តែង អាចជាថវិកា ឬសម្ភារផ្សេង។

លោកអភិបាលអូលីវីយ៉េ គ្រោងនឹងទៅសួរសុខទុក្ខបងប្អូនជាង១០គ្រួសារ ដើម្បីលើកទឹកចិត្ត និងផ្ដល់ក្ដីសង្ឃឹមដល់ពួកគាត់ក្នុងគ្រាមានលំបាកនេះ។

ជំនួយសង្គ្រោះបន្ទាន់ដែលព្រះសហគមន៍បានចែកជូននេះ រួមមាន៖ អង្ករ១០០គីឡូក្រាមក្នុងមួយគ្រួសារ និងសម្ភារប្រើប្រាស់ចាំបាច់ក្នុងការរស់នៅប្រចាំថ្ងៃ ដែលបានមកពីការបរិច្ចាគរបស់ក្រុមគ្រួសារបងស្រីសន្តប៉ូលនៅប្រទេសកូរ៉េ ផ្ញើជូនព្រះសហគមន៍ដើម្បីឆ្លើយតបបន្ទាន់នូវតម្រូវការរបស់បងប្អូន៕

# ព្រះសហគមន៍ភូមិភាគកំពង់ចាមផ្ដល់ម៉ាស់ និងអាកុលសម្លាប់មេរោគដល់ក្រុមការងារ ចុះមូលដ្ឋានឃុំអំពិលនៃខេត្តស្វាយរៀង



*អត្ថបទ៖ រឿន ស្រីម៉ាច*

លោកប្រ៊ុយណូ កូសម៍អភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម និងសហការី បាននាំយកនូវម៉ាស់ចំនួន២០.០០០ម៉ាស់ និងទឹកអាកុលសម្លាប់មេរោគចំនួន៤០លីត្រ ជូនលោក ហ៊ឹម វិបុលឫទ្ធិ អគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការសាសនា ជំនួសក្រុមការងារចុះមូលដ្ឋាន ឃុំអំពិលនៃខេត្តស្វាយរៀង កាលពីថ្ងៃសុក្រ ទី១១ ខែមិថុនា ឆ្នាំ២០២១ នៅក្រសួង ធម្មការ និងសាសនា រាជធានីភ្នំពេញ។

លោកអភិបាល ប្រ៊ុយណូ កូសម៍ មានប្រសាសន៍ថា ការផ្ដល់ជូននេះគឺដើម្បីចូលរួមចំណែកជួយសម្រួលក្នុងការប្រើប្រាស់ក្នុងសកម្មភាព ការពារ ទប់ស្កាត់ការរីករាលដាលនៃជម្ងឺកូវីដ-១៩ និងចែកជូនប្រជាជនមួយចំនួនតាមការជាក់ស្ដែង នៅក្នុងឃុំអំពិល ស្រុករមាលហែក ខេត្តស្វាយរៀងតាមលទ្ធភាព។

លោកអភិបាលបញ្ជាក់ថា៖«ម៉ាស់និងអាកុលនេះមិនមែនសម្រាប់ផ្គត់ផ្គង់បងប្អូននៅភ្នំពេញ គឺជូនតាមរយៈលោក ហ៊ឹម វិបុលឫទ្ធិ ជំនួសក្រុមការងារចុះមូលដ្ឋាន ឃុំអំពិលនៃខេត្តស្វាយរៀង ដើម្បីចូលរួមចំណែកទប់ស្កាត់ការឆ្លងរីករាលដាលជម្ងឺកូវីដ-១៩»។

លោកបានបន្ថែមថា៖ «កន្លងមកព្រះសហគមន៍ភូមិភាគកំពង់ចាម បានចែកជូនម៉ាស់ និងអាកុលនេះទៅតាមកន្លែងផ្សេងៗ ក្នុងភូមិភាគកំពង់ចាម តាមលទ្ធភាព ហើយគោលបំណងជារួមគឺ ចង់ចែករំលែក សេចក្ដីស្រឡាញ់ទៅបងប្អូនផ្សេងៗទៀត ចង់ចូលរួមការពារជម្ងឺកូវីដនេះ ជាពិសេស សម្រាប់ បងប្អូនជាច្រើន ដែលកំពង់ ខ្វះខាត ក្នុងគ្រួសារ»។

ក្នុងនោះផងដែរលោកអភិបាលប្រ៊ុយណូ កូសម៍ រំឭក ប្រជាជនទាំងអស់ឲ្យយកចិត្តទុកដាក់ចូលរួមទប់ស្កាត់ ការពារ ការឆ្លងរីករាលដាលនៃមេរោគឆ្លង កូវីដ-១៩ ដោយគោរពតាមការណែនាំរបស់ក្រសួងសុខាភិបាល ។ លោក សូមព្រះជាម្ចាស់ប្រទានពរបងប្អូនកូនចៅទាំងអស់ឲ្យមានសុខភាពល្អ ឆ្លងផុតគ្រាដ៏លំបាកនេះជាមួយគ្នា និងជួយគ្នាទៅវិញទៅមកក្នុងសេចក្ដីស្រឡាញ់ផង។



លោក ហ៊ឹម វិបុលឫទ្ធិ អគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការសាសនា ជំនួសក្រុមការងារចុះមូលដ្ឋាន ឃុំអំពិលនៃខេត្តស្វាយរៀង សូមថ្លែងអំណរគុណចំពោះទឹកចិត្តសប្បុរសរបស់លោកអភិបាល ក៏ដូចជាព្រះសហគមន៍ភូមិភាគកំពង់ចាមដែលបានចូលរួមចំណែកជួយដោយផ្ដល់ជូននូវម៉ាស់និងអាកុលសម្រាប់ការពារជម្ងឺកូវីដ-១៩ ទៅខាងខេត្តស្វាយរៀងក្នុងគ្រានេះ។

ដោយលោកសង្កត់ធ្ងន់ថា «៖ក្នុងពេលស្ថានភាពប្រទេសកំពុងតែរងនូវបញ្ហាជម្ងឺកូវីដ-១៩នេះអ្វីដែលប្រជាជនត្រូវការបន្ទាប់ពីស្បៀងអាហារនោះគឺម៉ាស់កាពារ និង អាកុលឬដែលសម្លាប់មេរោគដើម្បីការពារខ្លួនពីការឆ្លង»។

លោកបន្ថែមថា៖ «ស្ថានភាពបងប្អូនប្រជាពលរដ្ឋខាងឃុំអំពិល ស្រុករមាសហែក ខេត្តស្វាយរៀងមានការខ្វះខាតនូវម៉ាស់និងអាកុលសម្លាប់មេរោគនេះប្រើប្រាស់មែន ហើយអ្វីដែលសំខាន់ជាងនេះទៅទៀតនោះគឺនៅតំបន់នោះសុទ្ធសឹងជាអ្នកដែលមានជីវភាពខ្វះខាត»។

ប្រទេសកម្ពុជារហូតមកដល់ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១ កម្ពុជារកឃើញ អ្នកឆ្លងមេរោគកូវីដ១៩ សរុបចំនួន៣៧៣២១នាក់ មានអ្នកស្លាប់ ចំនួន ៣១១នាក់ និងអ្នកជាសះស្បើយចំនួន ៣០៦១៧នាក់៕

# សង្គ្រាមប្រឆាំងនឹងកូវីដ១៩!

នៅក្នុងពេលវេលាដែលមេរោគកូវីដ-១៩ផ្ទុះនៅក្នុងខេត្តតាកែវ គឺឱកាសដ៏ល្អដើម្បីទៅសួរសុខទុក្ខបងប្អូននៅក្នុងមណ្ឌលចត្តាឡីស័កនៅក្នុងឃុំគុស និងឃុំត្រាំកក់ និងដើម្បីរំលឹកដល់យើងទាំងអស់គ្នាយើងកំពុងធ្វើសង្គ្រាមប្រឆាំងកូវីដ-១៩។





លោក អភិបាល អេនរីគេ ហ្វីការេដូ (គីគេ) ជូនវត្ថុអនុស្សាវរីយ៍ដល់សម្ដេចប៉ាប ប្រ្វាំងស៊ីស្កូ នៅបុរីវ៉ាទីកង់កាលពីថ្ងៃទី២ ខែមិថុនា ក្នុងពេលសម្ដេចប៉ាប ចេញមកជួបជាមួយមហាជន។ វត្ថុអនុស្សាវរីយ៍ ផលិតដោយស្នាដៃកូនខ្មែរនៅបាត់ដំបង។ រូបនោះតំណាងឲ្យសេចក្ដីស្រលាញ់ដ៏ធំទូលំទូលាយ. មានទស្សនៈវែងឆ្ងាយ និង ការបម្រើដោយចិត្តសុភាពរាបសា។

សកម្មភាពចែករំលែកអំណោយដល់បងប្អូននៅភូមិឧត្តុង ក្រោមការថែទាំរបស់លោកឪពុក ប៉ូល រឿង ឆ័ត្រសិរី ជា បូជាចារ្យទទួលខុសត្រូវមណ្ឌលសកម្មភាពភ្នំពេញខាងជើង នាថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២១ ដែលមានចំនួន១០គ្រួសារ។





គណៈកម្មការព្រះសហគមន៍កាតូលិកត្រែងត្រយឹង នៃមណ្ឌលសកម្មភាពភ្នំពេញថ្មី បាននាំយកម៉ាស់ចំនួន ៧៥០០ម៉ាស់ជូនដល់រដ្ឋបាលឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ដើម្បីចូលរួមចំណែកទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩។

